Samanh EBooks

# ទស្សនៈខ្ញុំគេ

តើខ្ញុំគេគួរគិត និងគួរធ្វើអ្វីខ្លះ?



ហួត សេងតៀ

# មាតិកា


សៀវភៅផ្សេងទៀត

ទំព័រដើម

ការធ្វើការក្នុងពេលសិក្សា

ការធ្វើការក្នុងក្រុមហ៊ុនតូច

ជំនាញ ជាខ្លួន

ប្រាក់ខែ ជាតម្លៃ

ស្រលាញ់ការងារ តែកុំស្រលាញ់ក្រុមហ៊ុន

សេរីភាពនៅកន្លែងការងារ

ការរាប់អានគ្នាក្នុងការងារ

ការបែងចែកពេល

ការលាក់ និងការបញ្ចេញ

ការលើកជើងនៅកន្លែងការងារ

ការងារពីរ

ការលាឈប់ពីការងារ

ទំព័រចុងក្រោយ

# សៀវភៅផ្សេងទៀត

៤ឆ្នាំ

ចរិតឆ្កែ

អាល់ប៊ុមគំនិត ភាគពីរ

ជម្រើសទីពីរ

រើសមកទុកវិញ

រៀនតាមឆាវឆាវ

ជីវិតយើងខ្លីពេក

១០នាទី

ឱ្យគេដេកទៅ

រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ ហួត សេងគៀ

ឆ្នាំ ២០១៧

# ទំព័រដើម

ការមានការងារធ្វើដំបូង ជាពេលដែលយើងមានអារម្មណ៍រំភើប ព្រោះគិតថាខ្លួនបានប្រឡូកនឹងសង្គមពិតប្រាកដ។ យើងរីករាយ ព្រោះយើងអាចរកលុយដោយខ្លួនឯងបាន ឬនិយាយឱ្យចំពាក្យ គឺ រីករាយព្រោះបានធ្វើខ្ញុំគេ។

ខ្ញុំគេ ក៏មិនអាក្រក់ណាស់ណាដែរ ព្រោះយ៉ាងហោចក៏យើងអាចចិញ្ចឹមខ្លួនឯងបាន។ ខ្ញុំមិនប្រកាន់ថា ខ្លួនខ្ញុំ ជាខ្ញុំគេនោះទេ តែខ្ញុំក៏មិនសុខចិត្តធ្វើជាខ្ញុំគេដែលងាប់ក្រឡាដែរ។ រាល់កិច្ចការដែលខ្ញុំធ្វើ សុទ្ធតែបានកត់ទុក ជាពិសេស កិច្ចការណាដែលខ្ញុំយល់ថា សំខាន់ ហើយអាចនឹងមានប្រយោជន៍នៅពេលក្រោយ។ ខ្ញុំគេ គួរតែគិតដល់ថ្ងៃក្រោយ ហើយយកអ្វីដែលបានធ្វើក្នុងថ្ងៃនេះ ទៅប្រើម្តងទៀត។

ដោយសារតែកត់ទុកនេះហើយ ទើបខ្ញុំអាចយកមកអានឡើងវិញ ហើយរៀនយល់ដោយខ្លួនឯងពីរបៀបធ្វើខ្ញុំគេ។ អ្វីក៏មានរបៀបធ្វើដែរ។ ខ្ញុំគេសម័យថ្មី មិនអាចធ្វើដូចខ្ញុំគេជំនាន់ដើមបានទេ។ ខ្ញុំគេបច្ចុប្បន្ន មានការប្រកួតប្រជែងច្រើនណាស់ តែក៏មានឱកាសច្រើនដែរ។ ទោះបីជាចេញមិនផុតពីភាពជាខ្ញុំគេ ក៏យើងអាចនឹងមានសេរីភាពជាងអ្នកដទៃដែរ។

ខ្ញុំគេដូចគ្នា តែមួយជាប់ច្រវាក់ មួយទៀតមិនជាប់ តើយើងចង់បានមួយណា? ខ្ញុំធ្លាប់ជាប់ច្រវាក់ ហើយខ្ញុំក៏ធ្លាប់ត្រូវគេដោះច្រវាក់ឱ្យដែរ ហេតុនេះខ្ញុំអាចឱ្យយោបល់បានថា “អត់ច្រវាក់ជាប់ជើង ស្រួលធ្វើការជាង”។

ក្នុងសៀវភៅនេះ ខ្ញុំនឹងលើកយកបទពិសោធន៍ និងគំនិតផ្សេងៗនៅក្នុងពិភពការងារមកបង្ហាញ។ មិនមែនខ្ញុំមើលងាយថាអ្នកទាំងអស់គ្នា មិនចេះធ្វើការទេ តែអ្នកទាំងអស់គ្នាអាចផ្តោតលើការងារពេក ភ្លេចសង្កេតអ្វីដែលនៅជុំវិញការងារ។ ខ្ញុំជាអ្នកនិពន្ធ ដូច្នេះការសង្កេត ជាតួនាទីរបស់ខ្ញុំ និងជាអ្វីដែលខ្ញុំត្រូវប្រឹងធ្វើឱ្យបានល្អ។

បើមិនចេះសង្កេត ខ្ញុំក៏គ្មានអ្វីសរសេរដែរ។ អ្នកទាំងអស់គ្នាមិនបាច់ខាតពេលសង្កេតទេ អានសៀវភៅរបស់ខ្ញុំ ក៏អាចបានតម្រុយច្រើនដែរ។

សៀវភៅទស្សនៈខ្ញុំគេ នឹងបង្ហាញពីរបៀបដែលយើងអាចធ្វើខ្ញុំគេ ដោយមិនត្រូវគេដើរខ្សែលើគ្រប់ពេល។ យើងជាខ្ញុំគេហេតុនេះទំនួលខុសត្រូវរបស់យើង តូចជាងចៅកែឆ្ងាយណាស់។ បើយើងមិនហ៊ានទទួលស្គាល់ថាខ្លួនយើងជាខ្ញុំគេ ហើយមិនធ្វើអ្វីដែលខ្ញុំគេត្រូវធ្វើ តែបែរជាវង្វេងតាមអ្វីដែលចៅកែនិយាយ យើងនឹងរស់ដើម្បីអ្នកដទៃមួយជីវិត។

ហួត សេងគៀ

# ១

# ការធ្វើការក្នុងពេលសិក្សា

ឪពុកម្ដាយក្រ តែងតែប្រឆាំងគំនិតកូន នៅពេលលឺថាកូនចង់រកការងារធ្វើ ទាំងខ្លួនឯងកំពុងរៀនសូត្រ។ គាត់គិតបែបនេះ ព្រោះខ្លាចកូនទ្រាំមិនបាន ហើយបោះបោលការសិក្សា។ ឪពុកម្ដាយក្រ មិនអាចរកវិធីបង្រៀនកូនឱ្យបានខ្ពស់ក្នុងផ្នែកជីវភាពទេ ហេតុនេះគាត់មានតែពឹងទាំងស្រុងទៅលើការសិក្សា។ គាត់មិនដឹងថា វាជួយអ្វីបានខ្លះទេ ព្រោះគាត់ក៏មិនធ្លាប់រៀនបានខ្ពស់ដែរ។

នេះជាការគិតរបស់ពួកគាត់។ យើងជាកូនគ្មានអ្វីត្រូវទៅហាមគាត់កុំឱ្យគិតបែបនេះទេ។ អ្វីដែលយើងត្រូវធ្វើ គឺអ្វីដែលយើងគិតថាត្រូវ។ បើយើងមើលឃើញថា ការរកការងារធ្វើ អាចជួយយើងបានច្រើន យើងគួរតែសាកល្បង។ បើការងារមួយជួយមិនបាន ចាំរកមួយទៀតទៅ ក៏វាមិនហួសពេលដែរ។

មានអ្នកលេងហ្វេសប៊ុកម្នាក់ផ្ញើសារមកសួរខ្ញុំពីរឿងរកការងារធ្វើ។ គាត់រៀនពេញម៉ោង ហេតុនេះចង់បានការងារសៅរ៍-អាទិត្យធ្វើសាក។ គាត់ប្រាប់ថា គាត់ប្រឡងធ្លាក់ ហេតុនេះត្រូវរៀនសងគេ។ ខ្ញុំគ្មានយោបល់ក្នុងរឿងការងារក្រៅម៉ោងបែបនេះទេ ព្រោះខ្ញុំគិតថា បើធ្វើរបៀបនេះ គឺធ្វើបាបខ្លួនហើយ។ គោលបំណងរកការងារធ្វើ គឺដើម្បីជួយខ្លួនឯង មិនធ្វើបាបខ្លួនឯងទេ។ រៀន៥ថ្ងៃ ធ្វើការ២ថ្ងៃ តើមានពេលសម្រាកដែរ? ហេតុអ្វីមិនសាកធ្វើការផង និងរៀនផងក្នុងថ្ងៃតែមួយ?

# មូលហេតុទីមួយដែលយើងទៅរៀន

យើងទៅរៀនដើម្បីអាចចេញធ្វើការបាន ឬបង្កើតមុខរបរផ្ទាល់ខ្លួន។ អ្នកដែលងប់នឹងរៀន តែមិនអាចធ្វើអ្វីបាន ជាមនុស្សគ្មានប្រយោជន៍។ រៀនធ្វើអី បើរៀនរាប់ឆ្នាំហើយនៅតែសុំលុយម៉ែចាយដដែល។ អ្នករៀនខ្លះ អាងម៉ែឪស្រលាញ់ ក៏មិនរវីរវល់នឹងរឿងរកការងារធ្វើ។ ដោយសារតែមានអាង និងមានលេសថារៀនបន្ត ធ្វើឱ្យមនុស្សក្លាយជាអត់ដឹងអី មិនចង់ធំ និងស្រលាញ់សាលាផ្កាប់មុខ។

កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំគិតមិនដាច់ថា តើការរៀនផង ធ្វើការផង និងការរៀនតែមួយមុខ មួយណាល្អជាង។ ឥលូវខ្ញុំបានចម្លើយហើយ ព្រោះខ្ញុំឃើញក្មេងដែលរៀនក្រោយខ្ញុំ កំពុងជួបបញ្ហា។ បញ្ហារបស់ពួកគេ គឺរៀនចប់ អត់ការងារធ្វើ។

យើងគួរតែធ្វើការក្នុងពេលរៀន ដើម្បីឱ្យចេះសម្របនឹងការរស់នៅ។ បើល្អបំផុត គឺពេលកំពុងរៀនឆ្នាំទីមួយ ឬទីពីរតែម្តង។ យើងធ្វើការដើម្បីដឹងថា តើគេប្រើអ្វីនៅក្នុងការងារ និងកុំឱ្យគ្រូបោកថា មេរៀននេះសំខាន់ ឬចំណុចនេះគេប្រើច្រើន។ គ្រូខ្លះបានតែបង្រៀនប៉ុណ្ណោះ ពេលធ្វើការមែនទែន មិនកើតដូចតែគ្នា។ យើងគួរតែដឹងថា ការបង្រៀន ពឹងលើការត្រៀមច្រើនជាងសមត្ថភាព។ បើគ្រូត្រៀមបានល្អ ទោះបីគាត់មិនធ្លាប់ធ្វើដោយផ្ទាល់ដៃ ក៏គាត់អាចបង្រៀនបានដែរ គ្រាន់តែមិនសូវមានប្រសិទ្ធិភាពសម្រាប់សិស្ស។

យើងត្រូវចាំមូលហេតុដែលយើងទៅរៀនទុក ហើយរកឱកាសដើម្បីរកការងារធ្វើ។ ខ្ញុំមិននិយាយពីការងារស្ម័គ្រចិត្ត ឬការងារកំប៉ិកកំប៉ុកដែលគេបោកយើងថា អាចផ្តល់បទពិសោធន៍ឱ្យយើងនោះទេ។ ខ្ញុំនិយាយដល់ការងារមែនទែន ដែលយើងត្រូវគេបង្ខំឱ្យចុះកុងត្រា ធ្វើការក្រោមសម្ពាធថ្នាក់លើ និងបើកលុយមិនគ្រប់ជាដើម។ ការងាររបៀបនេះ ទើបអាចបង្រៀន និងបើកភ្នែកយើងឱ្យចេញផុតពីការស្រមើស្រមៃក្នុងថ្នាក់រៀន។

យើងចំណាយលុយ និងពេលវេលាទៅរៀន ដើម្បីរកការងារធ្វើ។ ជួនកាលអ្វីដែលយើងរៀន មិនអាចត្រូវនឹងលក្ខខណ្ឌការងារមែន តែឈ្មោះជាអ្នករៀន អាចជួយឱ្យគេ

ពិចារណាយើងបាន។ យើងមិនបាច់ចាំទាល់តែរៀនចប់ ចាំស្វែងរកការងារធ្វើទេ ព្រោះទម្រាំដល់ពេលនោះ វាហួសពេលហើយ។ អ្នកខ្លះមិនចូលសាលាផង គេនៅអាចមានការងារធ្វើ ចុះទម្រាំយើងដែលមានឈ្មោះជានិស្សិត ហេតុអីក៏គ្មានការងារធ្វើដូចគេ?

ពេលខ្ញុំចាប់ផ្ដើមមានការងារធ្វើដំបូង ខ្ញុំដឹងថា ការរៀនរបស់ខ្ញុំគ្មានប្រយោជន៍បាត់ទៅហើយ។ សាលារបស់ខ្ញុំគ្មានសមត្ថភាពផ្ដល់ជំនាញឱ្យខ្ញុំទេ ហេតុនេះខ្ញុំទៅរៀនបង្គ្រប់កិច្ចប៉ុណ្ណោះ។ មិនមែនថាខ្ញុំមិនចេះអ្វីសោះទេ តែយកទៅប្រើមិនកើត។ ចេះតិចពេក ក៏គេមិនឱ្យលុយយើងដែរ។ ខ្ញុំរៀនក្នុងសាលាបានត្រឹមតែដឹង និងអាចត្រឹមតែបោកស្រីៗឱ្យគេជឿថាខ្ញុំឆ្លាតប៉ុណ្ណោះ។

ដល់ពេលខ្ញុំមានការងារអាយធីធ្វើ ដែលជាជំនាញនៅសាកលវិទ្យាល័យ ទើបធ្វើឱ្យខ្ញុំដឹងថា មេរៀនដែលគេបង្រៀននៅសាលា ពិតជាជួយខ្ញុំមិនកើតមែន។ តិចណូឡូជីដើរលឿនពេក ហេតុនេះសៀវភៅក្នុងសាលាប្ដូរមិនទាន់ ហើយគ្រូក៏គ្មានពេលស្រាវជ្រាវមេរៀនថ្មីមកបង្រៀនទៀត។ សិស្សត្រូវប្រឹងរៀនមេរៀនហួសសម័យ ដោយមិនដឹងថា វាប្រើមិនកើតក្នុងពេលបច្ចុប្បន្ន។ សិស្សរៀនក្នុងភាពស្រពិចស្រពិល ហើយបោកខ្លួនឯងថា ចេះច្បាស់ហើយ។ ចំណុចល្អមួយដែលខ្ញុំបានជួប គឺគ្រូចេះប្រាប់ឱ្យសិស្សរៀនស្រាវជ្រាវដោយខ្លួនឯង។

ខ្ញុំសាកធ្វើការទាំងប្រថុយ តែវាជួយឱ្យខ្ញុំភ្ញាក់ខ្លួន។ ពិភពការងារ មិនស្រួលដូចក្នុងសាលារៀនទេ ជាពិសេស ពេលដែលយើងមិនចេះអ្វីសោះ។

# តើពេលណាដែលយើងត្រូវធ្វើការ?

នៅក្នុងផ្នែកធ្វើជំនួញ មានពាក្យមួយឃ្លាថា “ពេលណាក៏ជាពេលល្អដើម្បីបើកក្រុមហ៊ុនដែរ”។ ពាក្យនេះក៏ប្រើត្រូវជាមួយនឹងការរកការងារធ្វើដូចគ្នា។ ពេលណាក៏ជាពេលល្អដើម្បីរកការងារធ្វើដែរ លើកលែងតែពេលរៀនចប់។ អ្វីដែលខ្ញុំលើកឡើងនេះ គឺសម្រាប់អ្នកដែលមានជីវភាពក្រីក្រ ឬល្មមប៉ុណ្ណោះ សម្រាប់អ្នកដែលមានជីវភាពធូរធារ គេមានរបៀបរៀនផ្សេង។ បើយើងក្រ កុំធ្វើខ្លួនតាមកូនអ្នកមាន ហើយ

កុំហ៊ានរៀនដល់ចប់ទើបដាក់ពាក្យធ្វើការ។ យើងពិបាក គេមិនពិបាកទេ ហេតុនេះ យើងរកផ្លូវដោះស្រាយអ្វីដែលពិបាកឱ្យបានទាន់ពេលសិន។

ខ្ញុំចេញធ្វើការដំបូង នៅចុងឆ្នាំទីមួយ ហេតុនេះខ្ញុំឱ្យយោបល់ថា ឆ្នាំទីមួយ ឬឆ្នាំទីពីរ គឺល្អបំផុតដើម្បីរកការងារធ្វើ។ បើយូរជាងនេះ យើងអាចនឹងស្តាយការរៀន ហើយ គិតថា "រៀនជិតចប់ហើយ កុំអាលធ្វើល្អជាង"។ ពាក្យថា "កុំអាល" ច្រើនតែធ្វើឱ្យ យើងអត់ការងារធ្វើពេលរៀនចប់។

យើងត្រូវចែកឱ្យដាច់រវាងការរៀនមិនចេះ និងការមិនចេះធ្វើការ។ យើងរៀនមិនចេះ មិនពាក់ព័ន្ធនឹងការងារទេ។ ជួនកាល យើងអាចរៀនបានលឿននៅកន្លែងការងារ ជាងក្នុងថ្នាក់រៀនក៏ថាបាន។ ពេលចូលធ្វើការ ហើយរៀនតាមគេបន្តិចម្តង យើងនឹង ចេះធ្វើការហើយ។

# អត្ថប្រយោជន៍ការធ្វើការក្នុងពេលរៀន

ការចេញធ្វើការក្នុងពេលរៀន មានផលប្រយោជន៍ច្រើនណាស់ ដូចជា៖

- អាចសន្សំលុយបាន។ បើយើងធ្វើការស្ម័គ្រចិត្ត យើងមិនអាចសន្សំលុយបានទេ ហើយភាគច្រើន ការងារស្ម័គ្រចិត្ត ធ្វើឡើងដើម្បីយកមុខឱ្យល្អមើលក្នុងសង្គម ប៉ុណ្ណោះ។ យើងអាចនឹងល្ងង់ខ្លួនឯង សកម្មភាពរបស់យើង គឺបានជួយសង្គម តែតើយើងច្បាស់ប៉ុន្មានភាគរយដែលគិតបែបនេះ? យើងធ្វើការរកលុយទៅ យើងអាចជួយខ្លួនឯងបាន។ យើងជួយខ្លួនឯងបាន ក៏ដូចជាយើងបានជួយ សង្គមដែរ។ បើយើងមានចិត្ត យើងជួយគេបន្តទៀតទៅ។ ជួយខ្លួនឯងមុន កុំ ទាន់បោកខ្លួនឯងថាការជួយគេមុន ជារឿងល្អ។ បើយើងជួយខ្លួនឯងបាន យើង អាចជួយអ្នកដទៃទៀតបានច្រើនជាងការងារស្ម័គ្រចិត្តទៀត។
- ទទួលបានបទពិសោធន៍ការងារពិតប្រាកដ។ ការរៀនទ្រឹស្តីក្នុងសាលា មិនមែន ជាបទពិសោធន៍ទេ។ វាជាការដឹងពីបទពិសោធន៍អ្នកដទៃ។ បើយើងចេញធ្វើ ការ យើងអាចនឹងមានឱកាសផ្លាស់ប្តូរទ្រឹស្តីទាំងនោះឱ្យក្លាយជាបទពិសោធន៍ ផ្ទាល់ខ្លួន។ ការងារពិតប្រាកដ នឹងអាចបញ្ជាក់ថា អ្វីដែលយើងរៀនកន្លងមក

ត្រូវ ឬខុស ហើយខ្លួនយើងជាមនុស្សចោលម្សៀត ឬអត់។ បានបទពិសោធន៍ ហើយ ស្គាល់ខ្លួនឯងទៀត ហេតុអ្វីមិនចង់បាន?

- ស្គាល់អ្នកដែលចេះច្រើនជាងយើង។ កន្លែងការងារពោរពេញទៅដោយអ្នកចេះ និងអ្នកធ្វើពុតជាចេះ។ យើងមិនចាំបាច់រវល់នឹងអ្នកធ្វើពុតទេ ព្រោះពួកគេមិនអាចជួយអ្វីយើងឡើយ យ៉ាងច្រើនបង្រៀនយើងឱ្យចេះធ្វើពុតដូចពួកគេប៉ុណ្ណោះ។ ប៉ុន្តែអ្នកដែលចេះជាងយើង ជាគ្រូរបស់យើង។ គេមិនស្ម័គ្រចិត្តបង្រៀនយើង ក៏គ្មានបញ្ហាដែរ ព្រោះនៅកន្លែងធ្វើការ ពួកគេនឹងបញ្ចេញសមត្ថភាពឱ្យយើងឃើញមិនខាន ហើយយើងក៏អាចលួចរៀនតាមគេបាន។ កុំគិតថា គ្មានអ្នកណាចេះជាងយើងឱ្យសោះ។ ការគិតបែបនេះ នឹងបិទផ្លូវអភិវឌ្ឍខ្លួនរបស់យើង មិនឱ្យចេញផុតពីមោទនភាពក្លែងក្លាយលើខ្លួនឯង។

- មិនទុកពេលទំនេរចោល។ បើយើងទៅរៀនមួយពេល ហើយសល់ពេលទំនេរចោលដដែល យើងគួរតែរកការងារធ្វើ។ ពេលវេលា នឹងក្លាយជាមាសប្រាក់ បើយើងអាចយកវាទៅធ្វើការងារពិតប្រាកដ។ មានពាក្យមួយឃ្លាពោលថា "អ្នកសុំទាន និងមហាសេដ្ឋី មានពេល២៤ម៉ោងដូចគ្នា តែខុសគ្នាត្រង់ការយកទៅប្រើ"។ បើយើងខ្ជិល ហើយទុកពេលចោល និងរកលេសថា "ចាំរៀនឱ្យចប់សិន" នោះយើងនឹងបាត់បង់ពេលវេលាចោលទទេហើយ។

- ស្វែងយល់ពីសង្គម និងអ្នកដទៃ។ ការធ្វើការងារ ជាផ្នែកមួយនៃការប្រឡូកក្នុងសង្គម។ យើងមិនអាចរៀនពីសង្គម ដោយមិនចូលទៅក្នុងសង្គមទេ។ យើងនឹងដឹងថា តើសង្គមពិតប្រាកដ មានមុខមាត់បែបណា ហើយចរិតមនុស្សមានភាពខុសគ្នាពីអ្នករៀនក្នុងថ្នាក់យ៉ាងម៉េចខ្លះ។ មនុស្សមិនបញ្ចេញចរិតពិតនៅក្នុងថ្នាក់រៀន ដូចនៅកន្លែងធ្វើការទេ។ ពួកគេនៅតែលាក់ខ្លះ ប៉ុន្តែគេបញ្ចេញមកច្រើន។ ខ្ញុំហ៊ានធានាថា ក្រោយពីយើងធ្វើការ យើងនឹងស្គាល់ភាពអវិជ្ជមានរបស់សង្គម និងមនុស្សកាន់តែច្រើន។ យើងកាន់តែស្គាល់ច្រើនប៉ុណ្ណា យើងកាន់តែងាយស្រួលរស់នៅ ព្រោះយើងមិនចាំបាច់ស្មានដូចមុនទៀតទេ។ អ្នកមិនធ្លាប់ធ្វើការ គិតថា អ្នកណាក៏ជាមនុស្សល្អ។

- <u>ធ្វើឱ្យខ្លួនយើងរឹងមាំ និងជឿលើខ្លួនឯង</u>។ ការងារបង្រៀនយើងឱ្យចេះពឹងលើខ្លួនឯង បន្ទាប់មកវាផ្ដល់ឱ្យយើងនូវជំនាញជាបន្តបន្ទាប់។ ពេលយើងចេះពឹងលើខ្លួនឯង ហ៊ានសម្រេចចិត្ត និងទទួលខុសត្រូវចំពោះកំហុសដែលយើងជ្រុលធ្វើ យើងជាមនុស្សរឹងមាំហើយ។ យើងរឹងមាំ ព្រោះខ្លួនយើងប្រឹងធ្វើម្នាក់ឯង។ គ្មានអ្នកណារឹងមាំដោយមិនធ្លាប់ធ្វើអ្វីសោះ និងពូកែតែដេកស្រមៃទេ។ ពេលណាយើងរឹងមាំ យើងរៀនជឿខ្លួនឯងបណ្ដើរៗ។ កម្រិតនៃការជឿលើខ្លួនឯងត្រូវមើលលើយើងថា ហ៊ានដកជំនឿពីអ្វីផ្សេងទៀតឬអត់។ យើងដកជំនឿពីអ្នកដទៃ ពីព្រេងសំណាង ពីសាសនា ឬពីអ្នកនយោបាយ កាន់តែច្រើន យើងកាន់តែជឿលើខ្លួនឯងកាន់តែខ្លាំង។ អ្នកដែលមិនហ៊ានដក អាចជឿខ្លួនឯងតាមពេលប៉ុណ្ណោះ។
- <u>អភិវឌ្ឍជំនាញរបស់យើង</u>។ មនុស្សត្រូវការមានជំនាញ ទើបអាចឱ្យសង្គមទទួលស្គាល់បាន។ សង្គមរីកចម្រើនយឺតដូចស្រុកខ្មែរ ក៏ត្រូវការអ្នកមានជំនាញដែរ។ បើយើងមានជំនាញច្បាស់ ហើយចេះពីវិធីលក់វាទៅឱ្យអ្នកដែលត្រូវការ យើងអាចនឹងរស់ស្រួលដោយមិនបាច់បន់ព្រះឱ្យជួយ។ វិធីតែមួយគត់ដើម្បីបានជំនាញ គឺធ្វើការ។ យើងធ្វើពីមិនចេះអ្វីសោះ ទាល់តែក្លាយជាអ្នកជំនាញ។ វិធីនេះមានគេយកទៅប្រើច្រើនហើយ ហេតុនេះអ្នកទាំងអស់គ្នាមិនបាច់សង្ស័យថា ខ្ញុំបង្កើតវាដើម្បីបោកទេ។

ទោះបីយើងនៅរៀន ក៏មិនមែនបានន័យថា យើងត្រូវធ្វើជាមនុស្សដែលមិនបានការខ្លាចមុខខ្លាចក្រោយដែរ។ ពេលរៀន ជាពេលសាកល្បង ហេតុនេះយើងអាចរកការងារណាដែលល្មមនឹងខ្លួនយើង ហើយធ្វើវាលេងសិនក៏បានដែរ។ ប្រយោជន៍នៃការងារ មិនធ្វើឱ្យស្ដាយថ្នាក់រៀនទេ។ កន្លែងការងារ ជាថ្នាក់រៀនដែលយើងអាចរៀនផង និងអនុវត្តផងក្នុងពេលតែមួយ ហើយចុងខែមានលុយដល់ដៃទៀត។ មេរៀននៅកន្លែងការងារ ក៏មិនគួរឱ្យធុញដូចនៅក្នុងសាលាទេ។

# ការងារ បង្រៀនមនុស្ស

សាលារៀន អាចជាកន្លែងបង្រៀនយើង ប៉ុន្តែបើសិនជាចង់រៀនបានច្រើន កន្លែងការងារប្រហែលជាមានប្រសិទ្ធិភាពជាង។ ការងារល្អ អាចបង្រៀនយើងឱ្យក្លាយជាមនុស្សថ្មីម្នាក់បានទៀតផង។ មានការងារ មានមេរៀន។ មិនមែនថាសាលា ជាកន្លែងអត់ប្រយោជន៍នោះទេ។ យ៉ាងហោចណាស់ក៏វាជួយបង្កើតការងារឱ្យមនុស្សធ្វើដែរ និងធ្វើឱ្យឪពុកម្តាយយើងសប្បាយចិត្ត ពេលឃើញកូនចូលរៀនត្រឹមត្រូវ។

យើងនឹងមានអារម្មណ៍ចាស់ទុំជាងមុន ពេលចូលធ្វើការ។ យើងរៀនពីអ្នកដទៃផង និងរៀនពីខ្លួនឯងផង។ យើងអាចស្គាល់ខ្លួនឯងកាន់តែច្បាស់តាមក្រសែភ្នែកអ្នកដទៃ។ អ្វីដែលយើងធ្វើនៅកន្លែងការងារ នឹងជះឥទ្ធិពលត្រលប់មកវិញ។ បើយើងធ្វើមិនត្រូវ អ្នកដទៃអាចនឹងទើសចិត្ត ឬអាចប្រាប់ពីកំហុសរបស់យើងបាន។ យើងខ្ចីការវិភាគរបស់គេ ដើម្បីមានទិន្នន័យសម្រាប់ធ្វើការវិភាគខ្លួនឯង។ យើងមិនជឿគេទាំងស្រុងទេ តែយើងក៏មិនមានអំណួតថា “ខ្លួនយើងគិតត្រូវគ្រប់ជ្រុងរហូត” ដែរ។ ភ្នែកខាងក្រៅ អាចជួយយើងបានច្រើន បើយើងបើកចិត្តទទួល។

អារម្មណ៍ចាស់ទុំ នឹងធ្វើឱ្យយើងចេះអត់ធ្មត់ពេលជួបបញ្ហា និងមិនឆាប់ទម្លាក់កំហុសទៅលើអ្នកដទៃ ព្រោះតែការភ័យខ្លាចមួយពេលរបស់យើង។ ក្មេងអាចរត់គេចពីកំហុស តែមនុស្សចាស់ទុំ រកវិធីដោះស្រាយកំហុសនោះ។ បើស្រាយមិនចេញ គេសុខចិត្តទទួលលទ្ធផលទាំងអស់ដែលខ្លួនបានធ្វើ។ គេមិនលួងទទួលទោសជំនួសអ្នកដទៃ ហើយក៏មិនរុញអ្នកដទៃឱ្យទទួលកំហុសជំនួសដែរ។ មនុស្សចាស់ទុំ ហ៊ានស៊ី ហ៊ានសង។ អ្នកដែលធ្វើការរាប់ឆ្នាំ ហើយមិនមានអារម្មណ៍ចាស់ទុំជាអ្នកដែលមិនបានផ្តោត និងមិនប្រឹងរៀនពីការងារ។

ការដោះស្រាយបញ្ហា ជាផ្នែកសំខាន់ក្នុងការងារ។ ការងារគ្រប់ប្រភេទ សុទ្ធតែកើតចេញពីបញ្ហា។ ការងារដែលខ្ញុំកំពុងធ្វើ កើតឡើងដោយសារតែពួកគ្រីស្ទបរិស័ទបរទេស មានបញ្ហាពេលទៅបញ្ចុះបញ្ចូលអ្នកស្រុកក្រីក្រឱ្យជឿលើសាសនាគ្រីស្ទ ហេតុនេះទើបគេធ្វើមេរៀនសម្រាប់ជួយអ្នកដែលចុះទាំងនោះ។ ថៅកែខ្ញុំមើលឃើញពីបញ្ហា ហេតុនេះទើបគាត់ចង់ធ្វើជាអ្នកដោះស្រាយ ដើម្បីបានលុយខ្លះ។ អ្នកណាក៏

ដឹងដែរថា នៅក្នុងសាសនាគ្រឹស្ត មានលុយច្រើនណាស់។ បើគាត់ជាគ្រឹស្តបរិស័ទ មិនចេះយកលុយពីក្នុងសាសនាខ្លួនឯង តើគាត់ធ្វើជំនួញដោយរបៀបណា? គាត់បង្ហាញបញ្ហាដែលគាត់មើលឃើញទៅដល់បុគ្គលិកដើម្បីឱ្យពួកគេដោះស្រាយ។

បញ្ហាថ្មី មកជាបន្តបន្ទាប់ ហេតុនេះខ្ញុំមានការងារធ្វើរហូត។ បញ្ហាដែលដោះស្រាយរួច នឹងជួយរកចំណូល ឬបង្កើតកេរ្តិ៍ឈ្មោះដល់ក្រុមហ៊ុន។ ថៅកែពេញចិត្តនឹងដំណោះស្រាយដែលបុគ្គលិកផ្តល់ឱ្យ គាត់ក៏រកបញ្ហាផ្សេងទៀតមកឱ្យដោះស្រាយបន្ត។ អ្នកធ្វើការ ជាអ្នកដោះស្រាយបញ្ហា។ អ្នកដែលមិនចេះដោះស្រាយ ឬគេចពីបញ្ហា ជាអ្នកអត់ការងារធ្វើ ឬកូនអ្នកមានដែលដេកស៊ីលុយឪពុកម្តាយ។

ក្រៅពីការដោះស្រាយបញ្ហា យើងនឹងចេះទទួលស្គាល់ការពិត និងការស្រមៃ។ យើងអាចនឹងស្រមៃថា ជីវិតយើងពោរពេញទៅដោយភាពរីករាយ និងមានគេទ្រជើងយើងគ្រប់ពេល តែការពិតយើងជាខ្ញុំគេ ដែលប្រឹងរស់ដោយសមត្ថភាពខ្លួនឯង។ ពេលយើងចេះធ្វើការ យើងលែងស្រមៃទៀតហើយ។ យើងប្រឈមមុខនឹងការពិត ហើយរកវិធីធ្វើឱ្យគ្រប់យ៉ាងប្រសើរឡើងម្តងបន្តិច។ ក្តីស្រមៃរបស់យើងនៅតែមាន តែយើងឈប់ដេកស្រមៃ ហើយធ្វើឱ្យចេញជារូបរាងម្តង។

ការងារ បង្រៀនយើងឱ្យទទួលស្គាល់ការពិត។ ពេលយើងធ្វើខុស យើងនឹងត្រូវទទួលស្គាល់ថា យើងមិនទាន់ចេះ ឬចេះមិនច្បាស់ ហើយត្រូវការជំនួយពីអ្នកដទៃ។ ពេលយើងធ្វើត្រូវ យើងទទួលស្គាល់ថា យើងដឹងពីរបៀបធ្វើ ដូច្នេះមិនបាច់រំខានអ្នកដទៃមកជួយទៀតទេ។ ពេលត្រូវគេដេញចោល យើងមិនអាចដេកស្រមៃថា គេនឹងភ្ញាក់ខ្លួនថាដេញយើងខុស ហើយអង្វរយើងឱ្យទៅធ្វើការវិញទេ។ យើងត្រូវរកការងារថ្មីធ្វើ។ អ្នកធ្វើការ ត្រូវតែស្គាល់ការពិត និងមិនត្រូវលួងចិត្តខ្លួនឯងដោយមិនដឹងខុសត្រូវឡើយ។

ចំណុចចុងក្រោយនេះ ជាមេរៀនដែលខ្ញុំចូលចិត្តជាងគេ។ យើងមិនអាចទទួលស្គាល់ការពិតបានភ្លាមមែន ប៉ុន្តែយើងអាចរៀនបាន។ តើយើងរៀននៅកន្លែងណាដែលមិនអស់លុយនោះ? គឺកន្លែងការងារ។ អ្នកដទៃសុខចិត្តរស់នៅជាមួយការដេកស្រមៃ និងគេចវេសពីការពិត តែបើយើងស្រលាញ់ខ្លួនឯងមែន ត្រូវតែរស់នៅជាមួយ

ការពិត។ ការពិត អាចធ្វើឱ្យយើងឈឺចាប់ តែវាមិនធ្វើបាបយើងនៅពេលក្រោយដូចការដេកស្រមៃ។

# បទពិសោធន៍ក្នុងការងារ និងបទពិសោធន៍ក្នុងសាលា

យើងទទួលបានបទពិសោធន៍ដូចគ្នា តែមួយណាមានតម្លៃជាង? ពេលយើងនិយាយដល់ការពិត អ្វីដែលមានតម្លៃជាង ជារបស់ល្អជាងជានិច្ច។ យើងអាចទៅរៀន៤ឆ្នាំពេញ តែអ្វីដែលយើងចេះមិនអាចស្មើអ្នកដែលធ្វើការក្នុងផ្នែកនោះ៤ឆ្នាំទេ។ យើងចំណាយពេលស្មើគ្នា តែអ្វីដែលទទួលបាន មិនស្មើគ្នា។

បទពិសោធន៍ក្នុងការងារ ជាបទពិសោធន៍ជាក់ស្តែង ដែលខ្លួនយើងជាអ្នកធ្វើ រៀន និងកត់ចំណាំ។ យើងធ្វើកិច្ចការមួយដោយមិនច្បាស់ក្នុងចិត្ត តែក្រោយពេលធ្វើរួច យើងអាចរកភាពច្បាស់លាស់សម្រាប់ខ្លួនឯងបាន។ មេរៀនដែលយើងរៀន គឺខ្លួនយើងជាអ្នកបង្កើត ហេតុនេះយើងរៀនឆាប់ចេះ និងចាំបានយូរជាងមេរៀនរបស់អ្នកដទៃ។

បទពិសោធន៍ការងារ កើតឡើងពីការសាកល្បង ដូច្នេះយើងមិនមែនដឹងតែវិធីដែលធ្វើបានជោគជ័យទេ តែវិធីបរាជ័យក៏យើងដឹងដែរ។ យើងច្បាស់ជាងអ្នកដែលមិនធ្លាប់ធ្វើ។ អ្នកដែលគេរៀនក្នុងសាលាដឹងតែវិធីដែលត្រូវធ្វើប៉ុណ្ណោះ នៅពេលជួបបញ្ហាដែលមិនបានរៀន ពួកគេនឹងឆ្ងល់ ហើយប្រឹងធ្វើឡើងវិញតាមវិធីដែលធ្លាប់រៀន។ ភាពច្នៃប្រឌិតរបស់ពួកគេ ត្រូវគ្របសង្កត់ដោយការជឿលើអ្វីដែលធ្លាប់រៀន។ អ្នកដែលធ្វើការ ប្រើភាពច្នៃប្រឌិត ដោយផ្អែកលើការបរាជ័យ។

ខ្ញុំដឹងរឿងច្រើនពីការងារ ទាំងរឿងអាក្រក់ និងរឿងល្អ។ រឿងខ្លះ គ្មានអ្នកណានិយាយនៅក្នុងសាលាទេ ព្រោះគេចាំឱ្យយើងជួបខ្លួនឯង ។ ការធ្វើការងារ ក្នុងពេលរៀន ជាឱកាសសម្រាប់យើងធ្វើជាមនុស្សជំពេញវ័យ។

ការងារ និងការរៀនក្នុងសាលា សុទ្ធតែមានប្រយោជន៍ តែបើយកមកប្រៀបធៀបគ្នា ការងារ មានប្រយោជន៍ជាងឆ្ងាយណាស់។ មនុស្សគេយកបទពិសោធន៍មកប្រើ។ មានបទពិសោធន៍ច្រើន ខួរក្បាលក៏មិនសូវគាំង ហើយទឹកមាត់ក៏ប្រែបន្តិចម្តងៗ។

# អ្វីដែលគួរធ្វើ

បើអ្នកទាំងអស់គ្នាមិនទាន់បានសាកធ្វើការទេ សូមកុំពន្យារពេលទៀត។ វាយ CV ហើយយកទៅដាក់តាមក្រុមហ៊ុនណាដែលគេកំពុងរើសបុគ្គលិកលេងៗទៅ។ ពេលណាគេត្រូវការមនុស្ស គេនឹងហៅយើងទៅសួរនាំហើយ។ ក្រុមហ៊ុនមួយចំនួនចង់បានបុគ្គលិកដែលមិនទាន់រៀនចប់មកធ្វើការ ដើម្បីចំណេញ ប្រាក់ខែខ្លះ ហើយស្រួលប្រើធ្វើការ។ យើងអាចឆក់យកឱកាសបែបនេះបាន។

កុំជឿពាក្យថា “រៀនផង ធ្វើការផង នាំឱ្យបែកអារម្មណ៍”។ ពាក្យនេះប្រើបានសម្រាប់តែកូនអ្នកមាន ឬកូនដែលមិនចង់ជួយឪពុកម្តាយប៉ុណ្ណោះ។ យើងមិនបែកអារម្មណ៍ទេ ព្រោះពេលចូលធ្វើការ យើងនឹងផ្តោតច្រើនទៅលើការងារ ហើយមិនយូរទេ យើងនឹងដកការយកចិត្តទុកដាក់ចេញពីសាលារៀនហើយ។ ពេលយើងលែងខ្វល់ពីការរៀនក្នុងសាលា យើងក៏អាចពង្រឹងសមត្ថភាពក្នុងការងារបានដែរ។ អារម្មណ៍យើងមិនបែកទៅណាទេ គ្រាន់តែវាប្រមូលគ្នាមកដាក់លើការងារប៉ុណ្ណោះ។

ការងារ ជាអនាគតរបស់យើង មិនមែនការរៀនក្នុងថ្នាក់ទេ។ បើយើងខ្វល់ពីសញ្ញាបត្រណាស់ អាចរៀនល្មមៗឱ្យតែជាប់ទៅបានហើយ។ នៅពេលយើងធ្វើការបានលើសពី៥ឆ្នាំ គ្មានអ្នកណាមកសួរនាំយើងពីរឿងរៀនក្នុងសាលាទៀតទេ។ ក្រោយពេល៥ឆ្នាំក្នុងការងារ អ្វីដែលគេចង់សួរ គឺជំនាញ និងចំណេះដឹងដែលយើងបានពីការងារប៉ុណ្ណោះ។ ពេលខ្លះ គេសុំយើងមើលស្នាដៃចាស់ៗ ដែលយើងធ្លាប់ធ្វើ ដើម្បីបញ្ជាក់ពីសមត្ថភាពរបស់យើង។ ភស្តុតាង មិនមែនមានតែលើសញ្ញាបត្រ។

ខ្ញុំបញ្ជាក់បន្តិច មិនមែនគ្រប់ការងារទាំងអស់សុទ្ធតែអាចបោះបោលការរៀនក្នុងសាលានោះទេ។ ការងារដូចជា ពេទ្យ វិស្វកម្ម ហិរញ្ញវត្ថុ និងការងារស្មុគ្រស្មាញមួយចំនួនទៀត ចាំបាច់ត្រូវតែមានការរៀនក្នុងសាលាត្រឹមត្រូវ។ ប៉ុន្តែការងារផ្នែកតិ

ចណ្ឌូឡជី ឬផ្នែកច្នៃប្រឌិត មិនបាច់ទៅរៀនក្នុងសាលា ក៏អាចធ្វើបានដែរ។ បើមិនជឿខ្ញុំ ចូលមើលថ្នាក់រៀនអនឡាញទៅដឹងហើយ។ ចំណាយលុយតែ ២០ដុល្លារ និងពេលប៉ុន្មានអាទិត្យ យើងអាចធ្វើការបានហើយ។ ទោះបីមិនទាន់ស្ទាត់ ក៏យើងបានបង្កើតផ្លូវដើរលើទីផ្សារការងារឱ្យខ្លួនឯងដែរ។

# ២

# ការធ្វើការក្នុងក្រុមហ៊ុនតូច

មុនពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយឆ្នាំ ខ្ញុំបានចូលធ្វើការក្នុងក្រុមហ៊ុនតូចមួយ ដែលគ្មានអ្នកណាស្គាល់។ ក្រុមហ៊ុនអាយធីថ្មីនេះ មានបុគ្គលិកប្រមាណជាដប់នាក់ប៉ុណ្ណោះ ហើយខ្ញុំក៏ត្រូវមកធ្វើជាផ្នែកមួយរបស់ក្រុមហ៊ុននេះដែរ។ ពីដំបូង ខ្ញុំមិនដឹងថា វាជាកន្លែងដែលធ្វើឱ្យខ្ញុំបានប្រយោជន៍ច្រើននោះទេ។ អ្វីដែលខ្ញុំដឹង គឺ ម្ចាស់ក្រុមហ៊ុនធ្លាប់ជាគ្រូដែលបង្រៀនខ្ញុំនៅសាកលវិទ្យាល័យ ហើយប្អូនគាត់ធ្លាប់ជួយបង្រៀនខ្ញុំសរសេរកូដប៉ុណ្ណោះ។

ខាងក្រោមនេះជាប្រយោជន៍ដែលខ្ញុំទទួលបាន។

## រៀនបានច្រើន

ក្រុមហ៊ុនធំ និងក្រុមហ៊ុនតូច មានរបៀបធ្វើការខុសគ្នា។ ក្នុងក្រុមហ៊ុនធំ យើងគ្រាន់តែជាផ្នែកមួយនៃម៉ាស៊ីនធំមួយប៉ុណ្ណោះ។ នេះបញ្ជាក់ថា យើងមិនអាចដឹងពីផ្នែកផ្សេងទៀតនៃគ្រឿងចក្របានទេ។ នៅក្នុងក្រុមហ៊ុនតូច យើងអាចដឹងពីការរៀបគម្រោងទីផ្សាររបស់ក្រុមហ៊ុន ការបែកចែកភាគហ៊ុន ការចរចារជាមួយដៃគូការរៀបចំទំនិញ ការសម្ភាសបុគ្គលិក ការដេញបុគ្គលិក និងបញ្ហាជាច្រើនដែលក្រុមហ៊ុនជួប។

ខ្ញុំធ្វើការផ្នែកឌីហ្សាញ តែខ្ញុំដឹងរឿងទាំងនេះដែរ។ ខ្ញុំដឹងមិនអស់ទេ ព្រោះខាងក្រុមហ៊ុនមិនចង់ឱ្យខ្ញុំដឹង តែអ្វីដែលខ្ញុំបានរៀន ក៏មិនតិចដែរ។ សម្រាប់អ្នកដែលចង់រៀនច្រើន គួរតែរើសយកក្រុមហ៊ុនតូចធ្វើការ។

យើងអាចរៀនពីការងារមួយបានច្បាស់លាស់ក្នុងក្រុមហ៊ុនធំ តែយើងអាចដឹងច្រើនមុខក្នុងក្រុមហ៊ុនតូច។ ក្រុមហ៊ុនធំ ប្រៀបដូចជាប្រទេសដឹកនាំផ្ដាច់ការដែរ ព្រោះពួកគេលាក់រឿងសម្ងាត់ច្រើន ហើយមិនចង់ឱ្យបុគ្គលិកធម្មតាដឹងច្រើនពេក ហួសពីតម្រូវការក្នុងការងារ។ ក្រុមហ៊ុនតូចវិញ មិនសូវខ្វល់ពីរឿងនេះទេ ព្រោះអ្វីដែលត្រូវខ្វល់គឺរកចំណូលទប់ក្រុមហ៊ុន និងពង្រីកខ្លួនឱ្យទាន់ពេល មុននឹងត្រូវបិទទ្វារវិញ។ ក្រុមហ៊ុនតូច ខ្លាចបរាជ័យ ព្រោះបុគ្គលិកមិនដឹងរឿងច្រើន ចំណែកក្រុមហ៊ុនធំវិញ ខ្លាចបរាជ័យ បើបុគ្គលិកដឹងរឿងច្រើនពេក។

ក្រុមហ៊ុនធំ តែងតែត្រូវការអ្នកជំនាញតាមផ្នែកនីមួយៗ។ យើងដឹងហើយថា អ្នកជំនាញធ្វើការ មិនសូវចូលចិត្តឱ្យមានការរំខានពីអ្នកដទៃទេ។ ពួកគេត្រូវការផ្ដោតអារម្មណ៍ និងគិតទៅលើបញ្ហាចំពោះមុខ ដូច្នេះយើងមិនអាចទៅសូមគេរៀនបានទេ ហើយគេក៏គ្មានពេលបង្រៀនយើងដែរ បើមិនមានបញ្ជាពីថ្នាក់លើនោះ។ អ្នកជំនាញក្នុងក្រុមហ៊ុនធំ ប្រជែងគ្នាយកដំណែង ហេតុនេះ ការចែកគ្នាចេះ កម្រនឹងមានណាស់។

ចំណែកក្រុមហ៊ុនតូចវិញ មិនសូវមានអ្នកជំនាញ ព្រោះគ្មានលុយជួលពួកគេមកធ្វើការ។ អ្វីដែលអាចធ្វើបាន គឺ ជួលអ្នកដែលចង់ចេះ និងអាចធ្វើការបានល្មមៗបានប៉ុណ្ណោះ។ មនុស្សប្រភេទនេះមានចិត្តទូលាយ និងមិនសូវខ្វល់ពីការប្រជែងគ្នារឿងដំណែងប៉ុន្មានទេ។ ពួកគេមិនទាន់មានជំនាញ ដូច្នេះក៏មិនខ្លាចគេមកដណ្ដើមជំនាញខ្លួនឯងដែរ។ បុគ្គលិកក្នុងក្រុមហ៊ុនតូច អាចយកការងារផ្នែកផ្សេងគ្នាមកពិភាក្សា និងចែករំលែកពីអ្វីដែលខ្លួនដឹងទៅវិញទៅមកបាន។

បើយើងជាមនុស្សចូលចិត្តរៀនច្រើន ត្រូវរកកន្លែងដែលយើងរៀនអាចរៀនបានច្រើ។

# មានឱកាសច្រើនជាង

ការចាប់យកឱកាស ជារឿងមួយដែលយើងធ្វើ។ ឱ្យតែឃើញឱកាស យើងនឹងប្រឹងយកភ្លាម ទោះមិនដឹងថា ឱកាសនោះល្អ ឬមិនល្អក៏ដោយ។ នៅពេលយើងចូលធ្វើការក្នុងក្រុមហ៊ុនតូច យើងនឹងទទួលបានឱកាសជាច្រើន ដូចជា អាចឡើងដំណែង អាចទទួលបានការគោរព ស្គាល់ជិតស្និទ្ធជាមួយថៅកែ ឬអាចទទួលបានការទំនុកបម្រុងពីក្រុមហ៊ុនទៀតផង។

ឱកាសដែលមាននៅក្រុមហ៊ុនតូច មិនសូវមានគេដណ្តើមទេ ព្រោះមនុស្សដែលមកធ្វើការមានតិច។ បើប្រៀបធៀបនឹងក្រុមហ៊ុនធំ យើងអាចនឹងទទួលបានច្រើនជាង ព្រោះក្នុងក្រុមហ៊ុនធំ មានមនុស្សចាប់យកមុនយើងអស់ហើយ។ លើកលែងតែយើងចូលធ្វើការក្នុងក្រុមហ៊ុនធំក្នុងដំណែងខ្ពស់ ទើបយើងអាចមានឱកាសច្រើនជាងបុគ្គលិកចាស់។

មុនពេលខ្ញុំចូលមកធ្វើការ ខ្ញុំតែងគិតថា “បើខ្ញុំប្រឹងធ្វើការ តើខ្ញុំនឹងមានឱកាសអ្វីខ្លះ? ឡើងប្រាក់ខែ ឡើងដំណែង ទៅរៀនបន្ត ឬអាចធ្វើការពីផ្ទះ?” នៅក្នុងក្រុមហ៊ុនធំ ឱកាសបែបនេះ មិនងាយមានទេ ព្រោះរចនាសម្ព័ន្ធក្រុមហ៊ុនត្រូវបានគេរៀបចំរួចរាល់ហើយ។ ខ្សែខាងគេ នៅពីលើយើងជានិច្ច ទោះយើងខ្លាំងប៉ុណ្ណា ក៏គ្មានប្រយោជន៍ដែរ។ ថៅកែក្រុមហ៊ុនធំ តែងតែដាក់មនុស្សរបស់គេឱ្យធ្វើការស្ទើរតែគ្រប់ផ្នែកទាំងអស់ ដើម្បីងាយស្រួលតាមដានដំណើរការរបស់ក្រុមហ៊ុន។ យើងមិនបាច់ឆ្ងល់ថា ខ្សែខាងគេ មកពីណាទេ។ គេមកមុនយើងទៅទៀត។

កាលខ្ញុំធ្វើការនៅក្រុមហ៊ុនE-Commerce គេបានដាក់ឈ្មោះខ្ញុំចូលទៅក្នុង Management Team។ ខ្ញុំមិនមានឈ្មោះជា Manager ទេ តែខ្ញុំមានសិទ្ធិបញ្ចេញយោបល់នៅពេលសម្រេចចិត្តផ្សេងៗ ជាពិសេស គឺ ផ្នែកឌីហ្សាញ និងការសរសេរ។ ខ្ញុំបានធ្វើរឿងមួយសម្រាប់ក្រុមហ៊ុន គឺ ប្តូរពណ៌របស់ក្រុមហ៊ុន ពីពណ៌ទឹកក្រូច មកជាពណ៌បៃតង។ ម្ចាស់ក្រុមហ៊ុនជឿថា ពណ៌ទឹកក្រូច ជាពណ៌ហុងស៊ុយរបស់គាត់  តែខ្ញុំប្រាប់គាត់ថា ពណ៌បៃតងល្អប្រើជាង ហើយក្រោយមក

ក្រុមហ៊ុនក៏ប្រើពណ៌បៃតងវិញ។ Logo ក្រុមហ៊ុន ក៏ខ្ញុំជាអ្នកប្តូរចេញដែរ។ បើនៅក្រុមហ៊ុនធំវិញ កុំថាដល់ប្តូរ Logo ប្តូរតែកន្លែងដាក់ធុងសម្រាម ក៏ត្រូវមាត់គេដែរ។

គេផ្តល់ឱកាសឱ្យខ្ញុំតាំងពីចូលធ្វើការដំបូង។ ខ្ញុំដាក់ពាក្យធ្វើជាអ្នកសរសេរកូដវេបសាយទេ ប៉ុន្តែថៅកែឃើញខ្ញុំធ្វើការងារផ្នែកឌីហ្សាញ គ្រាន់បើ ក៏ហៅខ្ញុំទៅសួរ។ គាត់ប្រាប់ថា បើចង់ធ្វើការផ្នែកក្រាហ្វិចឌីហ្សាញ គាត់អាចឱ្យខ្ញុំសាកបាន។ ខ្ញុំក៏សាកតាមគាត់ ដោយអង្គុយរៀនខ្លួនឯងបណ្តើរ ហើយធ្វើការឱ្យក្រុមហ៊ុនបណ្តើរ។ ប្រហែលជាពីរឆ្នាំ ខ្ញុំអាចធ្វើការបាន ដោយមិនពិបាក ហើយក្រាហ្វិចឌីហ្សាញ ក៏ក្លាយជាជំនាញជាប់ខ្លួនខ្ញុំ។

បើនៅក្រុមហ៊ុនធំវិញ ឱកាសប្តូរមុខដំណែងពីផ្នែកមួយទៅផ្នែកមួយ មិនងាយមានទេ។ តាមផ្នែកនីមួយៗ តែងតែមានអ្នកគ្រប់គ្រងរបស់គេ ហើយមានរបៀបធ្វើការផ្សេងគ្នា។ ក្រុមហ៊ុនខ្លះ មានការប្រជែងគ្នារវាងផ្នែកខុសគ្នាទៀតផង ដូច្នេះការផ្លាស់ប្តូរពីផ្នែកមួយទៅផ្នែកមួយ ជារឿងពិបាកណាស់។ ក្រុមហ៊ុនធំ ក៏គេមិនទុកឱកាសឱ្យយើងរៀនដែរ ព្រោះមានមនុស្សដែលចេះស្រាប់ ចង់បានការងារធ្វើច្រើនណាស់។ បើដេញយើងចោលម្នាក់ គេអាចរើសម្នាក់ទៀតក្នុងថ្ងៃតែទៀតផង។

# មានសេរីភាព

ខ្ញុំសុខចិត្តធ្វើគ្រប់យ៉ាងដើម្បីសេរីភាពផ្ទាល់ខ្លួន។ នៅក្នុងក្រុមហ៊ុនដែលខ្ញុំធ្វើការ មិនចាំបាច់ស្លៀកពាក់ឯកសណ្ឋានចង្អៀត ឬធ្វើការតឹងរឹងគ្រប់ម៉ោងរហូតទេ។ ពេលដែលខ្ញុំភ្ញាក់ឡើង បើមានអារម្មណ៍ថាអត់ចង់ទៅធ្វើការ ខ្ញុំអាចប្រាប់មេរបស់ខ្ញុំថា “ថ្ងៃនេះឈឺក្បាលហើយ ចាំស្អែកចាំទៅធ្វើការ” ក៏បាន។ ខ្ញុំមិនមានសម្ពាធខ្លាំងជាមួយការងារទេ។

សេរីភាព គឺការអាចធ្វើអ្វីបាន តែស្ថិតក្នុងដែនកំណត់ច្បាស់លាស់។ ដែនកំណត់របស់ខ្ញុំ គឺ មិនធ្វើឱ្យប៉ះពាល់ដល់ចំណូល និងមុខមាត់របស់ក្រុមហ៊ុន។ ក្រៅពីនេះខ្ញុំរាប់ជាសេរីភាពរបស់ខ្ញុំទាំងអស់។ ពីមុនខ្ញុំគិតថា ប្រហែលជាគ្មានក្រុមហ៊ុនណាគេ

ហ៊ានឱ្យសេរីភាពដល់ខ្ញុំបែបនេះទេមើលទៅ តែខ្ញុំគិតខុស។ បើចង់មានសេរីភាព ត្រូវប្រឹងយកវាដោយខ្លួនឯង។ ការធ្វើការគ្មានសេរីភាព មិនខុសពីជាប់គុកទេ។

អ្នកទាំងអស់គ្នាអាចអានបន្ថែមក្នុងចំណុចទី៦បាន ព្រោះខ្ញុំសរសេរលម្អិតពីសេរីភាពទាំងប៉ុន្មាននៅក្នុងការងារ។

# អាចប្រើជំនាញបានពេញទំហឹង

ការប្រើជំនាញពេញទំហឹង បានន័យថា យើងប្រើអ្វីដែលយើងចេះឱ្យអស់ពីខ្លួន ឬរហូតទាល់ច្រក បន្ទាប់មកទើបមានឱកាសរៀនអ្វីថ្មីបន្ថែមទៀត។ ដោយសារក្រុមហ៊ុនតូច មានគ្នាតិច ហេតុនេះបុគ្គលិកម្នាក់ អាចនឹងត្រូវ៉រាប់រងកិច្ចការមួយដែលគេធ្វើជាក្រុមនៅក្រុមហ៊ុនធំ។ វាជាការពិបាក តែក៏ជាវិធីពង្រឹងជំនាញដែរ។ តាមពិតយើងមិនធ្វើម្នាក់ឯងទេ។ សម័យនេះ យើងមានអ៊ីនធឺណេត ដូច្នេះជំនួយរបស់យើងមានច្រើនណាស់។

ខ្ញុំធ្វើការទាល់គំនិតតែរហូតហ្នឹង។ កាន់តែទាល់ កាន់តែចេះថែម ហេតុនេះ ខ្ញុំមិនខ្វល់ពីការទាល់ច្រកពេលធ្វើការនោះទេ។ ខ្ញុំធ្វើមិនចេញ ខ្ញុំសួរ Google ភ្លាម។ បើថ្ងៃនេះខ្ញុំធ្វើមិនទាន់ចេញ ខ្ញុំទុកស្អែកចាំធ្វើបន្តទៀត។ ខ្ញុំធ្វើម្នាក់ឯង ហេតុនេះថៅកែយល់ពីរឿងនេះហើយ។ គេក៏មិនបង្ខំយើងឱ្យធ្វើការពិបាកក្នុងពេលខ្លីដែរ។

# ធ្វើការបានលឿនជាង

នៅក្នុងក្រុមហ៊ុនធំ ទម្រាំតែបានការសម្រេចពីថ្នាក់លើ ត្រូវឆ្លងកាត់មនុស្សច្រើននាក់ណាស់ ហេតុនេះការងារ ត្រូវអូសពេលវេលាកាន់តែយូរ។ ក្រុមហ៊ុនតូច មិនចាំបាច់ពិបាកបែបនេះទេ។ បើមានការចាំបាច់ អាចដើរទៅសួរអ្នកដែលអាចសម្រេចបានដោយផ្ទាល់តែម្តង។ ក្រុមហ៊ុនធំ ពិបាកត្រង់ក្បួនក្បាច់ពេក ទើបការងារយឺត។

យើងអាចប្រៀបក្រុមហ៊ុនធំ ទៅនឹងមនុស្សចាស់បាន ព្រោះមនុស្សចាស់ចូលចិត្តធ្វើអ្វីមួយៗ។ បើធ្វើលឿនពេក អាចនឹងថ្លោះត្រង់នេះ ត្រង់នោះមិនខាន។ ក្រុមហ៊ុនធំក៏ដូចគ្នា បើសម្រេចចិត្តលឿនពេក អាចនឹងប៉ះពាល់ដល់ផ្នែកផ្សេងទៀត។ ក្រុមហ៊ុន

តូច ប្រៀបដូចជាក្មេងដែលមានភាពរហ័សរហួន។ ពួកគេមិនខ្លាចនឹងដួលទេ ព្រោះគេអាចងើបឡើងវិញបានយ៉ាងស្រួល។ ក្រុមហ៊ុនតូច ធ្វើការលឿនជាងក្រុមហ៊ុនធំ។

កាលពីក្រុមហ៊ុនហ្វេសប៊ុកនៅតូច មិនទាន់ចូលទីផ្សារភាគហ៊ុន ក៏គេបញ្ចេញអ្វីថ្មីទៅក្នុងវេបសាយលឿនដែរ។ ពួកគេមិនមានដំណាក់កាលច្រើនដូចពេលក្លាយជាក្រុមហ៊ុនធំទេ។ ពាក្យស្លោករបស់ហ្វេសប៊ុកក្នុងពេលដំបូង គឺ ផ្លាស់ប្តូរឱ្យលឿន និងបំបែកឧបសគ្គ តែឥលូវគេលែងប្រើហើយ ព្រោះប្តូរលឿនពេក បាត់លុយ និងធ្លាក់តម្លៃភាគហ៊ុន។

# មានការទទួលស្គាល់

សាកគិតទៅមើល អ្នកដែលគ្មានសញ្ញាប័ត្រត្រឹមត្រូវ បើចូលធ្វើការក្នុងក្រុមហ៊ុនធំ ធ្វើម៉េចនឹងមានគេទទួលស្គាល់? ខ្ញុំរៀនដោយខ្លួនឯង ហើយរៀនមេរៀន free នៅលើអ៊ីនធឺណេតទៀត ហេតុនេះខ្ញុំគ្មានសញ្ញាបត្រអ្វីបញ្ជាក់ទេ។ ក្រុមហ៊ុនខ្លះ រើសតាំងពីឈ្មោះសាលាទៀតផង។ ឈ្មោះសាលាមិនសូវល្បី ក៏គេមិនយកដែរ។

ក្នុងក្រុមហ៊ុនតូច គេមិនផ្តោតលើសញ្ញាបត្រទេ។ គេត្រូវការមនុស្សដែលអាចធ្វើការបានលឿន តាមតម្រូវការរបស់ក្រុមហ៊ុន។ គេត្រូវការមនុស្សដែលចេះសម្របខ្លួន ហើយបត់បែនតាមក្រុមហ៊ុនបានលឿន។ គេចង់បានមនុស្សដែលមិនចេះប្រកាន់ខ្លួនក្នុងការធ្វើកិច្ចការតូចតាច ឬធ្វើការជាមួយអ្នកដែលមិនសូវចេះ។

អ្នកដែលមានសញ្ញាបត្រត្រឹមត្រូវ ចូលចិត្តប្រើក្បួន ហេតុនេះពួកគេពិបាកនឹងបត់បែន ពេលមានអ្វីមួយប្រែប្រួលលឿនពេក។ អ្នកដែលគ្មានសញ្ញាបត្រវិញ ខុសគ្នា។ បើគេអាចសាងជំនាញបានដោយមិនចូលសាលា អ្វីក៏គេគិតថា អាចទៅរួចដែរ។ ក្រុមហ៊ុនតូច ទទួលស្គាល់សមត្ថភាពមនុស្សដោយរបៀបនេះ។

# បានជួបមនុស្សដែលមានមហិច្ឆតា

អ្នកដែលប្រឹងប្រែងបង្កើតក្រុមហ៊ុនឡើងមក សុទ្ធតែជាមនុស្សដែលមហិច្ឆតា គួរឱ្យគោរព។ ពួកគេខុសប្លែកពីមនុស្សក្នុងក្រុមហ៊ុនធំៗ ដែលបានត្រឹមតែធ្វើការតាមគេ

ហើយធ្វើឬកទ្បុយ។ នៅជិតគេយូរទៅ ក្រែងលោយើងបានស្រូបចំហាយពីគេខ្លះ។ យើងរៀនពីមនុស្សដែលមានមហិច្ឆតា ទើបយើងមានចិត្តចង់បានដូចគេដែរ។ យើងអាចនឹងមិនចាប់អារម្មណ៍លើការធ្វើជំនួញ តែមិនបានន័យថា យើងមិនចាប់អារម្មណ៍លើភាពជោគជ័យរបស់គេដែរ។ យើងអាចទៅធ្វើអ្វីដែលត្រូវនឹងចំណង់ចំណូលចិត្តរបស់យើង ដោយប្រើវិធីរបស់គេបាន។

មហិច្ឆតារបស់ថៅកែក្រុមហ៊ុនតូច គឺពង្រីកខ្លួនឱ្យបានក្លាយជាក្រុមហ៊ុនធំដែរ។ មហិច្ឆតាបែបនេះ នឹងធ្វើឱ្យយើងដឹងថា ពេលមនុស្សចង់បានអ្វីមួយខ្លាំង តើគេនឹងប្រើវិធីអ្វីខ្លះ។ បើយើងចេះសង្កេតមើលមនុស្ស យើងនឹងទទួលបានមេរៀនល្អជាច្រើនពីពួកគេ។ ថ្ងៃណាមួយដែលមហិច្ឆតារបស់យើងដុះពន្លកមកដែរ យើងក៏អាចយកមេរៀនទាំងនោះទៅប្រើបានទៀតផង។ កុំទាន់អានអស់សង្ឃឹម ថាយើងនឹងធ្វើខ្ញុំគេអស់មួយជីវិត តែក៏កុំមានសង្ឃឹមខ្លាំងពេកដែរ ព្រោះអនាគតមើលមិនឃើញច្បាស់ទេ។

យើងរាប់អានមនុស្សបែបណា យើងនឹងក្លាយជាមនុស្សបែបនោះ។ យើងយកបុគ្គលបែបណាធ្វើជាគម្រូ ជីវិតយើងក៏មិនសូវខុសពីជីវិតមនុស្សនោះប៉ុន្មានដែរ។ យើងចំណាយពេលធ្វើការតាមបែបមនុស្សមានមហិច្ឆតា យើងក៏អាចក្លាយជាអ្នកដែលមានមហិច្ឆតាដូចគ្នា។

អ្នកដទៃមានឥទ្ធិពលមកលើចរិតរបស់យើង ជាពិសេសបើគេជាមនុស្សដែលយើងកោតសរសើរ។ ខ្ញុំមិនអាចធានាទាំងស្រុងបានទេថា វានឹងទៅជាបែបនេះរហូត ព្រោះខ្ញុំឃើញអ្នកដែលយកអ្នកនយោបាយ និងតារានយោបាយធ្វើជាគម្រូ នៅតែវេចខោអាវទៅធ្វើខ្ញុំគេដល់ស្រុកក្រៅ។ ខ្ញុំមិនឃើញពួកគេប្រឹងធ្វើតាមមនុស្សដែលគេគោរពសោះ។

# ផ្តល់បទពិសោធន៍ផ្នែកជំនួញ

ក្រុមហ៊ុនតូច កើតចេញពីមនុស្សដែលទើបនឹងចាប់ផ្តើមមុខជំនួញរបស់ពួកគេ។ យើងចូលធ្វើការនៅពេលដែលក្រុមហ៊ុនទើបចាប់ផ្តើមបែបនេះ នឹងធ្វើឱ្យយើងរៀនពី

វិធីដែលគេធ្វើជំនួញបានច្រើន។ យើងអាចដឹងថា ពេលណាក្រុមហ៊ុនចំណេញច្រើន និងដោយសារមូលហេតុអ្វី? តើការប្រើប្រាស់លុយទៅលើប្រព័ន្ធផ្សព្វផ្សាយ មានប្រយោជន៍ឬអត់? មេរៀនទាំងនេះ អាចជួយយើង នៅពេលយើងចង់ចាប់ផ្ដើមជំនួញផ្ទាល់ខ្លួន។

ក្នុងក្រុមហ៊ុនធំ រឿងទាំងអស់នេះ ត្រូវគេលាក់ជិត។ គេគិតថា យើងមិនបាច់ចង់ដឹងទេ ព្រោះយើងគ្មានសមត្ថភាពបើកមុខជំនួញដដែល។ ជួនកាល គេអាចខ្លាចយើងយកអ្វីដែលគេធ្វើ ទៅបង្កើតមុខជំនួញខ្លួនឯងដែរ។ ពួកគេខ្លាចគ្រប់យ៉ាង ហេតុនេះអ្វីដែលសំខាន់ក្នុងផ្នែកជំនួញ យើងមិនអាចដឹងឡើយ។

យើងអាចនឹងគិតថា បើទៅទិញសៀវភៅជំនួញអាន ប្រហែលជាងាយជាង។ វាពិតជាងាយមែន ហើយក៏មិនបានផលមែនដែរ។ សៀវភៅជំនួញ ជាការដកស្រង់ពីបទពិសោធន៍របស់អ្នកដទៃប៉ុណ្ណោះ។ យើងអាចអានបាន តែយើងមិនធ្លាប់ឆ្លងកាត់ដូច្នេះការយល់របស់យើង ក៏មិនគ្រប់គ្រាន់ដែរ។ យើងអាចអានពីមូលដ្ឋានគ្រឹះក្នុងការគិតរបៀបអ្នកជំនួញ តែយើងមិនអាចដឹងថា អ្នកជំនួញធ្វើអ្វីខ្លះ ក្នុងសង្គមពិតទេ។ វិធីប្រើលុយក្រោមតុ វិធីស្គាល់អ្នកនយោបាយ ការបង្កើតខ្នងបង្អែក ការបោកប្រាស់អតិថិជន ការប្រើសប្បុរសធម៌ដើម្បីបង្កើតកេរ្តិ៍ឈ្មោះ ការតាំងខ្លួនជា Idol ពត៌មានក្លែងក្លាយ និងអបិយជំនឿផ្សេងៗ សុទ្ធតែមិនមានបញ្ចូលទៅក្នុងសៀវភៅជំនួញ។ បើចង់ដឹង អានសៀវភៅ បើចង់ចេះច្បាស់ ដាក់ពាក្យធ្វើការ។

គេថា បើយើងចង់រកស៊ីអ្វី គួរតែទៅធ្វើការឱ្យគេក្នុងផ្នែកនោះសិន។ បើបទពិសោធន៍ការងារ អាចក្លាយជាបទពិសោធន៍ផ្នែកជំនួញ យើងនឹងចំណេញបានទ្វេរដង។ ការធ្វើជំនួញ ដោយគ្មានបទពិសោធន៍ ជារឿងប្រថុយ ហេតុនេះបើអាច យកបទពិសោធន៍អ្នកដទៃទៅប្រើសិនក៏បានដែរ។ យើងមើលគេរកស៊ីឱ្យហើយ ចាំសាកល្បងរកស៊ីខ្លួនឯង ក៏មិនខុសក្បួនខ្នាតអ្វីដែរ។

## មានទំនាក់ទំនងល្អ

ក្រុមហ៊ុនធំ ប្រៀបដូចជានៅក្នុងរាជវាំងស្រុកចិន។ វាមានការបែងចែកបក្សពួក កាច់កុងគ្នា ឬអាងអំណាចជាច្រើន។ ខ្ញុំនៅចាំកាលខ្ញុំទៅធ្វើការនៅកាស៊ីណូដំបូង គេចង់អូសខ្ញុំឱ្យចូលខាងនេះ ខាងនោះ ដើម្បីបន្ថែមបក្សពួកគេ។ ខ្ញុំគ្រាន់តែចង់មកធ្វើការទេ មិនបានចង់ធ្វើជាអ្នកម្នាងអីទេ។ អ្នកណាចង់ដណ្ដើម ធ្វើទៅ ខ្ញុំសូមដកខ្លួនហើយ។

ទំនាក់ទំនងក្នុងក្រុមហ៊ុនតូច អាចល្អជាងនេះ ព្រោះក្រុមហ៊ុនតូច ច្រើនតែធ្វើការជាលក្ខណៈគ្រួសារ។ ភាពជិតស្និទ្ធ មានច្រើនជាងអ្នកធ្វើការក្នុងក្រុមហ៊ុនធំ។ ក្នុងក្រុមហ៊ុនតូច អំណាចស្ថិតលើម្ចាស់ក្រុមហ៊ុនទាំងស្រុង ហេតុនេះ បុគ្គលិកទាំងអស់គឺធ្វើការដោយស្មើភាពគ្នា ព្រោះម្នាក់ៗសុទ្ធតែនៅខាងម្ចាស់ក្រុមហ៊ុនដូចគ្នា។

# រៀនដោះស្រាយពេលដាច់លុយ

ពេលដែលក្រុមហ៊ុនខាត ហើយអត់មានប្រាក់ខែបើកឱ្យបុគ្គលិកគ្រប់ ទើបខ្ញុំដឹងថាត្រូវចាត់ការចំណាយប្រចាំថ្ងៃដោយរបៀបណា។ និយាយទៅ ក្រុមហ៊ុនតូច អ្វីក៏ល្អដែរ តែរឿងប្រាក់ខែមួយមិនបាច់សង្ឃឹមទេ។ យើងអាចរើសបានរវាងលុយ និងការរៀនសូត្រ។ ខ្ញុំអាចទុកលុយចោលមួយឡែកសិន ព្រោះខ្ញុំមិនសូវចាយធំទេ។

លុយយើងមានតិច យើងអាចចាយរួចខ្លួន និងសន្សំបានខ្លះ បើយើងចេះរៀបចំការចំណាយឱ្យត្រឹមត្រូវ។ វិធីរៀបចំ គឺងាយទេ។ យើងទិញអ្វីដែលចាំបាច់ និងទិញអ្វីដែលអាចផ្ដល់ប្រយោជន៍ត្រលប់មកវិញស្មើនឹងតម្លៃ ឬលើសពីតម្លៃដែលយើងចំណាយ។ មុននឹងទិញ យើងគិតមុនសិន ថាបើទិញហើយ យើងនឹងប្រើវាបានប៉ុន្មានដង ហើយប្រើវាដើម្បីអ្វី។ បើយើងឆ្លើយមិនចេញ បានន័យថា របស់នោះមិនទាន់ចាំបាច់ទេ។

កាលខ្ញុំធ្វើការក្នុងក្រុមហ៊ុនតូច ក្នុងរយៈពេល១០ខែ មានយ៉ាងតិចណាស់ ៣ខែដែលខ្ញុំដាច់លុយ។ ពេលខ្លះ ខ្ញុំមិនទៅធ្វើការ ព្រោះគ្មានលុយជាប់ខ្លួន។ ពេលខ្លះម៉ាក់ខ្ញុំគាត់ជួយឱ្យលុយចាយប៉ុន្មានថ្ងៃ ហើយដល់ពេលបើកប្រាក់ខែមក ខ្ញុំយកទៅសងគាត់វិញ។

យើងរៀនស្គាល់ពីភាពលំបាកនៅពេលខ្វះលុយ ទើបធ្វើឱ្យយើងចេះស្រលាញ់លុយ និងដឹងពីវិធីចាយ។ យើងមិនស្រលាញ់លុយ រហូតដល់ក្លាយជាមនុស្សមុខលុយទេ តែយើងមិនគិតតាមមនុស្សមួយចំនួនដែលយល់ថា លុយមិនសំខាន់។ ទាល់តែមានលុយសិន ទើបយើងអាចធ្វើរឿងផ្សេងបាន។

# យើងមិនធ្វើការក្នុងក្រុមហ៊ុនតូចរហូតទេ

ចំណុចទាំង១០ខាងលើនេះ គឺខ្ញុំសរសេរមុនពេលលាឈប់ពីក្រុមហ៊ុនចាស់ ហើយយកមកបន្ថែមខ្លះក្រោយពេលធ្វើការក្នុងក្រុមហ៊ុនថ្មី។ ខ្ញុំអាចនិយាយបានថា ការធ្វើការក្នុងក្រុមហ៊ុនតូច ជាគ្រឹះសម្រាប់យើងបានមកធ្វើការនៅកន្លែងធំជាង។ បើគ្មានឈ្នាន់ យើងក៏ពិបាកឡើងដែរ។ បទពិសោធន៍ក្នុងក្រុមហ៊ុនតូច ធ្វើឱ្យយើងមានឱកាសរកការងារក្នុងក្រុមហ៊ុនធំ។

យើងមិនអាចធ្វើការក្នុងក្រុមហ៊ុនតូចរហូតបានទេ។ យើងត្រូវការផ្លាស់ប្តូរជីវភាពយើងដែរ ហេតុនេះបើមិនប្តូរការងារ យើងច្បាស់ជាងាប់ក្រឡាជាមួយគេឯងហើយ។ យើងអាចចាត់ទុកក្រុមហ៊ុនតូច ជាថ្នាក់រៀនមួយសម្រាប់យើង។ បើយើងធ្វើបានពិន្ទុល្អ យើងអាចឡើងថ្នាក់មួយហើយមួយទៀត រហូតដល់យើងអស់ចិត្ត។ ពេលដែលយើងអស់ចិត្ត ជាពេលដែលយើងចូលនិវត្តន៍តែម្តង។

ខ្ញុំគាំទ្រការធ្វើការក្នុងក្រុមហ៊ុនតូច សម្រាប់អ្នកទើបនឹងចេញធ្វើការដំបូង ឬចង់រៀនជំនាញអ្វីថ្មី។ ក្រោយពេលមានបទពិសោធន៍ល្មមហើយ រកផ្លូវដើរចេញទៅ។ គិតពីខ្លួនឯងឱ្យបានច្រើន កុំខ្វល់ថាក្រុមហ៊ុនមានមនុស្សធ្វើការឬអត់ ព្រោះវាមិនមែនជាបញ្ហារបស់យើងទេ។ បញ្ហារបស់យើង គឺអនាគតខ្លួនឯង។ ការងារដែលយើងប្រឹងធ្វើ ក៏ដើម្បីអនាគតដែរ។ បើការងារថ្មីល្អជាង រៀនខ្លួនទៅធ្វើការងារថ្មី។

សម្រាប់អ្នកដែលទើបនឹងចាប់ផ្តើមធ្វើការដំបូង សូមកុំគិតថា ក្រុមហ៊ុនតូច មិនល្អ។ សាកធ្វើប៉ុន្មានខែសិនទៅ យើងនឹងដឹងមិនខាន។ ពេលខ្លះ យើងនៅក្មេងពេកក្រុមហ៊ុនធំក៏មិនហ៊ានយកយើងដែរ ហេតុនេះមានតែត្រូវពឹងក្រុមហ៊ុនតូច ដើម្បីបណ្តុះជំនាញក្នុងខ្លួនសិន។

# ៣

# ជំនាញ ជាខ្លួន

អ្នកមានខ្សែ គេអាងខ្សែធ្វើជាខ្នង ចំណែកអ្នកដែលគ្មានខ្សែ ត្រូវអាងលើជំនាញ។ នៅក្នុងក្រុមហ៊ុនណាក៏ដោយ ក៏ជៀសមិនផុត ពីមានអ្នកដែលចូលធ្វើការអាងខ្សែដែរ។ ពួកគេមិនសូវជាមានសមត្ថភាពច្បាស់ទេ ប៉ុន្តែអាចមកធ្វើការបានដោយមានអ្នកចាំជួយពីក្រោយ។ យើងមិនទៅប៉ះពាល់ ឬប្រណែននឹងគេមានខ្សែនោះទេ ព្រោះបើធ្វើបែបនោះ វាធ្វើឱ្យខាតពេល។

បើគេមានអ្វីអាង យើងក៏ត្រូវរកអ្វីមកអាងដែរ។ ក្រៅពីខ្សែ គេនៅត្រូវការអ្នកមានជំនាញទៀតដើម្បីឱ្យកិច្ចការទៅមុខលឿន។ បើយើងមានជំនាញមួយ ឬពីរជាប់ខ្លួន យើងក៏មានឱកាសទទួលបានការយកចិត្តទុកដាក់ និងលើកតម្កើងដូចអ្នកមានខ្សែដែរ។ គេមិនទុកយើងជាគ្នាឯងមែន តែយើងមិនមែនជាអ្នកក្រៅក្នុងភ្នែកគេ។

ជំនាញ ត្រូវតែរៀន និងអនុវត្ត ទើបមាន។ បើតាមសម្ដីរបស់ប្រធានក្រុមហ៊ុនខ្ញុំចាស់គាត់ប្រាប់ថា “បើចង់បានជំនាញមួយល្មមអាចធ្វើការបាន ត្រូវការពេលពី៦ខែ ទៅ៨ខែ”។ គាត់និយាយលើផ្នែកអាយធី ប៉ុន្តែជំនាញផ្នែកផ្សេងទៀតក៏មិនខុសគ្នាប៉ុន្មានដែរ។ ភាគច្រើនកន្លែងបង្រៀនសិស្សមួយចំនួនផ្ដល់ពេលឱ្យសិស្ស៣ខែ ដើម្បីរៀនពីជំនាញមួយ តែតាមពិត សិស្សមិនទាន់មានជំនាញទេក្នុងរយៈពេលនេះទេ។ ៣ខែនោះ ជាមូលដ្ឋានគ្រឹះសម្រាប់បណ្ដុះជំនាញប៉ុណ្ណោះ។ សិស្សត្រូវបន្តអនុវត្តជាប្រចាំប៉ុន្មានខែទៀត ទើបអាចប្រើការបាន។

ពាក្យថា “ជំនាញ” ត្រូវតែយកមកប្រើបាន មិនមែនមានតែសញ្ញាបត្រមកអួតគេទេ។ ខ្ញុំគ្មានសញ្ញាបត្រជាប់ខ្លួនទេ ប៉ុន្តែខ្ញុំអាចធ្វើការបាន ហេតុនេះខ្ញុំអាចប្រាប់គេថា “ខ្ញុំ

មានជំនាញ”។ ជំនាញ បង្ហាញចេញមកតាមរយៈការធ្វើ និងការពេញចិត្តរបស់អ្នកដទៃ។ ជំនាញយើងមិនដល់កម្រិត ក៏មិនអាចបំពេញចិត្តថៅកែបានដែរ។ ថៅកែមិនពេញចិត្ត យើងក៏មិនអាចយកជំនាញមកធ្វើជាខ្នងបានដូចគ្នា។

# ជំនាញពីរ

បច្ចុប្បន្ននេះ ខ្ញុំធ្វើការដោយមានជំនាញពីរ។ ទីមួយ គឺក្រាហ្វិចឌីហ្សាញ ដែលខ្ញុំបានពីការងារចាស់។ ទីពីរ គឺផ្នែក E-Learning ដែលខ្ញុំកំពុងតែរៀនធ្វើ។ គេទុកពេលឱ្យខ្ញុំ៣ខែដំបូង ដើម្បីរៀនពី E-Learning ដោយយកឯកសារពីអ៊ីនធឺណេតមករៀន។ ក្រោយចប់៣ខែ ទើបគេចាប់ផ្តើមឱ្យខ្ញុំបង្កើតមេរៀនសម្រាប់ដាក់លក់។ មេរៀនដែលខ្ញុំធ្វើ ទាក់ទងនឹងសាសនាគ្រឹស្ត និងវប្បធម៌តាមតំបន់ ដូច្នេះខ្ញុំត្រូវអង្គុយអានឯកសារទាំងនោះទៀត។

E-Learning មិនទាន់ក្លាយជាជំនាញពិតប្រាកដរបស់ខ្ញុំមែន តែឥលូវនេះ ខ្ញុំអាចធ្វើការបានដូចបុគ្គលិកផ្សេងទៀតដែរ។ ទោះបីយឺតជាងគេ ក៏ខ្ញុំអាចធ្វើឱ្យចប់ចុងចប់ដើមដែរ។ ជំនាញទាំងពីរនេះ នឹងជួយឱ្យខ្ញុំទទួលបានការកត់សម្គាល់ និងទុកចិត្តពីថ្នាក់លើ។ ពួកគេមិនបាច់ភ័យថាខ្ញុំធ្វើមិនចេញ ពេលដាក់កិច្ចការឱ្យខ្ញុំធ្វើទេ។ ពួកគេក៏អាចរំពឹងបានថា ស្នាដៃរបស់ខ្ញុំក៏មិនអន់ដែរ។

ខ្ញុំធ្វើការដោយមិនស្គាល់ និងមិនទ្រដើងអ្នកណាទាំងអស់។ ខ្ញុំធ្វើការបាន ព្រោះខ្ញុំមានជំនាញប៉ុណ្ណោះ។ គេយកខ្ញុំចូលធ្វើការ ក៏ព្រោះតែគេគិតថាខ្ញុំមានអ្វីដែលគេចង់បាន។

# បន្ថែមជំនាញ

ចាត់ទុកថាខ្ញុំចង់បានច្រើន ក៏ថាបាន ព្រោះក្រៅពីជំនាញពីរនេះហើយ ខ្ញុំនៅមានជំនាញពីរទៀតដែលប៉ងនឹងយកឱ្យបាន។ មួយ គឺធ្វើ animation (វីដេអូចលនា) និងមួយទៀត គឺសរសេរកូដទូរស័ព្ទ។ ចំពោះ Animation ខ្ញុំចាប់ផ្តើមរៀនបណ្តើរៗ

ហើយ ព្រោះវាមិនស្មុគស្មាញពិបាកដូចការសរសេរកូដ។ ការសរសេរកូដ ទាមទារពេលវេលាច្រើន ហេតុនេះខ្ញុំមិនទាន់អាចធ្វើបាន។

## ចុះហេតុអ្វីបានជាយើងត្រូវបន្ថែមជំនាញថ្មីឱ្យខ្លួនឯង?

យើងត្រូវដឹងថា ពិភពលោកដើរលឿនណាស់។ សូម្បីតែប្រទេសយើង ដែលជាប្រទេសតូចតាច ក៏ដើរលឿនដែរ។ ជំនាញដែលយើងមានក្នុងថ្ងៃនេះ អាចនឹងត្រូវគេបោះចោល នៅថ្ងៃស្អែកបាន។ ជំនាញថ្មីៗ ត្រូវបានគេបង្កើតឡើងរហូត។ បើយើងមិនអើពើនឹងរឿងនេះ យើងគង់តែត្រូវគេទុកចោលម្នាក់ឯងទេ។

ឥលូវនេះ ការរៀនជំនាញថ្មី លែងពិបាកទៀតហើយ។ ឱ្យមានតែកុំព្យូទ័រ និងភ្ជាប់អ៊ីនធឺណេតដែលដើរលឿនបន្តិច យើងអាចរៀនអ្វីក៏បាន។ ពេលខ្លះ យើងក៏ត្រូវបង់លុយដែរ ព្រោះមេរៀនខ្លះល្អពេក គេមិនអាចដាក់ឱ្យយើងរៀន free បាន។ ខ្ញុំធ្វើការក្នុងផ្នែកនេះ ហេតុនេះ មេរៀនភាគច្រើន គឺខ្ញុំទិញពីគេ។ ខ្ញុំគោរព និងគាំទ្រការប្រឹងប្រែងធ្វើមេរៀនរបស់គេ ហើយក៏ចង់ចេះពីគេដែរ។

ខ្ញុំរៀននៅលើ Udemy ព្រោះវាសម្បូរមេរៀនថ្មី ហើយមានច្រើនប្រភេទទៀត។ ចំពោះតម្លៃ គឺខុសគ្នាទៅតាមគុណភាពមេរៀន និងរយៈពេលរៀន។ មេរៀនធ្វើ animation ដែលខ្ញុំទិញ ត្រូវការពេលតែ៣ម៉ោងប៉ុណ្ណោះដើម្បីបញ្ចប់ តែយើងមិនមែនរៀន ៣ម៉ោងឱ្យចប់ទេ។ ខ្ញុំរៀនមួយថ្ងៃបន្តិច និងធ្វើតាមគេ។ ពេលរៀនចប់គេចេញសញ្ញាបត្រឱ្យ ដូច្នេះបើពេលណាខ្ញុំត្រូវការប្តូរការងារ ខ្ញុំអាចផ្ញើរសញ្ញាបត្រនោះទៅឱ្យក្រុមហ៊ុនថ្មីឆែកមើលបាន។ Udemy ក៏មានឈ្មោះល្បីគួរសមដែរ ដូច្នេះខ្ញុំរៀនជំនាញពីនោះមក ធ្វើឱ្យជំនាញខ្ញុំឡើងមួយកម្រិតទៀត។

## ចុះតើពេលណាដែលយើងគួររៀនជំនាញថ្មី?

ដោយសារតែជំនាញ ត្រូវការពេលលើសពីកន្លះឆ្នាំ ដូច្នេះខ្ញុំគិតថា មួយឆ្នាំ យើងគួរតែរៀនជំនាញថ្មីមួយបានហើយ។ បើយើងមានសមត្ថភាពខ្លាំង រៀនពីរក៏កាន់តែល្អ។ រៀនយកច្បាស់ មួយដឹងមួយ ស្រួលប្រើជាង។

ឆ្នាំនេះ ខ្ញុំរៀនពី animation ហើយបើសល់ពេល ខ្ញុំនឹងរៀនសរសេរកូដបន្តទៀត។ ខ្ញុំរៀនជំនាញថ្មីរាល់ឆ្នាំ ព្រោះដូចខ្ញុំបញ្ជាក់ពីដើមហើយថា ខ្ញុំអាងលើជំនាញ។ បើអាង ត្រូវរកអ្វីមកអាងឱ្យបានច្រើន ដូចពួកកូនអ្នកមាន ហៅបងប្អូនមកជួយឈ្លោះគ្នាពេលមានរឿងអ៊ីចឹង។ មកកាន់តែច្រើន កាន់តែមានប្រៀបជាងគេ។ ខ្ញុំមានជំនាញកាន់តែច្រើន ខ្ញុំកាន់តែមិនខ្លាច។ ខ្ញុំមិនមែនទៅឈ្លោះគ្នាទេ តែខ្ញុំមិនចូលចិត្តធ្វើការមើលទឹកមុខគេ។ ជំនាញ ជាដៃជើងរបស់ខ្ញុំ។

# ជំនាញ អាចបង្កើតខ្សែ

យើងគ្មានខ្សែនឹងគេមែន តែមិនប្រាកដថាយើងមិនអាចបង្កើតខ្សែបានទេ។ ជំនាញដែលយើងមាន នឹងធ្វើឱ្យថ្នាក់លើមើលឃើញយើង ហើយចង់ទុកយើងឱ្យនៅជួយគេបន្តទៀត។ គេអាចនឹងចង់បោកយើងប្រើឱ្យអស់សាច់មែន តែគេនឹងធ្វើល្អដាក់យើង ហើយមិនរករឿងយើងផ្ដេសផ្ដាសទេ។ យើងនឹងទទួលបានសិទ្ធិពិសេសមួយចំនួនដែលបុគ្គលិកផ្សេងមិនមាន។ នេះជារឿងល្អសម្រាប់ជីវិតខ្ញុំគេ។

អ្នកដែលចូលតាមខ្សែ ពេលធ្វើការ តែងតែមានគេតាមរិះគន់ ឬនិយាយពីក្រោយខ្នងជានិច្ច។ ធម្មជាតិរបស់មនុស្ស គឺច្រណែនគ្នាបែបនេះហើយ ជាពិសេសអ្វីដែលខ្លួនឯងគ្មាន។ ប៉ុន្តែយើងដែលយកជំនាញមកធ្វើជាខ្សែនេះ គ្មានអ្នកណាមកច្រណែនទេ ព្រោះគេដឹងថា យើងមានជំនាញ។ អ្នកណាក៏ឱ្យតម្លៃលើជំនាញដែរ មិនថាអ្នកនោះទើបប្រឡូកក្នុងការងារ ឬចាស់វង្វេងទេ។

យើងបានអ្វីដែលអ្នកផ្សេងបាន ហើយអ្នកផ្សេងមកជួយអបអរយើងទៀត។ ជំនាញនាំរឿងល្អមកក្នុងការងារយើង។ ធ្វើការត្រូវតែមានខ្សែ ទើបងាយស្រួល។ ខ្ញុំមិនបង្រៀនអ្នកទាំងអស់គ្នាពីរឿងពុករលួយ ឬអែបអបគេទេ ខ្ញុំប្រាប់ពីការយកជំនាញទៅបង្កើតខ្សែប៉ុណ្ណោះ។

នៅក្នុងក្រុមហ៊ុនចាស់ ខ្ញុំធ្វើការផ្នែកក្រាហ្វិចឌីហ្សាញផង និងធ្វើជាគ្រូបង្រៀនឱ្យសាលារបស់ក្រុមហ៊ុនផង។ ខ្ញុំដើរតួពីរ ដោយមិនប្រកែកអ្វីទាំងអស់។ ក្រុមហ៊ុនមើលឃើញថា ខ្ញុំមិនជំពេក ហើយក៏មិនអត់ប្រយោជន៍ពេកដែរ ហេតុនេះគេផ្ដល់

សិទ្ធិឱ្យខ្ញុំជាច្រើន ដូចជា យកសៀវភៅមកលក់ដោយខ្លួនឯង, មិនបាច់មកធ្វើការពេលព្រឹក, ឈប់មិនបាច់សុំច្បាប់, ចេញចូលមិនបាច់ស្កេនមេដៃ, ដេកក្នុងម៉ោងធ្វើការ និងចេញចូលដោយមិនបាច់គោះទ្វារ។ អ្នកដែលមិនដឹង គេនឹងគិតថា ខ្ញុំជាបក្សពួកជាមួយមេធំដែរ តែតាមពិតខ្ញុំគ្រាន់តែជាខ្ញុំគេប៉ុណ្ណោះ តែខ្ញុំក៏មិនបាច់ដើរប្រាប់គេដែរ ព្រោះនេះជារឿងសម្ងាត់ក្នុងការងារ។

ខ្ញុំប្រើជំនាញធ្វើការ មេត្រូវការជំនាញរបស់ខ្ញុំ ដូច្នេះជំនាញក៏ក្លាយជាខ្នងរបស់ខ្ញុំ។ ពេលគេត្រូវការប្រើខ្ញុំឱ្យធ្វើអី គេនឹងនិយាយស្រួលបួលជាមួយខ្ញុំ ព្រោះបើមិនអ៊ីចឹងទេ ខ្ញុំនឹងធ្វើឱ្យយឺត ហើយស្ទះការងារទាំងអស់គ្នា។ ខ្ញុំមិនមែនជាបុគ្គលិកល្អទេតាំងពីដើមមក តែខ្ញុំមានអ្វីដែលក្រុមហ៊ុនត្រូវការ ហេតុនេះខ្ញុំគិតថា ខ្ញុំអាចអាងបាន។ បើពេលណាគេទ្រាំលែងបាន គេអាចដេញខ្ញុំបាន ព្រោះគេមានសិទ្ធិ។

អ្នកទាំងអស់គ្នា មិនបាច់យកជំនាញមកអាងដូចខ្ញុំទេ ព្រោះខ្ញុំមានចរិតបែបនេះ។ ខ្ញុំជាខ្ញុំគេសម័យអាយធី ដូច្នេះខ្ញុំចេះអាង ចេះរករឿង ចេះទាមទារ និងចេះធ្វើឱ្យក្រុមហ៊ុនឈឺក្បាល។ ជំនាញ ដែលខ្ញុំមាន នឹងជួយខ្ញុំបន្តទៀត ដោយមិនឱ្យខ្ញុំដួលមួយកន្លែងទេ។ ជំនាញ បង្កើតជំនឿចិត្តខ្ញុំ តែមិនដល់ថ្នាក់អឿលែងដឹងខុសត្រូវនោះទេ។ ខ្ញុំធ្វើការមានរបៀបខ្លួនឯង ហើយថ្នាក់លើក៏មិនថាអីឱ្យខ្ញុំដែរ។

ពេលយើងមានជំនាញ យើងអឿដោយមិនបាច់មានខ្សែ ព្រោះជំនាញដើរតួជាខ្សែរបស់យើងរួចហើយ។ កុំភ្លេច បើជំនាញយើងមិនទាន់ដល់ចំណុចល្អមទេ គេក៏មិនឱ្យយើងធ្វើអីតាមចិត្តដែរ។

# ៤

# ប្រាក់ខែ ជាតម្លៃ

វិធីងាយដើម្បីដឹងថា ក្រុមហ៊ុនដែលយើងកំពុងធ្វើការ ឱ្យតម្លៃយើងដល់កម្រិតណា គឺមើលលើប្រាក់ខែដែលគេបើកឱ្យយើង។ អ្នកជំនួញ មានខួរក្បាលឆ្លាតណាស់ក្នុងការគិតលុយ។ គេមិនបើកលុយឱ្យយើង លើសពីអ្វីដែលយើងអាចធ្វើបានទេ។ គេអាចនឹងស្មានដឹងថា សមត្ថភាពយើង សមនឹងទទួលបានប្រាក់ខែប៉ុន្មាន។

បើមើលលើប្រាក់ខែ យើងអាចដឹងថា តើក្រុមហ៊ុនដែលយើងប្រឹងធ្វើការឱ្យនោះ មើលយើងជាមនុស្សប្រភេទណា។ អ្នកបានប្រាក់ខែតិច មានន័យថា មានតម្លៃតិចនៅក្នុងភ្នែករបស់ក្រុមហ៊ុន។ អ្នកដែលបានប្រាក់ខែខ្ពស់ ហើយចេះតែឡើងរហូត បញ្ជាក់ថា សមត្ថភាពគេខ្ពស់ ហើយគេជួយរកប្រយោជន៍ដល់ក្រុមហ៊ុនបានច្រើនជាងមុន។

ប្រាក់ខែដែលយើងទទួលបាន មិនមែនជារឿងអាម៉ាសទេ តែជាអ្នកប្រាប់យើងថា ពេលនេះ តម្លៃរបស់យើង គឺប៉ុណ្ណឹង។ អ្នកដែលចេះគិត គេនឹងមិនទុកឱ្យប្រាក់ខែរបស់គេងាប់ក្រឡាទេ។ គេនឹងព្យាយាមធ្វើអ្វីផ្សេងទៀតដើម្បីឱ្យខ្លួនគេកាន់តែមានតម្លៃក្នុងក្រុមហ៊ុន។

## ពេលចូលធ្វើការដំបូង

ជាទូទៅ នៅពេលបុគ្គលិកចូលធ្វើការដំបូង ក្រុមហ៊ុនតែងតែមានការសម្ភាសន៍ ម្តង ឬពីរដងដើម្បីដឹងពីសមត្ថភាព ហើយលៃលកប្រាក់ខែទៅតាមនោះ។ គេនឹងសួរយើងថា តើរំពឹងនឹងបានប្រាក់ខែប៉ុន្មាន? សំណួរនេះ តែងតែធ្វើឱ្យអ្នកទើបនឹងចេញ

ធ្វើការ ពិបាកឆ្លើយ។ បើឆ្លើយថា ចង់បានច្រើនពេក ខ្លាចគេមិនឱ្យការងារធ្វើ។ បើឆ្លើយតិចពេក ខ្លាចខុសខ្លួនឯង ដូច្នេះពេលត្រូវគេសួរបែបនេះ អ្នកណាក៏គាំងដែរ។

នៅពេលខ្ញុំធ្វើការដំបូង គេសួររឿងប្រាក់ខែ ខ្ញុំឆ្លើយថា "អត់ដឹង"។ ខ្ញុំអត់ដឹងមែន ព្រោះគ្មានបទពិសោធន៍ការងារពិតប្រាកដពីមុនមក។ តែក្រោយពេលខ្ញុំប្តូរការងារប៉ុន្មានដង ខ្ញុំគិតប្រាក់ខែរបស់ខ្ញុំទៅតាមបទពិសោធន៍នឹងអ្វីដែលខ្ញុំចេះ។ ខ្ញុំមិនចេះទារគេឱ្យហួសសមត្ថភាពទេ ព្រោះខ្ញុំចង់មើលថា តើក្រុមហ៊ុនមើលឃើញតម្លៃរបស់ខ្ញុំប៉ុណ្ណា។ ម្យ៉ាងទៀត ពេលប្តូរការងារបែបនេះ ខ្ញុំក៏មិនច្បាស់ថា ខ្ញុំអាចធ្វើបាន ឬអត់ដែរ។

ខ្ញុំរាប់លុយតាមឆ្នាំដែលខ្ញុំធ្វើការ។ ឥលូវ ខ្ញុំមានបទពិសោធន៍ក្នុងផ្នែកក្រាហ្វិចឌីហ្សាញ២ឆ្នាំជាងហើយ ដូច្នេះខ្ញុំគុណលុយរបស់ខ្ញុំទៅតាមហ្នឹង។ ខ្ញុំប្រាប់គេតាមត្រង់ថា លុយប៉ុណ្ណឹងទើបខ្ញុំព្រមធ្វើ ហើយគេនឹងយកទៅពិភាក្សាគ្នា។ បើគេព្រម ខ្ញុំក៏ព្រមដែរ។ បើគេមិនព្រម គេនឹងលើកសំណើរប្រាក់ខែរបស់គេឱ្យយើងគិតវិញម្តង។ បើមិនលើសខ្វះគ្នាច្រើនទេ ខ្ញុំនឹងសម្រេចចិត្តទៅធ្វើការ។

ពេលចូលដំបូង រឿងប្រាក់ខែ អាចជាការស្មានទាំងសងខាង។ ក្រុមហ៊ុន ក៏ស្មាន យើងក៏ស្មាន។ ក្រោយប៉ុន្មានខែ ខ្ញុំមើលឃើញចំណុចផ្សេងទៀត។

# ពេលធ្វើបាន៣ខែ

ជាទូទៅ គ្រប់កន្លែងការងារ គេទុកពេលឱ្យយើងរៀន៣ខែ មុននឹងសម្រេចថា យើងអាចនៅធ្វើការបន្តទៀត ឬដើរចេញ។ ក្នុងពេល៣ខែនេះ យើងប្រៀបដូចជាសិស្សម្នាក់ដែលត្រូវរៀនគ្រប់មុខទាក់ទងនឹងការងារ។

ទំហំនៃការងារ ជាអ្នកកំណត់ពេលវេលានៃការរៀនបន្ថែមរបស់យើង។ ខ្ញុំធ្វើការក្នុងផ្នែកអាយធី ហេតុនេះអ្វីដែលត្រូវរៀន គឺមានថ្មីរហូត។ រាល់អាទិត្យ នឹងមានអត្ថបទថ្មី ឬគន្លឹះជាច្រើន រង់ចាំខ្ញុំទៅរៀន។ ខ្ញុំរៀនតពីគេប៉ុណ្ណោះ អ្វីក៏ខ្ញុំមិនចេះដែរ។

ក្នុងរយៈពេល៣ខែនេះ យើងនឹងអាចដឹងដោយខ្លួនឯងថា ប្រាក់ខែដែលគេបើកឱ្យយើង សមនឹងសមត្ថភាពយើងឬមិនសម។ យើងប្រៀបធៀបអ្វីដែលយើងអាចធ្វើបាន និងអ្វីដែលគេឱ្យយើងធ្វើ។ ជួនកាល យើងចេះហួសពីអ្វីដែលត្រូវធ្វើទៀត ប៉ុន្តែវាមិនត្រូវយកមកប្រើ ហេតុនេះមិនអាចយកអ្វីដែលយើងចេះលើសនោះ មកគិតក្នុងរឿងប្រាក់ខែបានទេ។ ខ្ញុំចេះសរសេរសៀវភៅ ប៉ុន្តែការងារខ្ញុំ គឺបង្កើតមេរៀនសម្រាប់ e-Learning ដូច្នេះវាមិនពាក់ព័ន្ធគ្នាទេ ហើយខ្ញុំក៏មិនរាប់ចំណុចនេះចូលដែរ។

តាមបទពិសោធន៍ខ្ញុំ និងមិត្តភក្តិខ្ញុំ ៣ខែ គឺល្មមនឹងឱ្យយើងមើលដឹងថា តើក្រុមហ៊ុនឱ្យតម្លៃរបស់យើង ត្រូវតាមហាងឆេងរបស់យើងឬអត់ហើយ។ ហាងឆេងនោះ គឺជំនាញ និងសមត្ថភាពក្នុងការរៀនអ្វីថ្មី។

ការងារខ្ញុំបច្ចុប្បន្ននេះ ខាងក្រុមហ៊ុនឱ្យប្រាក់ខែខ្ញុំសមនឹងអ្វីដែលខ្ញុំធ្វើណាស់។ ខ្ញុំធ្វើការយឺត ហើយទៅមិនទាន់ម៉ោង ដូច្នេះខ្ញុំគ្មានអ្វីត្រូវត៉ាទេ។ មិនមែនខ្ញុំធ្វើការមិនល្អទេ តែខ្ញុំធ្វើយឺតជាងអ្នកដទៃបន្តិច។ ខ្ញុំនៅខ្វះចំណេះដឹង និងបទពិសោធន៍បើប្រៀបនឹងអ្នកដទៃទៀតនៅក្នុងក្រុម។ ខ្ញុំត្រូវអានច្រើនដើម្បីតាមឱ្យទាន់គេ។ បើខ្ញុំតាមមិនទាន់គេទេ ក្រុមនេះនឹងយឺតដោយសារតែខ្ញុំម្នាក់ ហើយប្រាក់ខែខ្ញុំ ក៏តាមមិនទាន់គេដូចគ្នា។

# បង្កើនតម្លៃ បង្កើនប្រាក់ខែ

ដោយសារតែប្រាក់ខែចេញពីតម្លៃដែលគេមើលឃើញក្នុងខ្លួនយើង ដូច្នេះបើយើងចង់បានប្រាក់ខែច្រើន យើងត្រូវបង្ហាញតម្លៃឱ្យគេមើលឃើញកាន់តែច្រើនជាងមុន។ មុននឹងបង្ហាញបាន យើងត្រូវបង្កើនវាជាមុនសិន។

### តើអ្វីខ្លះជាតម្លៃរបស់បុគ្គលិក?

ជំនាញ ជាតម្លៃសំខាន់ទីមួយ។ បើគ្មានជំនាញទេ យើងក៏មិនអាចធ្វើការបានដែរ។ ជំនាញ អាចដោះស្រាយបញ្ហារបស់ក្រុមហ៊ុនបាន។ ក្រុមហ៊ុនទាំងអស់ ចាំបាច់ត្រូវតែមានអ្នកជំនាញតាមផ្នែក ទើបអាចរុញ ក្រុមហ៊ុននោះឱ្យដើរលើទីផ្សារបាន ជាពិសេស គឺរុញមហិច្ឆតារបស់ម្ចាស់ក្រុមហ៊ុន។

បើចង់រៀនជំនាញអ្វីមួយ អាចចុះឈ្មោះរៀនតាមអនឡាញបាន។ អ៊ីនធឺណេត ជាសាលាមួយដែលនៅជាប់នឹងខ្លួនយើង ដូច្នេះបើមិនចេះឆ្លៀតរៀនទេ កុំសង្ឃឹមថាបានជំនាញ។ ប្រើអ្វីដែលយើងមានជាប់ខ្លួនស្រាប់ ទើបយើងអាចសម្រេចគោលដៅបាន។ បើយើងចាំទាល់តែមានសាសាល្អមកបើកនៅក្នុងស្រុក ទើបយើងចុះឈ្មោះរៀន យើងគ្មានផ្លូវក្លាយជាអ្នកជំនាញទេ។ ការធ្វើជាអ្នកជំនាញ ជារឿងសប្បាយ។ រៀនមួយថ្ងៃបន្តិច យ៉ាងយូរ៣ខែ យើងនឹងអាចយកមកប្រើការបណ្តើរៗបានហើយ។

ជំនាញស្ទើរតែគ្រប់មុខ ត្រូវបានគេរៀបចំជាមេរៀននៅលើអ៊ីនធឺណេតរួចជាស្រេច នៅចាំតែយើងបង់លុយរៀនប៉ុណ្ណោះ។ ជំនាញខ្លះ មិនបាច់អស់លុយផង ព្រោះអ្នកធ្វើមានចិត្តល្អ ចង់ឱ្យអ្នកដទៃចេះ។ ខ្ញុំរៀនជំនាញផ្សេងៗនៅលើអនឡាញ ហើយវាធ្វើឱ្យខ្ញុំយល់កាន់តែច្រើនពីការងារ។

តម្លៃទីពីរ គឺបទពិសោធន៍។ យើងសាកគិតទៅមើល បើគេរើសបុគ្គលិកឱ្យចូលធ្វើការ តើគេចង់យកអ្នកដែលមានបទពិសោធន៍ស្រាប់ ឬយកអ្នកដែលគ្មានបទពិសោធន៍សោះ? គេច្បាស់ជាយកអ្នកមានបទពិសោធន៍ហើយ ព្រោះគេត្រូវការអ្នកចេះធ្វើពិតប្រាកដ។ អ្នកមិនមានបទពិសោធន៍ នឹងបង្កើតកំហុសច្រើនជាងអ្នកធ្លាប់ធ្វើ។

មេរៀន E-Larning ដំបូងដែលខ្ញុំធ្វើនៅឱ្យក្រុមហ៊ុន ត្រូវចំណាយពេលមួយខែ ទើបអាចដាក់ឱ្យគេធ្វើការ review លើកទីមួយបាន។ អ្នកដែលគេធ្លាប់ធ្វើ ប្រើពេលតែពីរអាទិត្យប៉ុណ្ណោះ។ នេះជាភាពខុសគ្នាចំពោះបទពិសោធន៍។

បទពិសោធន៍ក្នុងការងារ បានមកពីការធ្វើជាប្រចាំរបស់យើង។ យើងកាន់តែធ្វើច្រើនប៉ុណ្ណា យើងកាន់តែមានបទពិសោធន៍ច្រើនទៅតាមនោះដែរ។ សូមកុំច្រឡំបទពិសោធន៍ និងចំណេះដឹងឱ្យសោះ។ បទពិសោធន៍ បានពីការធ្វើដោយខ្លួនឯង មិនមែនគ្រាន់តែរៀនតាមសៀវភៅ ឬស្តាប់គេទេ។ ខ្ញុំអាចអង្គុយអានសៀវភៅទាក់ទងនឹងក្រាហ្វិចឌីហ្សាញឱ្យចប់១០ក្បាល តែនោះមិនមែនជាបទពិសោធន៍ទេ។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណោះ តែមិនបានធ្វើពិតប្រាកដ។ ការដឹង និងការធ្វើខុសគ្នាឆ្ងាយណាស់ ហើយនៅក្នុងក្រុមហ៊ុន គេចង់បានអ្នកធ្លាប់ធ្វើ។

តម្លៃទីបី គឺការជួយ។ យើងជួយអ្នកដទៃក្នុងក្រុមហ៊ុនឱ្យបានច្រើន យើងនឹងក្លាយជាមនុស្សមានតម្លៃក្នុងក្រុមហ៊ុន។ អ្នកណាក៏គេអាចមើលឃើញអ្វីដែលយើងធ្វើដែរ។ យើងមិនមែនទៅជួយធ្វើការងាររបស់គេទេ តែយើងជួយនៅពេលដែលមិនអាចធ្វើបាន។ ការងារគេ នៅតែជាការងារគេដដែលទេ តែយើងចូលរួមមួយផ្នែកទៅក្នុងការងាររបស់គេ។ យើងមិនដណ្ដើមទេ តែយើងជួយរុញឱ្យឆាប់ហើយ។

ពេលខ្លះ ក៏គេមិនចង់ឱ្យយើងជួយដែរ។ គេអាចខ្លាចយើងដណ្ដើមយកគុណសម្បត្តិពីគេ ឬជួយក្នុងបំណងអាក្រក់។ បើគេមិនចង់ឱ្យជួយ កុំជួយ។ កុំចិត្តល្អ នឹងអ្នកដែលមិនត្រូវការយើង។ ក្នុងការងារ មិនចេះខ្វះអ្នកដែលត្រូវការយើងជួយនោះទេ។

ពេលខ្ញុំចូលធ្វើការដំបូង គេមិនទាន់ឱ្យខ្ញុំទៅធ្វើផ្នែកE-Learning ភ្លាមទេ ព្រោះគេត្រូវការអ្នកឌីហ្សាញឱ្យជួយធ្វើការផ្នែកទីផ្សារ។ គេមិនចង់រើសបុគ្គលិកថែមទៀត ដូច្នេះគេឱ្យខ្ញុំទៅជួយខាងទីផ្សារមួយខែសិន។ ខ្ញុំមិនបដិសេធទេ ព្រោះនេះជាឱកាសបញ្ចេញស្នាដៃ ហើយដើម្បីដឹងពីផ្នែកផ្សេងផង។ ក្រោយពេលធ្វើចប់ គេក៏ធ្វើ report ដើម្បីផ្ញើទៅមេរបស់ខ្ញុំ។ គេអាចសរសើរ ឬបន្ទោសខ្ញុំ តែខ្ញុំមិនខ្វល់ទេ ព្រោះខ្ញុំបានធ្វើរួចហើយ។

នៅក្នុងក្រុមខ្ញុំ អ្នកណាក៏អាចពឹងខ្ញុំបានដែរ។ ត្រូវការរូបភាពថ្មី ខ្ញុំជួយធ្វើឱ្យបាន។ ត្រូវការអ្នកជួយរកកំហុសក្នុងមេរៀន ខ្ញុំក៏អាចជួយបាន។ ត្រូវការកាត់សម្លេង ខ្ញុំក៏អាចធ្វើបាន។ ត្រូវការគូស template វេបសាយ ក៏ខ្ញុំអាចធ្វើបាន។ ខ្ញុំជួយបានច្រើន ហើយខ្ញុំធ្វើដើម្បីបន្ថែមតម្លៃឱ្យខ្លួនឯងប៉ុណ្ណោះ។ ខ្ញុំមិនជឿលើបុណ្យបាប ហើយក៏មិនត្រូវការឱ្យគេសងគុណខ្ញុំដែរ។ ខ្ញុំចង់ធ្វើជាបុគ្គលិកមានតម្លៃ។

តម្លៃទីបួន បានមកពីការណែនាំរបស់មេខ្ញុំ គឺចរិត។ គាត់ឃើញចរិតខ្ញុំមិនសូវល្អ ដូច្នេះគាត់ឆ្លៀតពេលបាយមកនិយាយប្រាប់ខ្ញុំ។ ខ្ញុំមានចរិតអវិជ្ជមានច្រើនណាស់ ហើយមិនសូវចុះសម្រុងនឹងអ្នកដទៃទៀត ហេតុនេះគាត់ចង់ឱ្យខ្ញុំកែចេញ។ នៅពេលដែលថ្នាក់លើប្រាប់បែបនេះ បានន័យថា ចរិត ក៏ស្ថិតនៅក្នុងការវាយតម្លៃរបស់ពួកគេដែរ។ ចរិតល្អ មានតម្លៃជាងចរិតមិនល្អ។

ខ្ញុំអាចធ្វើការជាមួយអ្នកដទៃបាន តែមិនអាចស្និទ្ធស្នាលជាមួយគេគ្រប់គ្នាបានទេ។ ខ្ញុំត្រូវការពេលវេលាច្រើនណាស់ ក្នុងការស្គាល់មនុស្សម្នាក់។ អ្នកផ្សេងគេរាប់អានមិត្តភក្តិលឿនជាងខ្ញុំ។ ខ្ញុំមិនប្រាកដថាត្រូវកែនោះទេ ព្រោះខ្ញុំចង់ទុកចរិតរបស់ខ្ញុំឱ្យទៅតាមធម្មជាតិ។ អ្នកណាមិនចូលចិត្ត ក៏មិនអីដែរ។

អ្នកដែលមាន៤ចំណុចនេះ អាចចាត់ទុកជាបុគ្គលិកដែលមានតម្លៃ។ ខ្ញុំអាចមាន៣ចំណុច ដូច្នេះខ្ញុំក៏ជាបុគ្គលិកដែលមានតម្លៃដែរ។ អ្នកទាំងអស់គ្នាអាចពិនិត្យមើលនឹងដឹងពីតម្លៃរបស់ខ្លួនឯងហើយ។ យើងត្រូវដឹងពីតម្លៃរបស់យើងសិន ទើបយើងដឹងថាត្រូវលក់ឱ្យគេប៉ុន្មាន។

បើមើលរួចហើយ គិតថានៅមានចំណុចខ្វះខាត កុំបង្អង់យូរ ត្រូវរកវិធីដោះស្រាយភ្លាម។ រៀនឱ្យច្រើន ធ្វើឱ្យច្រើន ជួយគេឱ្យច្រើន និងកែចរិតមិនល្អរបស់យើងខ្លះចេញ យើងអាចបង្កើនតម្លៃបានហើយ។

# ប្រាក់ខែ ធ្វើឱ្យយើងភ្ញាក់ខ្លួន

មនុស្សយើងទាល់តែចេះភ្ញាក់ខ្លួន ទើបអាចកែខ្លួនបាន។ កត្តាដែលធ្វើឱ្យយើងភ្ញាក់ខ្លួន មានច្រើនដូចជា ស្នេហា ការបាត់បង់អ្វីមួយ ការខ្មាសគេ ពាក្យមើលងាយពីអ្នកដទៃ ឬមើលឃើញការពិតអ្វីមួយ។ នៅក្នុងការងារ ប្រាក់ខែក៏ធ្វើឱ្យយើងភ្ញាក់ខ្លួនបានដែរ។ ខ្ញុំប្រាប់ពីបទពិសោធន៍របស់ខ្ញុំដែលភ្ញាក់ខ្លួនដោយសារប្រាក់ខែ។

ខ្ញុំចូលធ្វើការបានប្រហែលជា៣ខែ គេក៏ឱ្យខ្ញុំទៅធ្វើសៀវភៅការងារ។ គេប្រាប់ថាសៀវភៅនេះអាចជួយយើងនៅពេលជួបបញ្ហាក្នុងការងារ។ អ្នកដែលចូលធ្វើការដំណាលខ្ញុំមាន៦នាក់ ដូច្នេះត្រូវទៅជាមួយគ្នា។ ក្នុងក្រុមហ៊ុនរបស់ខ្ញុំ គេមិនឱ្យបង្ហើបពីប្រាក់ខែខ្លួនឯងទេ ព្រោះគេចាត់ទុកជារឿងសម្ងាត់របស់ក្រុមហ៊ុន។ ខ្ញុំ និងមិត្តភក្តិ មិនដែលលាក់រឿងនេះទេ ព្រោះគិតថាវាមិនចាំបាច់។

ទៅដល់កន្លែងធ្វើសៀវភៅការងារ ខ្ញុំក៏ឆ្លៀតលួចមើលឯកសាររបស់គេ ព្រោះខ្ញុំចង់ដឹងថា តើក្រុមហ៊ុនមើលឃើញតម្លៃរបស់គេប៉ុន្មាន។ ក្រោយពេលមើលហើយ ខ្ញុំស្ងាត់មាត់តែម្តង ព្រោះប្រាក់ខែរបស់គេលើសខ្ញុំ៤ដង។ គេចូលក្រោយខ្ញុំប្រហែលជា

១០ថ្ងៃ ហេតុអីគេបានលុយច្រើនជាងខ្ញុំបែបនេះ? ពីមុន ខ្ញុំគិតថា ប្រាក់ខែខ្ញុំគួរសម ហើយ តែដល់ឃើញ ប្រាក់ខែគេ ធ្វើឱ្យខ្ញុំភ្ញាក់ខ្លួនតែម្តង។

គេបានលុយលើសខ្ញុំ គឺព្រោះតែគេមានបទពិសោធន៍ក្នុងការងារច្រើនជាងខ្ញុំ។ ខ្ញុំគ្មានបទពិសោធន៍ក្នុងផ្នែក e-Learning តែម្តង តែគេមានបទពិសោធន៍ពីក្រៅមក ៥ឆ្នាំហើយ។ ៥ឆ្នាំ ប្រៀបនឹងសូន្យ ចេញលទ្ធផលខុសគ្នាបែបនេះ។ ម្យ៉ាងទៀត គេមានអាយុច្រើនជាងខ្ញុំ បានន័យថា គេដឹងរឿងជីវិតច្រើនជាង។ ខ្ញុំអាចនឹងបង្កបញ្ហាខ្លះពេលធ្វើការ ព្រោះមិនទាន់គ្រប់គ្រងខ្លួនឯងបាន តែគេចាស់ទុំជាងខ្ញុំ ដូច្នេះ ក្រុមហ៊ុនទុកចិត្តគេជាង។ ចំណុចសំខាន់មួយទៀត គឺផ្នែករបស់គេ រកលុយឱ្យក្រុមហ៊ុនបានច្រើនជាងផ្នែករបស់ខ្ញុំ។

ខ្ញុំដឹងរឿងនេះហើយ យកផ្ទះគិតរកវិធី ធ្វើយ៉ាងណាបានលុយច្រើនដូចគេដែរ។ ខ្ញុំមិនសុខចិត្តនឹងលុយដែលខ្ញុំបានឥលូវនេះទេ ព្រោះខ្ញុំជឿថា ខ្ញុំអាចរកបានច្រើនជាងនេះទៀត។ ខ្ញុំមិនទៅសុំគេឡើងប្រាក់ខែទេ តែខ្ញុំសម្ងំរៀនអ្វីផ្សេងដែលខ្ញុំជឿថា មានទីផ្សារការងារល្អនៅពេលប៉ុន្មានឆ្នាំខាងមុខ។ ជំនាញខ្លះ អាចរកលុយបានច្រើន ហើយមិនបាច់ទៅធ្វើការពេញម៉ោងទៀតផង។

ពេលដឹងពីប្រាក់ខែអ្នកដទៃ ធ្វើឱ្យខ្ញុំដឹងពីតម្លៃខ្លួនឯងក្នុងក្រុមហ៊ុន ឱកាសលុយដែលខ្ញុំអាចនឹងចាប់បាន និងដឹងថាលុយមិនពិបាករកនោះទេពេលយើងចេះពិតប្រាកដ។ ប្រាក់ខែអ្នកដទៃ ធ្វើឱ្យខ្ញុំលែងខ្វល់ពីអ្វីទាំងអស់ ហើយផ្តោតការយកចិត្តទុកដាក់មកលើការងាររបស់ខ្លួនឯងវិញ។ បើក្រុមហ៊ុនមើលឃើញស្នាដៃរបស់ខ្ញុំ គេអាចនឹងបន្ថែមលុយឱ្យខ្ញុំក៏ថាបាន។ បើគេមិនឡើងឱ្យ ខ្ញុំនឹងដើរចេញ ហើយយកជំនាញដែលខ្ញុំសម្ងំរៀននោះ ទៅរកការងារផ្សេងទៀត។ ខ្ញុំធ្វើការ ដោយគ្មានភាពសាំញ៉ាំ។ បើគេមិនឱ្យតម្លៃខ្ញុំតាមអ្វីដែលខ្ញុំអាចធ្វើបាន ខ្ញុំដើរចេញ។

កុំប្រឹងធ្វើការនៅកន្លែង ដែលគេមើលមិនឃើញតម្លៃរបស់យើង។ ការងារ ជាផ្នែកមួយនៃជីវិតរបស់មនុស្ស។ បើយើងធ្វើការដោយមិនពេញថ្លៃ ជីវិតយើងក៏រស់នៅដោយមិនពេញថ្លៃដូចគ្នា។ ពេលវេលាដែលយើងទៅធ្វើការ គឺជាពេលវេលាដែល

ទៅបាត់ ហេតុនេះប្រើវាឱ្យសមនឹងតម្លៃផង។ ការមិនចេះឱ្យតម្លៃពេលវេលាប្រចាំថ្ងៃ ស្មើនឹងមើលងាយជីវិតរបស់ខ្លួន។

ប្រាក់ខែរបស់ខ្ញុំជាអ្នកចិញ្ចឹមរាងកាយខ្ញុំ តែប្រាក់ខែអ្នកដទៃ ជាអ្នកចិញ្ចឹមចិត្តខ្ញុំឱ្យប្រឹងធ្វើ ប្រឹងរៀនបន្ថែមទៀត។ បើគេអាចបានលុយច្រើន ខ្ញុំក៏អាចបានដូចគេដែរ។ ខ្ញុំប្រើប្រាក់ខែអ្នកដទៃដែលលើសខ្ញុំ ជាកម្លាំងជម្រុញខ្លួនឯងឱ្យធ្វើការបន្ត។ ខ្ញុំចង់ឡើងម្តងមួយកាំៗ ហើយទទួលយកបទពិសោធន៍បន្តិចម្តងដោយខ្លួនឯង។

បើខ្ញុំមិនដឹងថាអ្នកដទៃបានប្រាក់ខែប៉ុន្មានទេ ខ្ញុំក៏ប្រហែលជាទៅធ្វើការធម្មតា គ្មានបំណងអ្វីផ្សេងដែរ ព្រោះខ្ញុំគិតថា ប្រាក់ខែរបស់ខ្ញុំច្រើនហើយ។ នេះជារឿងល្អដែលខ្ញុំលួចមើលក្រដាសប្រាក់ខែអ្នកដទៃ។ ខ្ញុំក៏បានយករឿងនេះទៅប្រាប់មិត្តភក្តិខ្ញុំដែរ ដើម្បីឱ្យត្រៀមខ្លួនទាំងអស់គ្នាចាំយកលុយធំជាងនេះ។

កុំប្រណែនគេ ពេលដឹងថាប្រាក់ខែគេលើសយើង ព្រោះការប្រណែនមិនអាចជួយអ្វីបានទេ។ ទុកពេលដែលយកទៅប្រណែនគេនោះ មកពង្រឹងជំនាញ និងស្នាដៃរបស់យើងវិញល្អជាង។ ក្មេងៗទើបប្រណែនគ្នា មនុស្សធំគេធ្វើការដើម្បីបានអ្វីដែលគេចង់បាន។ បើប្រាក់ខែមិនអាចធ្វើឱ្យយើងភ្ញាក់ខ្លួនបាន ខ្ញុំក៏មិនដឹងថាអ្វីអាចជួយបានដែរ។

# ៥

# ស្រលាញ់ការងារ តែកុំស្រលាញ់ក្រុមហ៊ុន

វាជារឿងធម្មតាទេ ពេលយើងធ្វើការយូរឆ្នាំទៅ យើងនឹងមានចិត្តស្រលាញ់ក្រុមហ៊ុន ប៉ុន្តែនេះជាកំហុសមួយយ៉ាងធំ។ យើងមិនគួរស្រលាញ់ក្រុមហ៊ុនទេ ព្រោះយើងមិនដឹងពេលណាក្រុមហ៊ុនឈប់ស្រលាញ់យើងវិញ។ ពេលដែលគេឈប់ស្រលាញ់យើង គេនឹងដេញក្បាលយើងចេញមិនខាន។ ក្រុមហ៊ុន ត្រូវការមនុស្សមកធ្វើការ មិនមែនព្រោះតែស្រលាញ់ទេ គឺព្រោះតែប្រយោជន៍។ ក្រុមហ៊ុនត្រូវការប្រយោជន៍ប៉ុណ្ណោះ ដូច្នេះពេលយើងអស់ប្រយោជន៍ ឬមានអ្នកណាអាចផ្តល់ប្រយោជន៍ឱ្យគេច្រើនជាងយើង យើងនឹងត្រូវគេទាត់ចោល។ កុំប្រាប់ខ្ញុំថា មិនធ្លាប់ឃើញគេដេញបុគ្គលិកឈប់ឱ្យសោះ។

រូបមន្តនៃការស្រលាញ់ គឺមានទៅមានមក។ បើយើងស្រលាញ់អ្វីមួយ ត្រូវប្រាកដថា យើងនឹងទទួលបានក្តីស្រលាញ់ត្រលប់មកវិញ។ ការស្រលាញ់ក្រុមហ៊ុន ធ្វើខុសនឹងរូបមន្តនេះហើយ។ ថ្ងៃនេះគេត្រូវការយើង គេទុកយើងនៅបម្រើការងារឱ្យគេសិន ថ្ងៃក្រោយគេលែងត្រូវការ តើគេអាចនឹងលូង់ទុកយើងនៅឱ្យចង្អៀតក្រុមហ៊ុនគេទៀតទេ? ជំនួញ គឺជំនួញ។

ចុះបើមិនស្រលាញ់ក្រុមហ៊ុន តើយើងធ្វើការដោយរបៀបម៉េច ឱ្យពេញដៃពេញជើង? សំណួរនេះមានគេឆ្លើយរួចទៅហើយ។ ស្ទីវចប បាននិយាយពីចំណុចនេះថា “ត្រូវ

ស្រលាញ់អ្វីដែលយើងធ្វើ ទើបយើងធ្វើវាបានល្អ”។ អ្វីដែលយើងធ្វើ គឺការងារនៅក្នុងក្រុមហ៊ុន។ បើយើងចេះស្រលាញ់ការងារខ្លួនឯង យើងនឹងមិនបាច់ខ្វល់ក្រុមហ៊ុននឹងដេញយើងចោលពេលណាទេ។ ទោះជាគេដេញយើងចេញ យើងក៏អាចទៅរកក្រុមហ៊ុនផ្សេងដើម្បីធ្វើការនោះបានដែរ។

នៅក្រុមហ៊ុនចាស់ ខ្ញុំធ្វើការផ្នែកក្រាហ្វិចឌីហ្សាញ ដល់ពេលមកដល់កន្លែងថ្មី គេនៅតែដាក់ការងារផ្នែកនេះឱ្យខ្ញុំធ្វើដដែល។ ខ្ញុំមិនស្រលាញ់ក្រុមហ៊ុនណាទេ ដូច្នេះពេលធ្វើការងារ ខ្ញុំដាក់អារម្មណ៍ទាំងស្រុងទៅលើការងារ ហើយទឹកដៃរបស់ខ្ញុំនឹងចេញមកដូចនៅក្រុមហ៊ុនចាស់ដែរ។ គ្មានអ្វីរំខានការងារខ្ញុំទេ។ ខ្ញុំធ្វើការដូចមុន ខុសគ្នាតែកន្លែងអង្គុយ និងក្លិនអ្នកដែលអង្គុយក្បែរខ្ញុំប៉ុណ្ណោះ។

# ស្រលាញ់ការងារខ្លួនឯង

មិនថាខ្ញុំគេ ឬមិនខ្ញុំគេទេ យើងត្រូវស្រលាញ់ការងារដែលយើងធ្វើ។ បំភ្លេចក្រុមហ៊ុនចោលទៅ គិតតែការងារបានហើយ។ ការស្រលាញ់ការងារខ្លួនឯង ធ្វើឱ្យយើងមិនពិបាក ពេលប្តូរក្រុមហ៊ុនធ្វើការ។ ឱ្យតែយើងមិនចងខ្លួនឯងទៅក្រុមហ៊ុនណាមួយ យើងអាចធ្វើការបានដោយរីករាយ។

ខ្ញុំចេញពីក្រុមហ៊ុនចាស់ ដោយគ្មានស្រណោះអ្វីទាំងអស់។ ខ្ញុំប្រមូលទាំងសៀវភៅដែលខ្ញុំលក់នៅក្រុមហ៊ុនចាស់មកផ្ទះទុកទៀតផង តែខ្ញុំឱ្យលុយគេពេញថ្លៃទេ។ ខ្ញុំប្រមូលអ្វីដែលខ្ញុំគិតថា ជារបស់ខ្ញុំ មកវិញទាំងអស់ មិនឱ្យសល់ដាននៅក្រុមហ៊ុនចាស់ឡើយ។ មិនមែនខ្ញុំស្អប់ក្រុមហ៊ុនដែលខ្ញុំធ្វើការទេ តែខ្ញុំមិនខ្វល់តែម្តង។ ក្រុមហ៊ុននោះ មិនមែនជារបស់ខ្ញុំ ហេតុនេះខ្ញុំមិនដាក់ចិត្តស្រលាញ់ឱ្យខកបំណងទេ។ ខ្ញុំមិនចេះស្រលាញ់របស់អ្នកដទៃ ហើយក៏មិនចេះយករបស់អ្នកដទៃមកធ្វើឱ្យឈឺក្បាលខ្លួនឯងដែរ។ អ្វីដែលជារបស់ខ្ញុំ គឺការងារដែលខ្ញុំធ្វើ។

អ្នកដែលធ្វើការស្រលាញ់ក្រុមហ៊ុន ប្រៀបដូចជាអ្នកនយោបាយដែលឡើងកាន់ដំណែងយូរ ហើយគិតថា ប្រទេសនោះជារបស់ខ្លួនឯងអ៊ីចឹង។ មិនថាយើងធ្វើការ ១០ ឬ២០ឆ្នាំទេ យើងនៅតែមិនមែនជាម្ចាស់ក្រុមហ៊ុនដដែល។ បើចង់ធ្វើជាម្ចាស់

មានតែត្រូវដាក់ថ្នាំបំពុលថៅកែឱ្យស្លាប់ ឬបង្ខំគាត់ឱ្យផ្ទេរសិទ្ធិឱ្យយើង ប៉ុន្តែធ្វើបែប នេះមិនល្អទេ ព្រោះអ្នកជំនួញ គេមិនលូង់ឱ្យយើងធ្វើដាក់គេបានទេ។

ស្ទីវចប ជាឧទាហរណ៍ល្អជាងគេនៅពេលនិយាយដល់ការងារ។ គាត់មិនមែនជា បុគ្គលិកមែន តែគាត់ធ្លាប់ជាបុគ្គលិកគេ។ ស្ទីវចប ត្រូវការដកសិទ្ធិក្នុងការផលិត កុំព្យូទ័រនៅក្នុងក្រុមហ៊ុន ព្រោះគាត់ចំណាយដើមទុនច្រើនពេកទៅលើការស្រាវជ្រាវ កុំព្យូទ័រថ្មី។ គាត់មិនសុខចិត្ត ក៏លក់ហ៊ុនទាំងអស់របស់គាត់ ហើយដើរចេញពី ក្រុមហ៊ុនអេបផល។ ស្ទីវចបតែងតែប្រាប់គេថា គាត់ត្រូវគេបណ្តេញចេញពីក្រុមហ៊ុន តែតាមពិត គឺគាត់ខឹងនឹងគេដកសិទ្ធិរបស់គាត់ ហើយដើរចេញប៉ុណ្ណោះ។

ស្ទីវចប ជាអ្នកបង្កើតក្រុមហ៊ុនអេបផល ដូច្នេះចិត្តស្រលាញ់របស់គាត់ចំពោះ ក្រុមហ៊ុន ប្រាកដជាធំជាងយើងដែលខ្ញុំគេហើយ។ ប៉ុន្តែគាត់បានដកចិត្តស្រលាញ់ នោះចេញ ហើយដាក់វាទៅក្នុងការងារដែលគាត់ធ្វើវិញ។ គាត់ក៏យកលុយដែល នៅសល់បើកក្រុមហ៊ុន NEXT មួយទៀត ដែលផលិតកុំព្យូទ័រសម្រាប់ធ្វើគំនូរជីវចល និងកុំព្យូទ័រសម្រាប់សាលារៀន។ ស្ទីវចប ស្រលាញ់អ្វីដែលគាត់ធ្វើ ជាងស្រលាញ់ ក្រុមហ៊ុន។ ក្រុមហ៊ុនណាមិនសំខាន់ទេ ឱ្យតែគាត់បានធ្វើការងារដែលគាត់ពេញ ចិត្ត។

ក្រុមហ៊ុន NEXT មិនទទួលបានជោគជ័យខ្លាំងដូចអេបផលនោះទេ ប៉ុន្តែស្ទីវចប នៅតែបន្តធ្វើការងាររបស់គាត់ដដែល ព្រោះគាត់ស្រលាញ់ និងមានជំនឿលើវា។ ឥលូវសាកគិតទៅមើល ស្ទីវចបជាអ្នកជំនួញផង នៅមិនស្រលាញ់ក្រុមហ៊ុន ជាង ការងារ ចុះយើងគ្រាន់តែជាខ្ញុំគេ ហេតុអីបានជាស្រលាញ់ក្រុមហ៊ុនខ្លាំងម្ល៉េះ?

# អ្នកស្រលាញ់ក្រុមហ៊ុន និងអ្នកស្រលាញ់ការងារ

តើអ្នកដែលស្រលាញ់ក្រុមហ៊ុន និងអ្នកស្រលាញ់ការងារ មានអ្វីខុសគ្នា? ហើយ មួយណាល្អជាង?

បើគិតថាល្អ យើងត្រូវបែងចែងជាពីរទៀត គឺល្អសម្រាប់ខ្លួនយើង និងល្អសម្រាប់ក្រុមហ៊ុន។ សម្រាប់ខ្លួនយើង ធ្វើជាអ្នកស្រលាញ់ការងារ គឺល្អណាស់ តែបើសម្រាប់ក្រុមហ៊ុន គេបន់ឱ្យតែយើងជួយស្រលាញ់ក្រុមហ៊ុនរបស់គេទេ ស្រួលគេធ្វើអ្វីតាមចិត្ត។

អ្នកដែលស្រលាញ់ក្រុមហ៊ុន នឹងធ្វើគ្រប់យ៉ាងដើម្បីក្រុមហ៊ុន ដោយមិនគិតពីខ្លួនឯង។ ខ្ញុំលើកឧទាហរណ៍ពីការចំណាយពេលវេលាក្នុងក្រុមហ៊ុនបន្តិច ដើម្បីងាយយល់ទាំងអស់។ អ្នកដែលស្រលាញ់ក្រុមហ៊ុន នឹងចំណាយពេលច្រើននៅក្នុងក្រុមហ៊ុន ព្រោះគេចង់ដឹងថា មានអ្វីកើតឡើងខ្លះ។ គេទុកក្រុមហ៊ុនជាផ្ទះរបស់គេ។ ការងាររបស់ពួកគេ ធ្វើមិនបានច្រើនប៉ុន្មានទេ ប៉ុន្តែចំណាយពេលច្រើនហួសហេតុដោយមិនបានអ្វីទាំងអស់។ ពួកគេគិតថា ការបង្ហាញមុខគ្រប់ពេលនៅក្នុងក្រុមហ៊ុនបញ្ជាក់ថា ពួកគេស្រលាញ់ការងារ តែតាមពិតពួកគេស្រលាញ់ក្រុមហ៊ុនប៉ុណ្ណោះ។

អ្នកដែលស្រលាញ់ក្រុមហ៊ុន អាចមានមូលហេតុរបស់គេ។ វាអាចមកពីគេគិតថាក្រុមហ៊ុននោះឡូយ ឬមានអ្នកដទៃចូលចិត្តគេច្រើននៅក្រុមហ៊ុនជាដើម។ ពេលប្អូនខ្ញុំ ទៅដាក់ពាក្យធ្វើការ ពេលមកវិញ ក៏ប្រាប់ខ្ញុំថា “ឯកសណ្ឋានក្រុមហ៊ុនគេស្អាតណាស់ ឃើញហើយចង់ទៅធ្វើការតែម្តង”។ នេះបញ្ជាក់ថា ប្អូនខ្ញុំស្រលាញ់ក្រុមហ៊ុនតាំងពីមិនទាន់ចូលធ្វើការទៅហើយ។

ការដាក់ចិត្តដាក់កាយជាមួយក្រុមហ៊ុនខ្លាំងពេក ក៏អាចបង្កជាបញ្ហាបានដែរ។ WWE ជាក្រុមហ៊ុនផ្សព្វផ្សាយកីឡាកាសដែលល្បីជាងគេ ក្នុងបច្ចុប្បន្ននេះ ហើយក៏ជាក្រុមហ៊ុនដែលមានរឿងអាស្រូវទាក់ទងនឹងកីឡាករច្រើនដែរ។ កីឡាករមួយចំនួនបានសម្រេចចិត្តប្រើ Steroid ដែលជាថ្នាំសម្រាប់ជំនួយសាច់ដុំ និងកម្លាំង ដើម្បីបំពេញចិត្តថៅកែ WWE។ ថ្នាំនេះ ធ្វើឱ្យអ្នកប្រើមានបញ្ហាសុខភាពទាំងផ្លូវកាយនិងផ្លូវអារម្មណ៍។

កីឡាករទាំងនេះ អាចទៅចាប់អាជីពនៅកន្លែងផ្សេងបាន ប៉ុន្តែពួកគេមិនទៅ ព្រោះស្រលាញ់ WWE។ WWE ជាក្រុមហ៊ុនធំ ហេតុនេះលុយដែលផ្តល់ឱ្យ ក៏មិនអន់ដែរ ហើយម្យ៉ាងទៀត បានចេញមុខតាមទូរទស្សន៍ទៀតផង។ ពួកគេមិនស្រលាញ់អ្វី

ដែលគេធ្វើទេ តែស្រលាញ់កន្លែងដែលគេធ្វើ។ កីឡាករផ្សេងទៀតដែលគេស្រលាញ់វិស័យនេះ គេទៅធ្វើការនៅក្រុមហ៊ុនណាក៏បានដែរ ព្រោះគេមិនខ្វល់ទេ។ អ្វីដែលគេខ្វល់ គឺបានធ្វើការងារដែលគេពេញចិត្ត។

ខ្ញុំមើលកីឡាកាសរាប់ឆ្នាំហើយ ហេតុនេះខ្ញុំអាចមើលដឹងខ្លះថា តើកីឡាករណាចេញមកសម្ដែងដោយចិត្តស្រលាញ់ ហើយអ្នកណាចេញមកដើម្បីតែលុយ? អ្នកគាំទ្រផ្សេងទៀត ក៏អាចមើលដឹងដូចគ្នាដែរ។

ខ្ញុំជាមនុស្សស្រលាញ់ការងារប៉ុណ្ណោះ ចំពោះក្រុមហ៊ុន ខ្ញុំគ្មានអ្វីត្រូវជាប់ចិត្តទេ។ ក្រុមហ៊ុនណា ក៏ខ្ញុំអាចទៅធ្វើបានដែរ ឱ្យតែគេមានអ្វីឱ្យខ្ញុំធ្វើ ហើយឱ្យលុយខ្ញុំសមល្មម។ ខ្ញុំមិនចេះប្រកាន់កន្លែងតូច ឬធំទេ សំខាន់លើការងារប៉ុណ្ណោះ។ ម៉ាក់ខ្ញុំ ក៏តែងតែប្រដៅខ្ញុំដែរពីរឿងការងារនេះ។ គាត់ថា កន្លែងណាក៏យើងធ្វើបានដែរ បើមួយមិនត្រូវ ទៅធ្វើនៅកន្លែងមួយទៀតទៅ។ គាត់មិនចេះប្រកាន់ថា ទាល់តែក្រុមហ៊ុនធំ ឬល្បីឈ្មោះ ទើបត្រូវចូលទៅធ្វើទេ។

ខ្ញុំមិនចេះស្រលាញ់ក្រុមហ៊ុនទេ ឬអាចថា ខ្ញុំមិនមែនជាកញ្ជះដាច់ថ្លៃដូចជូកឺលាងក្នុងរឿងសាមកុកក៏បានដែរ។ ខ្ញុំមិនដាក់ភាពស្មោះស្ម័គ្រទៅលើប្រយោជន៍របស់អ្នកណាទាំងអស់។ ខ្ញុំមានភាពស្មោះត្រង់ តែមិនមានភាពស្មោះស្ម័គ្រ។ ពេលណាខ្ញុំធុញ ឬគិតថា ក្រុមហ៊ុនធ្វើមិនល្អដាក់ខ្ញុំ ខ្ញុំនឹងដើរចេញ។ ទាល់តែមិនចេះស្រលាញ់ក្រុមហ៊ុន ទើបយើងមើលឃើញជម្រើសការងារច្រើន។

# ភាពស្មោះត្រង់ សម្រាប់ខ្ញុំគេ

មនុស្សត្រូវតែមានភាពស្មោះត្រង់ក្នុងខ្លួន ទើបយើងមិនអន់ជាងឆ្កែ។ ភាពស្មោះត្រង់ធ្វើឱ្យគេគោរពយើងនៅកន្លែងការងារ។ មិនមែនគ្រប់គ្នាទេ តែមនុស្សស្មោះត្រង់ គេនឹងគោរពយើង។ យើងមិនបាច់ចង់ឱ្យមនុស្សមិនស្មោះត្រង់មកគោរពយើងទេ។

ខ្ញុំមានសំណួរមួយ តើខ្ញុំគេ ត្រូវស្មោះត្រង់ដូចម្ដេចខ្លះ? **ភាពស្មោះត្រង់ដំបូងគេបង្អស់ គឺមិនលួចរបស់ក្រុមហ៊ុន។** អ្វីក៏ដោយឱ្យតែជាកម្មសិទ្ធិរបស់ក្រុមហ៊ុន គឺយើងមិនត្រូវប៉ះពាល់ជាដាច់ខាត។ មិនមែនតែសម្ភារៈធ្វើការ ឬលុយកាក់ទេ សូម្បីតែ

ទិន្នន័យ ក៏យើងមិនត្រូវយកចេញដែរ។ ត្រូវចាំផង យើងមកធ្វើការ មិនមែនមកធ្វើចោរទេ។ យើងត្រូវចេះបែងចែកខុស និងត្រូវ។ ការលួចរបស់គេ នឹងធ្វើឱ្យយើងបាក់មុខ ហើយត្រូវគេនិយាយដើមប៉ុណ្ណោះ។

ចំពោះសម្ភារៈ គេមិនសូវភ័យទេ ព្រោះតាមក្រុមហ៊ុនធំៗ តែងតែមានបង្កប់កាម៉េរ៉ាដើម្បីតាមដាន ប៉ុន្តែទិន្នន័យ ទើបពិបាកគ្រប់គ្រង។ បើបុគ្គលិក គ្រាន់តែនិយាយពីកិច្ចការធម្មតាជាមួយអ្នកដទៃ វាមិនមែនបញ្ហា តែបើជារឿងសម្ងាត់ ឬជាផែនការវិញ ក្រុមហ៊ុនអាចនឹងជួបបញ្ហាមិនខាន។ ភាពស្មោះត្រង់ បញ្ជាក់ថា យើងជាមនុស្សដែលគេអាចទុកចិត្តបាន មិនមែនជាមនុស្សដែលគេភ័យគ្រប់ពេលដែលហើបមាត់នោះទេ។

ក្រុមហ៊ុនដែលខ្ញុំធ្វើការ មានរឿងសម្ងាត់ច្រើនណាស់។ មានតែបុគ្គលិកប៉ុណ្ណោះដែលដឹង ហេតុនេះទោះបីខ្ញុំចូលចិត្តសរសេរហែកកេរ្តិ៍ពីគេប៉ុណ្ណា ក៏ខ្ញុំមិនល្មើសនឹងរឿងនេះដែរ។ ខ្ញុំគោរពគេ ព្រោះគេប្រាប់ខ្ញុំហើយថា វាជារឿងសម្ងាត់សម្រាប់ផ្ទៃក្នុង។

ខ្ញុំធ្លាប់លឺជាងកុំព្យូទ័រ និយាយគ្នាពីលួចរបស់របរក្នុងហាងយកទៅលក់។ រាល់ពេលដែលថៅកែភ្លេចខ្លួន គេតែងតែបន្លំលួចយក RAM ឬ Hard Disk ទៅលក់យកលុយផឹកជានិច្ច។ បុគ្គលិកបែបនេះ បើទុកកាន់តែយូរ កាន់តែជួយឱ្យក្រុមហ៊ុនបិទទ្វារកាន់តែឆាប់។ យើងមិនស្រលាញ់ក្រុមហ៊ុនគេមែន តែយើងក៏មិនទៅបំផ្លាញរបស់គេដែរ។ មិនស្រលាញ់ និងបំផ្លាញ មិនមែនជារឿងដូចគ្នាទេ។

**ភាពស្មោះត្រង់ទីពីរ គឺការនិយាយត្រង់**។ បើបុគ្គលិកមិនហ៊ានលើកឡើងពីបញ្ហាក្នុងក្រុមហ៊ុន ដោយការខ្លាច បញ្ហាក្នុងក្រុមហ៊ុន នឹងកាន់តែយ៉ាប់ឡើង។ ក្រុមហ៊ុនមានបញ្ហា យើងជាអ្នកធ្វើការក្នុងនោះ ក៏ជួបបញ្ហាដូចគ្នា។

មកដល់ត្រង់នេះ ខ្ញុំនឹងឃើញឈុតមួយក្នុងរឿងសាមកុកដែល លីយានព្យាយាមផ្គាប់ចិត្តលីវប៉ី ដោយឱ្យយោបល់ចេញធ្វើសង្គ្រាមនឹងតុងអ៊្វ។ លីយាន គិតថា ខ្លួនជាមន្ត្រីចុះចូល ដូច្នេះមិនគួរនិយាយអ្វីប្រឆាំងនឹងលីវប៉ីទេ។ លីវយាន ថែមទាំងប្រដៅកូនខ្លួនឯង ឱ្យធ្វើតាមចិត្តលីវប៉ី ជាពិសេសត្រូវធ្វើផ្ទុយពី ជូកឺលាង។ លីយានគិតថា ខ្លួននិងជូកឺលាងមិនដូចគ្នាទេ ហេតុនេះទើបមិនអាចនិយាយការពិតបាន។

លីយាន មិនមែនមិនដឹងថា ការចេញវាយតុងអ៊ូ ជារឿងមិនល្អ និងមិនសមពេលនោះទេ តែគាត់នៅតែគាំទ្រលីវប៊ុដដែល ព្រោះខ្លាចលីវប៊ីមិនពេញចិត្ត។ ការខ្លាចនេះ នាំមកនូវបរាជ័យក្នុងសង្គ្រាម។

មនុស្សដូចលីយាន មានច្រើនណាស់នៅក្នុងក្រុមហ៊ុន។ ពួកគេខ្លាចថៅកែមិនពេញចិត្ត ដូច្នេះមិនហ៊ាននិយាយត្រង់ទេ។ យើងមិនអាចនិយាយថា ខ្លួនយើងជាមនុស្សស្មោះត្រង់បានទេ បើយើងមិនធ្វើឱ្យដូចមាត់យើង។ ភាពស្មោះត្រង់របស់បុគ្គលិក គឺជាកត្តាមួយដែលនាំឱ្យក្រុមហ៊ុនជោគជ័យ។

ក្រុមហ៊ុនចាស់ដែលខ្ញុំធ្វើការពីមុន ជាកន្លែងដែលបង្ហាញខ្ញុំឱ្យមើលឃើញថា បើគ្មានភាពស្មោះត្រង់ក្នុងក្រុមហ៊ុន ភាពរីកចម្រើនក៏គ្មានដូចគ្នា។ ប្រធានក្រុមហ៊ុន ជាមនុស្សចូលចិត្តការអែបអប តែគាត់ក៏ត្រូវការមនុស្សដែលនិយាយត្រង់ដែរ។ ពេលមានរឿងសំខាន់ណាមួយ គាត់តែងតែយកមកពិភាក្សាជាមួយបុគ្គលិកសំខាន់ៗ ដើម្បីរកផ្លូវដើរ។

ខ្ញុំក៏នៅក្នុងនោះដែរ ហើយខ្ញុំតែងតែជំទាស់ជានិច្ច បើអ្វីដែលគាត់លើកឡើងមិនសូវសម។ ខ្ញុំនិយាយតាមអ្វីដែលខ្ញុំគិតឃើញប៉ុណ្ណោះ ព្រោះខ្ញុំមិនខ្លាចចិត្តគាត់ទេ។ ខ្ញុំធ្វើការយកប្រាក់ខែតិច ដូច្នេះខ្ញុំមិនខ្លាចគេដេញចោល ឬកាត់លុយទេ។ ខ្ញុំធ្វើឱ្យមេជំទាស់ចិត្តច្រើនលើកណាស់ ព្រោះពេលគាត់ប្រាប់ខ្ញុំពីគំនិតរបស់គាត់ ខ្ញុំចូលចិត្តជំទាស់។ ខ្ញុំធ្វើបែបនេះ ពេលខ្លះដើម្បីដុតគាត់លេង តែភាគច្រើន គឺដើម្បីជួយឱ្យគំនិតរបស់គាត់កាន់តែល្អជាងមុន។ ខ្ញុំនិយាយតាមអ្វីដែលខ្ញុំចេះ។ អ្វីដែលមិនចេះខ្ញុំនៅស្ងៀម ហើយប្រាប់គាត់ថា"គ្មានយោបល់ក្នុងរឿងនេះទេ" ដើម្បីឱ្យគាត់ដើរសួរគេផ្សេង។

អ្នកដែលមិនស្មោះត្រង់វិញ ពេលលឺខ្ញុំនិយាយផ្សេងពីមេជំ ពួកគេតែងតែនិយាយកាន់ជើងមេរហូត។ ពួកគេធ្វើបែបនេះដើម្បីផ្គាប់ចិត្តមេប៉ុណ្ណោះ តែអ្វីដែលខ្ញុំធ្វើ គឺដើម្បីលទ្ធផល។ ខ្ញុំគិតថា គាត់ធ្វើមេខ្ញុំបាន គាត់ក៏គួរតែចេះលើកជើងខ្លួនឯងដែរហើយ មិនបាច់ខ្ញុំទៅលើកឱ្យហត់ទៀតទេ។ មេល្អ ចេះលើកជើងខ្លួនឯង ដើម្បីទុកពេលឱ្យបុគ្គលិកមានពេលធ្វើការ។

**ភាពស្មោះត្រង់ចុងក្រោយ គឺធ្វើការឱ្យអស់ពីសមត្ថភាព។** យើងចេះប៉ុណ្ណា យើងបញ្ចេញឱ្យអស់ក្នុងការងារ។ កុំកេងចំណេញលើក្រុមហ៊ុនដែលឱ្យលុយយើង។ ពេលយើងទៅទំនិញនៅហាង បើសិនជាម្ចាស់ហាងកេងរបស់យើង ក៏យើងមិនសុខចិត្តដូចគ្នា ដូច្នេះកុំធ្វើអ្វីដែលយើងមិនចង់បាន។ គេជួលយើងមកធ្វើការ គេឱ្យលុយយើងពេញថ្លៃ ដូច្នេះត្រូវធ្វើការឱ្យគេពេញដៃជើងវិញ ទើបស្មើគ្នា។

ការងារណាដែលខ្ញុំគិតថា អាចមានវិធីធ្វើឱ្យល្អជាងនេះបាន ខ្ញុំយកមកធ្វើឡើងវិញជានិច្ច។ មិនមែនឱ្យខាតពេលទេ គឺដើម្បីឱ្យវាល្អជាងមុន។ តើយើងធ្លាប់ឆ្ងល់ទេថា ហេតុអីបានជាក្រុមហ៊ុនតិចណូឡូជី តែងតែសួរយោបល់អ្នកប្រើគ្រប់ពេល? ពួកគេចង់ដឹងថាយើងប្រើរបស់គេយ៉ាងម៉េចខ្លះ ដើម្បីគេយកទៅកែឡើងវិញ។ គេធ្វើរួចមែន តែគេចង់បានល្អជាងនេះទៀត។

ចំណុចសំខាន់ គឺស្ថិតនៅលើពាក្យថា "អស់ពីសមត្ថភាព"។ តើយើងអាចធ្វើការឱ្យអស់ពីសមត្ថភាពដែរទេ បើសមត្ថភាពយើងចេះតែកើនឡើងរហូតនោះ? ចម្លើយ គឺមិនអាចទេ។ យើងកាន់តែប្រឹងធ្វើ សមត្ថភាពយើងកាន់តែរីកចម្រើន ហើយស្នាដៃយើងកាន់តែល្អជាងមុន។ ទោះបីមិនអស់ ក៏យើងត្រូវប្រឹងធ្វើឱ្យដល់កម្រិតដែរ។

យើងគ្រាន់តែមិនលួចរបស់ក្រុមហ៊ុន និយាយឱ្យត្រង់ និងធ្វើការឱ្យដល់សមត្ថភាពយើង គឺគ្រប់គ្រាន់ពេកទៅហើយសម្រាប់បុគ្គលិក។ ភាពស្មោះត្រង់នេះនឹងកាត់ផ្ដាច់នៅពេលយើងដើរចេញពីក្រុមហ៊ុន។ ការងារ ជាផ្នែកមួយនៃជីវិត។ ពេលណាយើងប្ដូរការងារ បានន័យថា ផ្នែកដែលយើងប្ដូរចេញនោះបានកន្លងផុតទៅហើយ។ បើយើងស្មោះស្ម័គ្រនឹងក្រុមហ៊ុនណាមួយ យើងនឹងខាតចិត្តរបស់យើងនៅថ្ងៃណាមួយមិនខាន។

# ក្រុមហ៊ុនប្រើយើងដើម្បីប្រយោជន៍

ខ្ញុំជឿថា អ្នកណាក៏ដឹងពីចំណុចនេះដែរ។ ក្រុមហ៊ុន ត្រូវការតែបុគ្គលិកណាដែលអាចនាំប្រយោជន៍ចូលក្នុងក្រុមហ៊ុនប៉ុណ្ណោះ។ គេនឹងយកចិត្តទុកដាក់ លើកតម្កើងយើង ពេលដែលគេមើលឃើញ ប្រយោជន៍របស់យើង។ បើយើងជាមនុស្សគ្មាន

ប្រយោជន៍ ឬមិនត្រូវនឹងអ្វីដែលគេត្រូវការ គេនឹងទាត់យើងចោលភ្លាម។ ជំនួញ គឺបង្កើតឡើងដើម្បីប្រយោជន៍។

បើយើងជាខ្ញុំគេ យើងត្រូវចាំចំណុចនេះ។ ក្រុមហ៊ុនចង់បានប្រយោជន៍ពីយើង យើងក៏ត្រូវទាញយកប្រយោជន៍ពីក្រុមហ៊ុនមកវិញដែរ។ យើងអាចយកក្រុមហ៊ុនជាកន្លែងអនុវត្តអ្វីដែលយើងបានរៀន ឬសន្សំលុយក៏បានដែរ។ គេយកប្រយោជន៍ពីយើងបាន យើងក៏អាចយកប្រយោជន៍ពីគេបានដូចគ្នា។ មានតែធ្វើបែបនេះទេ ទើបថៅកែ និងខ្ញុំគេ មានភាពស្មើគ្នាខ្លះ។

ខ្ញុំទុកក្រុមហ៊ុនជាកន្លែងបង្កើតរឿងឱ្យខ្ញុំសរសេរក្នុងសៀវភៅ។ ខ្ញុំសម្រេចថា ធ្វើជាអ្នកនិពន្ធសៀវភៅទៅហើយ ហេតុនេះខ្ញុំត្រូវតែប្រឹងរកអ្វីមកសរសេរដោយខ្លួនឯង។ ខ្ញុំមិនចង់ធ្វើដូចរោងពុម្ពខ្លះដែលអង្គុយចាំតែយកអ្វីដែលគេសរសេរហើយ មកបកប្រែ រួចថែមន័យបន្តិចបន្តួចទេ។ តើមានអ្វីស្រួលជាងការទៅធ្វើការ ហើយស្វែងយល់ពីមនុស្សនៅក្នុងក្រុមហ៊ុននោះ? បានលុយហើយ បានអ្វីមកសរសេរទៀត។

ពេលដែលខ្ញុំមើលឃើញថា ក្រុមហ៊ុននេះលែងមានអ្វីថ្មីដែលខ្ញុំអាចយកមកសរសេរបានទៀត ខ្ញុំនឹងទៅធ្វើការនៅក្រុមហ៊ុនផ្សេង ដើម្បីបន្តការសរសេរសៀវភៅរបស់ខ្ញុំ។ ប្រធានផ្នែករបស់ខ្ញុំ បាននិយាយប្រាប់អ្នកដទៃថា “ខ្ញុំមកធ្វើការនៅក្រុមហ៊ុននេះ ជាការងារក្រៅម៉ោងប៉ុណ្ណោះ ការងារពេញម៉ោងរបស់ខ្ញុំ គឺសរសេរសៀវភៅ”។ គ្រប់គ្នាស្តាប់ហើយ នាំគ្នាសើចព្រោះគិតថា គាត់និយាយលេង។ ពួកគេមិនដឹងថា ប្រធានផ្នែករបស់ខ្ញុំ ស្គាល់ខ្ញុំច្រើនជាងពួកគេនោះទេ។

ខ្ញុំមិនប្រកាន់នឹងក្រុមហ៊ុនយកប្រយោជន៍ពីខ្ញុំទេ ព្រោះខ្ញុំខ្លួនឯង ក៏យកប្រយោជន៍ពីក្រុមហ៊ុនដូចគ្នា។ ប្រយោជន៍ទាល់តែមានទៅមានមកបែបនេះ ទើបចុះសម្រុងគ្នា។ លុយតែមួយមុខ មិនគ្រប់គ្រាន់សម្រាប់ខ្ញុំទេ។ ការយករឿងអ្នកដទៃមកសរសេរ ទើបជាប្រយោជន៍ដែលអាចនាំប្រយោជន៍បន្តទៀតឱ្យខ្ញុំបាន។

មានបុគ្គលិកផ្សេងទៀតដែលធ្វើការនៅទីនោះដែរ មកធ្វើការដើម្បីរៀនពីរបៀបបើកក្រុមហ៊ុនអាយធីប៉ុណ្ណោះ។ ពេលដែលពួកគេចេះដឹងល្មមហើយ ពួកគេក៏សាកល្បងបើក ហើយយកប្រាក់ខែរបស់ខ្លួនឯង ធ្វើជាដើមទុន។ នៅពេលក្រុមហ៊ុនរបស់គេ

មានអតិថិជនល្អមនឹងអាចឈរជើងបាន គេក៏មកដាក់ពាក្យឈប់ដើម្បីផ្ដោតលើជំនួញរបស់ខ្លួនឯងម្ដង។ គេយកក្រុមហ៊ុនជាប្រយោជន៍សម្រាប់អនាគតរបស់គេ។

ក្រុមហ៊ុន ជាមុខជំនួញ ដូច្នេះយើងដែលចូលទៅប្រឡូកក្នុងនោះ ត្រូវគិតថាវាជាមុខជំនួញ។ កុំទុកវាជាគ្រួសារ ឬជាមិត្តភក្តិរបស់យើង។ បើជាមុខជំនួញ ត្រូវតែមានប្រយោជន៍ទាំងសងខាង។ បើយើងមើលឃើញតែលុយមួយមុខ យើងគ្រាន់តែជាខ្ញុំគេដែលហួសសម័យប៉ុណ្ណោះ។ បើយើងមើលឃើញ ប្រយោជន៍ច្រើនជាងនេះ ទើបយើងអាចរស់នៅដោយសេរីភាពបាន។

ខ្ញុំគេហួសសម័យខ្លះគិតថា ការដើរចេញពីក្រុមហ៊ុន ជាការក្បត់ក្រុមហ៊ុនទៀតផង។ តើយើងអាចក្បត់ក្រុមហ៊ុនម៉េចនឹងកើត បើក្រុមហ៊ុន និងយើងគ្មានទំនាក់ទំនងអ្វីផងហ្នឹង? តើយើងទៅមានទំនាក់ទំនងជាមួយគេតាមណា បើយើងគ្រាន់តែជាខ្ញុំគេហ្នឹង? យើងត្រូវរៀនគិតបែបនេះ ទើបការងារយើងមានភាពរីកចម្រើន។ យើងមើលឃើញភាពរីកចម្រើន នៅពេលយើងមានសេរីភាពគ្រប់គ្រាន់។

# ក្រុមហ៊ុន មិនមែនជាគ្រួសាររបស់យើងទេ

ក្រុមហ៊ុនណា ក៏តែងតែមានទម្លាប់និយាយថា ទីនេះជាគ្រួសារ ឬជាផ្ទះរបស់បុគ្គលិកដែរ។ ក្រុមហ៊ុនដែលខ្ញុំធ្លាប់ធ្វើការ ក៏គេនិយាយដូចគ្នា តែខ្ញុំមិនជឿទេ។ ឥលូវសាកគិតទៅមើល តើគ្រួសារណាដែលអាចយកចំណេញ ចាក់រុក ប្រកួតប្រជែងគ្នាបែបនេះ? តើគ្រួសារណា ដែលដាច់ចិត្តបណ្ដេញសមាជិកចេញនៅពេលដែលធ្វើអ្វីមួយខុស? តើគ្រួសារណា ដែលទុកសមាជិករបស់ខ្លួន ជាខ្ញុំគេ?

អ្នកដែលទុកក្រុមហ៊ុនជាគ្រួសារ ជាអ្នកដែលចាញ់បោកមនោគមន៍របស់ក្រុមហ៊ុន។ ពួកគេប្រឹងធ្វើការ ដោយចំណាយពេលស្ទើរពេញមួយថ្ងៃ នៅក្នុងក្រុមហ៊ុន ហើយភ្លេចគ្រួសាររបស់គេដែលនៅផ្ទះ។ ពួកគេគ្មានពេលសម្រាប់គ្រួសារពិតប្រាកដទេ ព្រោះជាប់រវល់នឹងគ្រួសារក្លែងក្លាយ។ ដល់ពេលចុងក្រោយ ពួកគេនឹងត្រូវគេបណ្ដេញចេញ ឬដើរចេញដោយខ្លួនឯង ហើយពួកគេនឹងស្ដាយក្រោយ ព្រោះមិនបានចំណាយពេលគ្រប់គ្រាន់ជាមួយអ្នកផ្ទះរបស់ខ្លួន។

ខ្ញុំមានគ្រួសាររួចហើយ ហេតុនេះ ខ្ញុំមិនត្រូវការគ្រួសារណាទៀតទេ។ ខ្ញុំទៅធ្វើការដើម្បីប្រយោជន៍របស់ខ្ញុំប៉ុណ្ណោះ ហើយខ្ញុំជឿថា ប្រយោជន៍ទាំងនោះ នឹងអាចជួយសម្រួលការលំបាករបស់គ្រួសារខ្ញុំបាន។ ខ្ញុំត្រូវរកវិធីកាត់បន្ថយពេលធ្វើការ ដើម្បីមានពេលនៅផ្ទះ។ ចំពោះរឿងពេលវេលា យើងមិនអាចកំណត់បានទេ ព្រោះយើងយកលុយពីគេពេញថ្លៃ។ គេទិញទាំងជំនាញ និងពេលវេលារបស់យើង តែយើងអាចកំណត់ពេលក្រៅពីនោះបាន ដោយមិនឱ្យការងារមកពាក់ព័ន្ធនៅផ្ទះ។

អ្នកនិពន្ធ James Altucher បាននិយាយថា "ដល់ពេលដែលយើងស្លាប់ទៅ គ្មានអ្នកណាខ្វល់ពីពេលវេលាដែលយើងចំណាយនៅក្នុងក្រុមហ៊ុននោះទេ"។ អ្នកដែលចំណាយពេលច្រើនពេកទៅលើការងារ ហើយទុកក្រុមហ៊ុនជាគ្រួសារ នឹងស្ដាយក្រោយនៅដង្ហើមចុងក្រោយ។ ក្រុមហ៊ុនមិនខ្វល់ថាយើងស្លាប់ទេ។ ពួកគេគ្រាន់តែបាត់បង់បុគ្គលិកម្នាក់ប៉ុណ្ណោះ ហើយគេអាចរកមនុស្សមកជំនួសយើងបានគ្រប់ពេល។ គ្រួសាររបស់យើង ទើបពិបាក។ គ្មានអ្នកណាមកជំនួសកន្លែងយើងទេ។

កុំស្រលាញ់ក្រុមហ៊ុនជាងគ្រួសារ កុំទុកក្រុមហ៊ុនជាគ្រួសារ និងកុំលះបង់ដើម្បីក្រុមហ៊ុនច្រើនជាងគ្រួសារ។ ក្រុមហ៊ុន គឺជាកន្លែងដែលយើងទៅធ្វើការដើម្បីចិញ្ចឹមគ្រួសារប៉ុណ្ណោះ។ យើងអាចប្ដូរក្រុមហ៊ុនប៉ុន្មានដងក៏បានដែរ តែយើងមិនអាចប្ដូរគ្រួសារយើងបានទេ។

ប៉ាខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ទុកក្រុមហ៊ុនជាគ្រួសារ។ ពួកគេរីករាយនៅពេលទៅធ្វើការ ហើយត្រលប់មកវិញដោយចងចិញ្ចើមដាក់អ្នកផ្ទះ។ ប៉ាខ្ញុំធ្វើការគ្មានថ្ងៃឈប់ទេ ហើយបើគេត្រូវការបុគ្គលិកឱ្យធ្វើការថែមម៉ោង គាត់នឹងធ្វើទៀត។ ខ្ញុំមិនឯកភាពនិងមិនសរសើរអ្នកដែលលះបង់ជ្រុលបែបនេះដែរ។ ខ្ញុំគេ ធ្វើឱ្យត្រូវក្បួនខ្នាតជាខ្ញុំគេ កុំតាំងខ្លួនជាសហគ្រិនក្នុងក្រុមហ៊ុនរបស់គេ។

# ៦

# សេរីភាពនៅកន្លែងការងារ

កន្លែងធ្វើការ ជាកន្លែងដែលឃុំឃាំងយើងក្នុងរយៈពេលប៉ុន្មានម៉ោង ដើម្បីបំពេញការងារឱ្យរួច។ កន្លែងនេះ អាចក្លាយជាគុកសម្រាប់មនុស្សមួយចំនួនដែលចូលចិត្តសេរីភាព។ យើងអាចនឹងឆ្ងល់ថា តើអ្នកណាមិនចង់បានសេរីភាព? តែបើឆ្ងល់បែបនេះ បានន័យថាយើងមិនធ្លាប់ស្វែងយល់ពីមនុស្សជុំវិញខ្លួនទេ។ មិនមែនគ្រប់គ្នាសុទ្ធតែចង់បានសេរីភាពនោះទេ។ ពួកគេអាចនិយាយតាមគ្នាថា “ចង់បាន” តែក្នុងចិត្តមិនដែលគិតពីសេរីភាពផ្ទាល់ខ្លួនឡើយ។ មនុស្សបែបនេះសមនឹងអត់សេរីភាពណាស់។

ក្រុមហ៊ុន មិនចង់ឱ្យបុគ្គលិកមានសេរីភាពច្រើនពេកទេ ព្រោះពិបាកគ្រប់គ្រង។ គេចង់បានបុគ្គលិកដែលមិនចូលចិត្តសេរីភាព ហើយចូលចិត្តធ្វើតាមច្បាប់ទម្លាប់ដែលគេដាក់ឱ្យ។ និយាយឱ្យចំ ថៅកែក្រុមហ៊ុន ស្រលាញ់ចៀមដែលចេះធ្វើការ។ ចៀមចង់តែរស់ប៉ុណ្ណោះ ដូច្នេះស្រួលចាត់ការណាស់។ ឱ្យវាស៊ីល្មមតែអាចរស់បាន ហើយបង្កើតរូបភាពបន្លំភ្នែកឱ្យពួកវាគិតថាមានសេរីភាពទៅ គឺគ្រប់គ្រាន់នឹងធ្វើឱ្យចៀមសប្បាយចិត្តហើយ។

សៀវភៅនេះ មិនមែនសម្រាប់ចៀមអានទេ ដូច្នេះខ្ញុំជឿថា អ្នកដែលកំពុងអាន ក៏មិនមែនជាចៀមដែរ។ ការធ្វើជាខ្ញុំគេ មិនអាក្រក់នោះទេ តែការធ្វើជាចៀមទើប

អាក្រក់ ហើយភ្លើទៀតផង។ មនុស្ស និងចៀម ខុសគ្នាត្រង់ការគិតពីសេរីភាព។ មនុស្សចេះចង់បាន ហើយចេះរកវិធីបង្កើតសេរីភាព។ ចៀមចង់បានសេរីភាព ដែលគេកំណត់ឱ្យប៉ុណ្ណោះ។ បើគេកំណត់ឱ្យដដែល គេមិនហៅថា សេរីភាពទេ។

## សេរីភាពក្នុងការការងារ

នៅពេលយើងមានការងារធ្វើ យើងក៏បាត់បង់សេរីភាពរបស់យើងប៉ុន្មានម៉ោងដែរ។ ពេញមួយថ្ងៃ ខ្ញុំចំណាយពេលដល់ល្ងាច សម្រាប់ការងារក្រុមហ៊ុន។ ខ្ញុំមិនអាចចេញទៅណាបានទាំងអស់ ព្រោះខ្ញុំត្រូវធ្វើការ។ ខ្ញុំបាត់សេរីភាព ព្រោះចង់បានលុយពីគេ។ បើខ្ញុំឈប់ធ្វើការ ខ្ញុំនឹងបាត់លុយ ហេតុនេះ ខ្ញុំគ្មានផ្លូវផ្សេងទេ។

ក្រៅពីសេរីភាពនេះ នៅមានសេរីភាពក្នុងការងារមួយទៀត ដែលខ្ញុំត្រូវការពារកុំឱ្យបាត់បង់។ ខ្ញុំត្រូវធ្វើការដោយមានសេរីភាព ព្រោះខ្ញុំបានបាត់សេរីភាពខាងក្រៅរួចទៅហើយ។

សេរីភាពក្នុងការងារ មានច្រើនណាស់ ដូចជាៈ ការបញ្ចេញមតិ ការប្រឆាំងមតិ ការបដិសេធមិនចូលរួម ការសម្រេចចិត្ត ការធ្វើការងារផ្ទាល់ខ្លួន និងការដើរចេញ។ ខ្ញុំនឹងលើកពីចំណុចមួយចំនួនមកបង្ហាញ។ បើយើងគ្មានសេរីភាពទាំងនេះទេ យើងធ្វើការក៏មិនពេញចិត្តដែរ។

មិនមែនក្រុមហ៊ុនបើកដៃឱ្យយើងមានសេរីភាពទាំងអស់នេះទេ ទាល់តែយើងខ្លួនឯងហ៊ានធ្វើដោយមិនខ្លាចគេដេញចោល ទើបអាចទទួលបាន។ សេរីភាពជារបស់ល្អអ្នកមិនបាន ព្រោះមិនហ៊ានសាក។ ពេលយើងសាកបានហើយ អ្នកផ្សេងទៀតនឹងឆ្ងល់ថាហេតុអីយើងមានសេរីភាពច្រើនជាងពួកគេ ប៉ុន្តែពួកគេមិនធ្វើអ្វីទាំងអស់។ ពួកគេចូលចិត្តឆ្ងល់ តែដល់ពេលរកចម្លើយមិនបាន ក៏ងាកមកច្រណែនវិញ។

## ការប្រឆាំងមតិ

មនុស្សពីរនាក់ មិនអាចមានគំនិតស្របគ្នាទេ ដូច្នេះការប្រឆាំងមតិគ្នា តែងតែកើតមាននៅតាមកន្លែងធ្វើការ។ បើយើងមិនអាចប្រឆាំងមតិរបស់អ្នកដទៃបាន

យើងក៏គ្មានសេរីភាពក្នុងការងារដែរ។ យើងមានយោបល់ យើងត្រូវតែលើកឡើងឱ្យសមពេលវេលា ហើយពេលខ្លះអ្វីដែលយើងលើកឡើង អាចផ្ទុយពីមតិអ្នកដទៃ យើងក៏ត្រូវប្រឆាំងវិញដែរ។

ការប្រឆាំងមតិក្នុងការងារ មិនដូចគ្នានឹងការប្រឆាំងក្នុងផ្នែកនយោបាយទេ។ ភាពខុសគ្នា គឺវាធ្វើឡើងដើម្បីការរីកចម្រើនរួម។ បុគ្គលិកទាំងអស់ គួរតែជួយឱ្យក្រុមហ៊ុនរីកចម្រើន ដើម្បីខ្លួនឯងបានរីកចម្រើនដែរ។ ការធ្វើការក្នុងក្រុមហ៊ុនដែលដើរទៅមុខមិនរួច មិនខុសពីយើងស្លាក់ឆ្អឹងត្រីជាប់កទេ ចូលក៏ពិបាក ចេញក៏ពិបាក។

ខ្ញុំប្រឆាំងមតិអ្នកដទៃច្រើនណាស់ នៅកន្លែងធ្វើការ។ ពេលខ្លះអ្វីដែលគេលើកឡើង វាត្រូវតែមួយជ្រុង តែបែរជាបង្កើតបញ្ហាផ្សេងទៀត ដូច្នេះក្នុងនាមខ្ញុំជាអ្នកស៊ីលុយក្រុមហ៊ុនដែរ ខ្ញុំត្រូវតែជំទាស់ ហើយលើកយោបល់ផ្សេង។

នៅក្នុងការប្រឆាំងមតិ យើងមិនអាចនិយាយថា “ខ្ញុំមិនចូលចិត្ត” ដោយមិនពន្យល់ហេតុផលបានទេ។ ចំណុចសំខាន់ មិនស្ថិតលើចូលចិត្ត ឬមិនចូលចិត្តទេ វាស្ថិតលើត្រូវ ឬខុស។ បើអ្វីដែលយើងចូលចិត្ត ជារឿងមិនត្រូវ ការប្រឆាំងរបស់យើង ប្រៀបបាននឹងក្មេងឈ្លោះគ្នាលេងប៉ុណ្ណោះ។

សម្រាប់ឧទាហរណ៍ទាក់ទងនឹងការប្រឆាំងមតិ ខ្ញុំនឹងលើកខ្លះមកបង្ហាញដើម្បីចែកគ្នាធ្វើ។ នៅក្នុងបន្ទប់ធ្វើការរបស់ខ្ញុំ គេប្រើអំពូលភ្លើងពណ៌លឿង ដោយគេគិតថា វាមិនសូវចាំងភ្នែក ហើយមានពណ៌ស្រដៀងនឹងពន្លឺព្រះអាទិត្យ។ ខ្ញុំចូលធ្វើការបានតែមួយថ្ងៃ ចាប់ផ្តើមងងុយដេក ដោយសារតែពន្លឺភ្លើងនេះ។ អ្នកផ្សេងក៏គេងងុយដេកដែរ តែគេមិននិយាយអី ព្រោះគេជឿថា ក្រុមហ៊ុនមិនរើសអំពូលភ្លើងខុសទេ។ ពេលពួកគេងងុយដេក គេសុខចិត្តឆុងកាហ្វេផឹក។

តាមពិត ក្នុងបន្ទប់ធ្វើការបែបនេះ គេត្រូវការភ្លើងពណ៌ស ដើម្បីដាស់អ្នកធ្វើការកុំឱ្យងងុយដេក។ អំពូលភ្លើងពណ៌លឿង គេទុកដាក់តាមផ្ទះបាយ ឬបន្ទប់ប្រជុំប៉ុណ្ណោះ ព្រោះភ្លើងលឿង ជាភ្លើងស្រទន់ លួងលោមអារម្មណ៍មនុស្ស។ ការជ្រើសរើសភ្លើងបែបនេះ ជារឿងងាយស្រួលទេ ព្រោះតាមវេបសាយរបស់ក្រុមហ៊ុនផលិតអំពូលភ្លើងមានសរសេរច្រើនណាស់។

ខ្ញុំនិយាយរឿងភ្លើងនេះជាមួយគេ តែគេនៅតែប្រកាន់ជំនឿរបស់គេដដែល។ បើខ្ញុំផ្ញើអត្ថបទក្នុងវេបសាយឱ្យគេ វាដូចជាផ្ទាញ់ផ្ទាលគ្នាពេក ព្រោះសុទ្ធតែជាអ្នកស្គាល់គ្នា ហើយអ្នកដែលប្ដូរអំពូលភ្លើងនោះ គឺជាមិត្តភក្ដិជិតដិតរបស់ខ្ញុំទៀត។ ខ្ញុំក៏មិនអាចធ្វើអ្វីបានដែរ។ ត្រង់នេះបង្ហាញថា ខ្ញុំអាចប្រឆាំងមតិគេបាន តែគេមិនធ្វើតាមខ្ញុំទេ ហើយសេរីភាពរបស់ខ្ញុំក៏មិនទាន់ពេញលេញដែរ។ ត្រូវចាំ បុគ្គលិកថ្មី មិនដែលមានសេរីភាពភ្លាមទេ។ ខ្ញុំមានតែត្រូវចាំបន្តិចសិន ទម្រាំតែខ្ញុំអាចមានសិទ្ធិនិយាយខ្លះ។

ការងាររបស់ខ្ញុំ គឺធ្វើមេរៀនសម្រាប់អ្នកកាន់សាសនាគ្រីស្ទ ដែលមានភារកិច្ចចុះទៅតាមប្រទេសនានាដើម្បីផ្សព្វផ្សាយពីព្រះរបស់គេ។ មេរៀនទាំងអស់ សុទ្ធតែមានសិទ្ធិផលិតពីម្ចាស់មេរៀនហើយអ្វីដែលខ្ញុំត្រូវធ្វើ គឺយកមេរៀនដែលមានស្រាប់នោះមកបង្កើតជាមេរៀនបែប Interactive E-Learning។

ពេលខ្ញុំចូលធ្វើការភ្លាម គេបានឱ្យខ្ញុំអង្គុយមើលមេរៀនចាស់ៗដែលគេធ្វើប៉ុន្មានឆ្នាំមុន ហើយយកទៅប្រៀបនឹងមេរៀនថ្មីៗ។ គេចង់ដឹងយោបល់របស់ខ្ញុំអំពីមេរៀនទាំងនោះ។ ខ្ញុំមិនសូវយល់ពី E-Learning និងអត្ថន័យក្នុងគ្រីស្ទសាសនា តែខ្ញុំអាចយល់ពីរបៀបនៃការឌីហ្សាញ។ ខ្ញុំមើលចប់ប៉ុន្មានមេរៀន ហើយក៏បានកត់ទុកចំណុចមួយចំនួនដែលខ្ញុំគិតថា មិនសូវត្រូវ។ ខ្ញុំយកចំណុចនោះទៅនិយាយក្នុងពេលប្រជុំ។

គេស្ដាប់ហើយ ក៏ពន្យល់ខ្ញុំវិញពីមូលហេតុដែលគេធ្វើមេរៀនទាំងនោះ។ ខ្ញុំស្ដាប់ហើយ តែខ្ញុំមិនយល់ស្រប ក៏លើកហេតុផលរបស់ខ្ញុំទៅវិញ។ ហេតុផលរបស់ខ្ញុំភាគច្រើនចេញពីអ្វីដែលខ្ញុំរៀនក្នុងសៀវភៅប៉ុណ្ណោះ ចំណែកហេតុផលរបស់គេ គឺចេញពីបទពិសោធន៍។ ហេតុផលទៅ ហេតុផលមក អ្នកគ្រប់គ្រងរបស់ខ្ញុំ ក៏កាត់ដើម្បីកុំឱ្យយូរពេល។

យោបល់ផ្សេងគ្នាមែន តែវាជួយឱ្យអ្នកក្នុងក្រុមមើលឃើញពីកំហុសតូចៗផ្សេងទៀតដែលគេមើលរំលងពេលធ្វើមេរៀន។ ខ្ញុំក៏មើលឃើញច្រើនពីអ្វីដែលខ្ញុំមិនយល់ដែរ។ ការប្រឆាំងមតិនៅកន្លែងការងារ ធ្វើឡើងដើម្បីជួយកែតម្រូវឱ្យកាន់តែល្អ។ បើម្នាក់ៗ

ចេះតែងក់ក្បាល មេរៀនដែលពួកខ្ញុំធ្វើ ក៏មិនអាចចូលទៅដល់ទីផ្សារក្រៅស្រុកបានដែរ។ យើងមិនមែនប្រឆាំងមតិដើម្បីឈ្លោះគ្នាទេ តែយើងធ្វើបែបនេះដើម្បីជួយគ្នា។

# ការបដិសេធមិនចូលរួម

ការងារជាក្រុម ជៀសមិនផុតពីការធ្វើអ្វីរួមគ្នានោះទេ។ វាអាចជាការដើរលេង ការហូបចុក ឬការចូលរួមកម្មវិធី ដែលជាវិធីពង្រឹកទំនាក់ទំនងរវាងបុគ្គលិក។ ចៅកែក្រុមហ៊ុនឆ្លាតៗ ចូលចិត្តរៀបចំកម្មវិធីកំសាន្តដើម្បីឱ្យបុគ្គលិកស្និទ្ធស្នាលជាមួយគ្នា។ ប៉ុន្តែ យើងមិនចាំបាច់ចូលរួមគ្រប់ទាំងអស់ទេ ព្រោះបើធ្វើបែបនេះ យើងនឹងក្លាយជាទាសកររបស់អ្នកដទៃហើយ។ ទាសករ មិនហ៊ានបដិសេធអ្វីទេ។

ខ្ញុំមិនទៅចូលរួមដើម្បីឱ្យអ្នកដទៃរីករាយទេ។ ខ្ញុំនឹងចូលរួម បើខ្ញុំពេញចិត្តទៅ។ មិនមែនឱ្យតែគេបបួលយើង យើងត្រូវទៅតាមការបបួលរបស់គេរហូតឯណា។ បើសិនជាយើងមានហេតុផលគ្រប់គ្រាន់សម្រាប់ខ្លួនឯង យើងអាចបដិសេធនឹងគេបាន។

ការបដិសេធ មានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ គុណវិបត្តិរបស់វា គឺយើងអាចនឹងត្រូវគេទុកចោលមួយឡែក ប៉ុន្តែគុណសម្បត្តិវិញ គឺយើងសល់ពេលសម្រាប់ខ្លួនឯង និងធ្វើឱ្យអ្នកដទៃដឹងថា យើងជាមនុស្សដែលមានជំហរផ្ទាល់ខ្លួន។

បើសិនជាអ្នកបបួលយើងជាមនុស្សដែលចេះគិត និងមានឯករាជ្យលើខ្លួនឯង គេនឹងយល់ពីយើងដោយមិនបាច់សួរនាំ។ គេនឹងដឹងថា យើងមិនធ្វើតាមអ្នកដទៃដើម្បីចូលចំណោម ដោយមិនពិចារណាពីហេតុផលខ្លួនឯងទេ។ ហេតុផលដែលយើងមាន គឺជាប្រយោជន៍របស់យើង ហេតុនេះបើយើងមិនរវល់នឹងវា ហើយគិតតែពីដើរតាមគេរហូត យើងនឹងអស់ប្រយោជន៍ម្តងបន្តិចៗដោយសារការងារ។

ពេលដែលគេមានពិធីជប់លៀងចុងសប្តាហ៍នៅផ្ទះអ្នកណាម្នាក់ ខ្ញុំមិនដែលទៅទេ។ មូលហេតុរបស់ខ្ញុំ គឺខ្ញុំមិនចូលចិត្តពិធីជប់លៀងដែលមានតែការស៊ីចុក និងនិយាយរឿងដែលខ្ញុំមិនចាប់អារម្មណ៍។ ម្យ៉ាងទៀត ចុងសប្តាហ៍ ជាពេលវេលាដែលខ្ញុំមានសម្រាប់ខ្លួនឯង ហេតុនេះខ្ញុំមិនចង់លះបង់ពេលវេលាដ៏តិចតួចនេះ ដើម្បីផ្គាប់ចិត្តអ្នកដទៃ។

ខ្ញុំដឹងថា គេហៅខ្ញុំទៅ ព្រោះចង់ឱ្យទំនាក់ទំនងក្នុងក្រុមហ៊ុន មានភាពប្រសើរឡើង ប៉ុន្តែខ្ញុំមិនខ្វល់។ បើពួកគេគ្មានភាពច្នៃប្រឌិតក្នុងខ្លួន ហើយរកមិនឃើញវិធីផ្សេង ដើម្បីសាងទំនាក់ទំនងល្អក្នុងការងារទេ ខ្ញុំក៏មិនឈឺក្បាលដែរ។ យើងរៀនដកចិត្ត និងទំនួលខុសត្រូវមិនចាំបាច់ខ្លះចេញ ទើបយើងអាចបដិសេធអ្នកដទៃបាន។

ការបដិសេធ ដែលធ្វើឡើងដោយត្រឹមត្រូវ និងសមកាលៈទេសៈ ជាសេរីភាពដែលយើងគួរតែរក្សាទុក។ យើងមិនចូលរួមនឹងគេក្នុងរឿងផ្សេង មិនបានន័យថា យើងមិនចូលរួមក្នុងការងារទេ។ ការមិនចូលរួមរបស់យើង គឺឈរទៅលើហេតុផលដែលយើងមាន និងព្រំដែននៃការចំណាយពេលជាមួយអ្នកធ្វើការរួមគ្នា។

បើយើងមិនកំណត់ព្រំដែនទេ ពួកគេនឹងដណ្ដើមយកពេលវេលារបស់យើងទាល់តែអស់ ហើយយើងនឹងឆ្ងល់ថា ធ្វើការដូចគេ ហេតុអ្វីអ្នកដទៃទៀត ដូចជាមានពេលផ្ទាល់ខ្លួនច្រើនជាងយើង។ អ្វីដែលមិនគួរចូលរួម ឬមានអារម្មណ៍ថាមិនចូលចិត្ត យើងត្រូវបដិសេធ។ កុំទ្រាំតាមគេ ហើយធ្វើបាបខ្លួនឯងឱ្យសោះ។

# ការសម្រេចចិត្ត

នៅកន្លែងការងារ ការសម្រេចចិត្ត ជាសេរីភាពមួយដែលធ្វើឱ្យយើងធ្វើការដោយពេញចិត្ត ឬមិនពេញចិត្ត។ បើគេហាមយើងមិនឱ្យធ្វើការសម្រេចចិត្តគ្រប់យ៉ាងការងាររបស់យើង ក៏មិនខុសពីអ្នកទោសក្នុងទ្រុងដែរ។

យើងជាបុគ្គលិក ហេតុនេះ រឿងខ្លះយើងមិនអាចសម្រេចចិត្តបានមែន ប៉ុន្តែរឿងភាគច្រើនដែលទាក់ទងនឹងការងាររបស់យើង សុទ្ធតែនៅក្នុងបញ្ជីដែលយើងអាចសម្រេចដោយខ្លួនឯងបាន។ ក្រុមហ៊ុនខ្លះតឹងរឹងពេក រហូតធ្វើឱ្យបុគ្គលិកខ្លាចក្នុងការសម្រេចចិត្តដោយខ្លួនឯង។

ដោយសារការងាររបស់ខ្ញុំទាក់ទងនឹងការឌីហ្សាញមេរៀនសម្រាប់ដាក់លក់ ហេតុនេះមានរឿងជាច្រើនដែលខ្ញុំអាចសម្រេចដោយខ្លួនឯង។ ការប្រើប្រាស់ពណ៌ ការយករូបភាពមកប្រើ និងការបង្កើតចលនាទៅលើរូបភាព សុទ្ធតែឆ្លងកាត់ការសម្រេចចិត្តរបស់ខ្ញុំ។ ខ្ញុំមិនមែនសម្រេចចិត្តដោយមិនគិតអ្វីសោះទេ ព្រោះមុនពេលចាប់ផ្ដើម

ធ្វើមេរៀនមួយ ខ្ញុំត្រូវចំណាយពេលយ៉ាងហោចក៏ ពីរ ទៅបីថ្ងៃដែរ ដើម្បីស្វែងយល់ពីមេរៀន។ ខ្ញុំមិនយល់ច្បាស់ទេ ប៉ុន្តែយល់ល្មមអាចចាប់ផ្តើមធ្វើបាន។ ការងារបង្រៀនមនុស្សតាមជំហានរបស់វា។ ពេលមកដល់ជំហានផ្សេង ខ្ញុំនឹងយល់ផ្សេង ហើយបន្តបែបនេះរហូតដល់ការយល់របស់ខ្ញុំដល់កម្រិតដែលយល់លែងកើតទៀត។

ខ្ញុំមានថ្នាក់លើ ដែលចាំសម្រេចចិត្ត មុននឹងបញ្ចេញមេរៀនទៅលើអ៊ីនធឺណេត។ ការសម្រេចចិត្តរបស់គាត់ មានអាទិភាពជាងខ្ញុំ ហើយជួនកាលធ្វើឱ្យខ្ញុំពិបាកក្នុងការធ្វើតាមទៀតផង។ អ្វីដែលខ្ញុំគិតថា ខ្លួនឯងមានសំណាងគឺ ខ្ញុំធ្វើការពីក្រោមអ្នកដែលចេះជាង។ អ្វីដែលគាត់គិត ភាគច្រើនគឺល្អជាងខ្ញុំ ព្រោះគាត់មានបទពិសោធន៍ និងសមត្ថភាពយល់ពី E-Learning។

មានពេលខ្លះ ក្រុមហ៊ុនបើកសិទ្ធិឱ្យបុគ្គលិកសម្រេចចិត្តលើអ្វីដែលកំពុងធ្វើ ក្នុងគោលបំណង បណ្តុះបុគ្គលិកឱ្យចេះធ្វើការដោយខ្លួនឯង។ គេមិនចង់គ្រប់គ្រងបុគ្គលិកគ្រប់ចំណុចនោះទេ ព្រោះវាខាតពេល។ គេឱ្យយើងសម្រេចចិត្តលើរឿងតូចតាច ហើយធ្វើតាមគេចំពោះរឿងធំ។ សេរីភាពរបស់យើងមានដែនកំណត់ ព្រោះយើងជាខ្ញុំគេ ប៉ុន្តែបើចេះប្រើសេរីភាពនេះ ភាពជាខ្ញុំគេរបស់យើង ក៏មិនកំសត់ដែរ។

នៅមានចំណុចមួយទៀត ដែលយើងត្រូវតែយកមកគិតដែរ។ ជួនកាល គេមិនបើកដៃឱ្យយើងសម្រេចដោយខ្លួនឯង ព្រោះគេមើលឃើញថា យើងគ្មានសមត្ថភាពក្នុងការសម្រេចចិត្ត។ វាអាចមកពីខ្លួនយើង ដែលបិទសេរីភាពខ្លួនឯង។ មិនមែនបុគ្គលិកទាំងអស់ សុទ្ធតែអាចសម្រេចចិត្តលើការងារខ្លួនឯងទេ។ បុគ្គលិក ប្រៀបដូចជាសិស្សក្នុងថ្នាក់រៀនមួយដែរ មានអ្នករៀនពូកែ និងរៀនខ្សោយ។ បុគ្គលិកដែលពូកែ នឹងទទួលបានសេរីភាពច្រើនជាង បុគ្គលិកដែលមិនពូកែ។

ក្រុមហ៊ុនឱ្យសេរីភាពក្នុងសម្រេចចិត្ត ព្រោះគេទុកចិត្តលើបុគ្គលិក ហើយគេទុកចិត្តបុគ្គលិកបាន ដោយមើលលើស្នាដៃកន្លងមក។ យើងប្រឹងបង្កើតស្នាដៃល្អឱ្យច្រើនទៅ យើងនឹងបានសេរីភាពហើយ។ ធ្វើការឱ្យគេ មិនចាំបាច់ចង់បានភាពស្មើគ្នាទេ ឱ្យតែខ្លួនយើងមានសមត្ថភាពអាចយកបាន ត្រូវតែយក។

# ការធ្វើការងារផ្ទាល់ខ្លួន

បើយើងអាចយកការងារផ្ទាល់ខ្លួនទៅធ្វើក្នុងម៉ោងធ្វើការបាន នោះយើងមានសេរីភាពខ្លាំងណាស់។ គ្មានក្រុមហ៊ុនណាអាចសប្បាយចិត្ត នៅពេលដែលបុគ្គលិកយកម៉ោងធ្វើការទៅធ្វើរឿងផ្សេងទេ។ គេជួលយើងមកធ្វើការ ហេតុនេះគេចង់ឱ្យយើងផ្តោតកម្លាំង និងអារម្មណ៍ទាំងមូលមកលើការងាររបស់គេ។ គេជួលយើងមកបង្កើតប្រយោជន៍ឱ្យគេ មិនមែនប្រយោជន៍សម្រាប់ខ្លួនយើងទេ។

ក្រុមហ៊ុនចាស់ដែលខ្ញុំធ្លាប់ធ្វើការ មិនហាមឃាត់បុគ្គលិកធ្វើការផ្ទាល់ខ្លួនទេ បើសិនជាទំនេរ។ ពួកគេបើកសិទ្ធិឱ្យបុគ្គលិកអាចលក់ផលិតផលអនឡាញ នៅក្នុងម៉ោងធ្វើការ ប៉ុន្តែមិនមែនហួសហេតុពេកទេ។ បើសិនជាគ្មានអ្វីធ្វើ ការងារផ្ទាល់ខ្លួន អាចយកមកធ្វើបាន។

ខ្ញុំក៏យកការងារផ្ទាល់ខ្លួនទៅធ្វើនៅកន្លែងការងារដែរ។ បើគិតតាមវិន័យក្នុងការងារ ការធ្វើបែបនេះ គឺខុសហើយ។ ប៉ុន្តែបើគិតតាមសេរីភាព ការធ្វើខុសក្រមការងារ ជារឿងត្រឹមត្រូវវិញ។ បើយើងមិនហ៊ានធ្វើខុសពីអ្វីដែលគេកំណត់ តើយើងបានសេរីភាពមកពីណា? សេរីភាពខ្លះ ទាមទារឱ្យយើងហ៊ានធ្វើជាមុនសិន។ សេរីភាពដែលបានមកពីគេឱ្យ អាចមិនគ្រប់គ្រាន់សម្រាប់អ្នកដែលស្រលាញ់សេរីភាពខ្លាំង។

ការងារផ្ទាល់ខ្លួនរបស់ខ្ញុំ គឺសរសេរសៀវភៅ។ ជួនកាលក្នុងម៉ោងធ្វើការ ខ្ញុំនឹកឃើញអ្វីសម្រាប់ដាក់បញ្ចូលក្នុងសៀវភៅ ខ្ញុំត្រូវផ្អាកការងារមួយសន្ទុះសិន ដើម្បីសរសេរអ្វីដែលខ្ញុំនឹកឃើញចេញមក។ ខ្ញុំខ្លាចអ្វីដែលខ្ញុំនឹកឃើញនោះទៅវិញបាត់ ហេតុនេះខ្ញុំត្រូវចាត់ការវាភ្លាម។ ការងារផ្ទាល់ខ្លួន គឺនៅជាប់ជាមួយយើងពេញមួយថ្ងៃ។

ពេលខ្ញុំទើបចូលធ្វើការដំបូង ខ្ញុំចំណាយពេលប៉ុន្មានម៉ោងដើម្បីសរសេរសៀវភៅចរិតឆ្កែ។ ខ្ញុំមានគំនិតសរសេរក្នុងម៉ោងការងារ ដូច្នេះខ្ញុំត្រូវតែសរសេរ។ ខ្ញុំប្រើពេលមួយអាទិត្យដើម្បីសរសេរសៀវភៅនេះ ហើយភាគច្រើន គឺនៅក្នុងម៉ោងការងារ។

សម្រាប់ខ្ញុំ ការធ្វើជាខ្ញុំគេ មិនសំខាន់ ហើយក៏គ្មានតម្លៃអ្វីដែរ។ ខ្ញុំមិនអាចឱ្យតម្លៃទៅលើការងារផ្សេង ច្រើនជាងការងារផ្ទាល់ខ្លួនទេ។ អ្នកដទៃអាចនឹងគិតថា ខ្ញុំគ្មាន

ទំនួលខុសត្រូវ ឬមិនចេះបែងចែករឿងផ្ទាល់ខ្លួនចេញពីការងារ។ បើថា ខ្លួនខ្ញុំគ្មានទំនួលខុសត្រូវ គឺមិនត្រូវទាំងស្រុងទេ ព្រោះខ្ញុំមានទំនួលខុសត្រូវលើការងារផ្ទាល់ខ្លួនខ្លាំងណាស់។ ហើយបើថា ខ្ញុំមិនចេះបែងចែករឿងផ្ទាល់ខ្លួន ក៏មិនត្រូវដែរ ព្រោះពេលវេលាដែលខ្ញុំមានទាំងអស់ សុទ្ធតែធ្វើដើម្បីរឿងផ្ទាល់ខ្លួន។ រឿងការងារ មិនដែលឈរនៅលំដាប់ទីមួយក្នុងខួរក្បាលខ្ញុំទេ។

ខ្ញុំទៅធ្វើការដើម្បីរកលុយមកទប់ក្តីស្រមៃធ្វើជាអ្នកនិពន្ធសៀវភៅរបស់ខ្ញុំ និងរកអ្វីថ្មីមកសរសេរ។ ការងារ ជាឈ្នាន់ដ៏រឹងមាំមួយ ដែលអាចឱ្យខ្ញុំក្លាយជាអ្នកនិពន្ធដែលគ្មានបញ្ហារឿងលុយកាក់។ ការងារផ្ទាល់ខ្លួន តែងតែមានតម្លៃជាងការងារក្រៅខ្លួនជានិច្ច។

ក្រុមហ៊ុនដែលខ្ញុំធ្វើការ មិនបានហាមឃាត់រឿងនេះ។ គេមិនចូលចិត្ត តែក៏មិនហាមដែរ។ បើសិនជាយើងធ្វើជ្រុលពេក គេនឹងដេញយើងចោលតែម្តង ឬបើគេចង់ទុកយើង គេក៏មិនតម្លើងលុយ ឬដំណែងឱ្យយើង។ ខ្ញុំឃើញបុគ្គលិកប៉ុន្មាននាក់ដែលរវល់នឹងការងារផ្ទាល់ខ្លួនខ្លាំងពេក រហូតដល់ក្រុមហ៊ុនដឹង ហើយក៏មិនតម្លើងអ្វីឱ្យទាំងអស់។

ដោយសារការងារផ្ទាល់ខ្លួនរបស់ខ្ញុំ ងាយធ្វើ ហេតុនេះគេមិនសូវចាប់អារម្មណ៍នឹងសកម្មភាពរបស់ខ្ញុំទេ។ សេរីភាពរបស់ខ្ញុំត្រង់កន្លែងនេះ មានពេញបន្ទុក។

ទោះបីខ្ញុំយកការងារផ្ទាល់ខ្លួនទៅធ្វើមែន ក៏ខ្ញុំធ្វើទាន់ពេលកំណត់របស់ក្រុមហ៊ុនជានិច្ច។ ខ្ញុំលៃពេល មុននឹងចាប់ផ្តើមធ្វើអ្វីមួយ ព្រោះខ្ញុំមិនចង់បង្កើតកំហុសដោយសារការងារផ្ទាល់ខ្លួន។ ការងារផ្ទាល់ខ្លួនរបស់ខ្ញុំ ត្រូវតែជារឿងដែលនាំតែប្រយោជន៍ និងភាពរីករាយមកឱ្យខ្ញុំប៉ុណ្ណោះ។ ខ្ញុំប្រឹងរក្សាការងារផ្ទាល់ខ្លួនរបស់ខ្ញុំ ឱ្យស្ថិតក្នុងផ្នែកវិជ្ជមានគ្រប់ពេល។

# ការដើរចេញ

ការលាឈប់ពីការងារ ក៏ជាសេរីភាពមួយរបស់ខ្ញុំគេដែរ។ ការងារខ្លះ ទាមទារឱ្យយើងចុះកិច្ចសន្យាក្នុងរយៈពេលប៉ុន្មានឆ្នាំ ទើបអាចដាក់ពាក្យឈប់បាន។ ខាង

ក្រុមហ៊ុនតែងតែមានហេតុផលជានិច្ច ហើយភាគច្រើន គឺគេមិនចង់ខាតពេលបង្រៀនមនុស្សឱ្យចេះហើយ ក៏ចេញទៅធ្វើការកន្លែងផ្សេង។ សេរីភាពក្នុងការដើរចេញ ប្រៀបដូចជាយើងធ្វើការឱ្យគេ ដោយមិនជាប់ខ្នោះជើង។ ពេលណាយើងចង់ទៅ យើងអាចរៀបចំខ្លួនចេញភ្លាម ដោយមិនបាច់មានរឿងជាមួយក្រុមហ៊ុន។

ខ្ញុំធ្លាប់ដើរចេញពីការងារ៤ដង យ៉ាងងាយស្រួល។ ខ្ញុំគ្រាន់តែប្រាប់គេថា "ខ្ញុំធ្វើការលែងកើតនៅក្រុមហ៊ុនគាត់" ហើយក៏ដើរចេញ។ កាលពីខ្ញុំដាក់ពាក្យឈប់នៅក្រុមហ៊ុនទិញលក់រូបិយបណ្ណអន្តរជាតិ គេបង្គាប់ឱ្យខ្ញុំចុះកិច្ចសន្យាជាមួយគេក្នុងរយៈពេលពីរឆ្នាំ មិនឱ្យទៅធ្វើការក្នុងក្រុមហ៊ុនដែលប្រជែងគ្នាក្នុងទីផ្សារនេះ។ ខ្ញុំមិនចង់ធ្វើការរបៀបនេះបន្តទៀត ហេតុនេះ ខ្ញុំនៅតែមានសេរីភាពក្នុងការដើរចេញដដែល។

សេរីភាពក្នុងការដើរចេញ ត្រូវពឹងលើពីរផ្នែក គឺខាងក្រុមហ៊ុន និងខ្លួនយើង។ បើក្រុមហ៊ុន មិនតឹងរឹងចំពោះការលាឈប់ ហើយមិនចេះរករឿងបុគ្គលិកខ្លួនឯង យើងបានសេរីភាពពាក់កណ្តាលហើយ។ ក្រុមហ៊ុនខ្លះ ក៏ចេះឃោគយល់ដល់ស្នាដៃរបស់បុគ្គលិកដែរ ហើយធ្វើឱ្យគេមិនដេញដោលពេលយើងចង់ឈប់។

សេរីភាពពាក់កណ្តាលទៀត បានមកពីខ្លួនយើង។ យើងត្រូវប្រាកដក្នុងចិត្តថា មិនធ្វើអ្វីឱ្យខ្លួនឯងជាប់ក្នុងការងារ។ ចំណងមួយចំនួនដែលយើងត្រូវប្រយ័ត្ន មានដូចជា បំណុល ទំនាក់ទំនងស្និទ្ធស្នាលជ្រុល ស្នេហា ការជាប់ចិត្តជាមួយក្រុមហ៊ុនពេក កង្វះខាតជំនាញដែលចាំបាច់ និងចរិតខ្ជិលរកការងារថ្មី។ល។ ចំណងទាំងនេះ ជាការធ្វើបាបខ្លួនឯង។

បើយើងចង់បង្កើតសេរីភាពក្នុងការដើរចេញដល់ខ្លួនឯង ត្រូវត្រៀមខ្លួនដើរចេញគ្រប់ពេល។ ខាងក្រោមនេះជាវិធីដែលខ្ញុំត្រៀមខ្លួន៖

- យើងរៀនជំនាញថ្មីដែលចង់សាកល្បងធ្វើ ឬគិតថាអាចមានឱកាសរកការងារធ្វើបាន ឱ្យបានមុនយ៉ាងហោចណាស់ ៦ខែ។ ជំនាញថ្មីត្រូវការពេលយូរជាងនេះ ប៉ុន្តែក្នុងរយៈពេល ៦ខែ វាល្មមឱ្យយើងអាចធ្វើការបានហើយ។ ការងារនឹងបង្រៀនយើងថែម ដូច្នេះមិនបាច់ខ្លាចធ្វើមិនកើតទេ។

- កុំឱ្យខ្លួនយើងជំពាក់ចិត្តនឹងអ្វីទាំងអស់ មិនថាមនុស្ស ឬកន្លែងធ្វើការទេ។ រៀនធ្វើចិត្តដាច់ ទើបយើងមានសេរីភាព។ សេរីភាពមានតម្លៃ តែមុននឹងបានវា យើងក៏ត្រូវលះបង់ដែរ។ រឿងទីមួយដែលយើងត្រូវលះបង់ គឺមនោសញ្ចេតនាក្នុងការងារ។ ខ្ញុំទៅធ្វើការ និងលេងសើចជាមួយអ្នកដទៃធម្មតា តែខ្ញុំមិនបណ្តោះមនោសញ្ចេតនាជាមួយអ្វីទាំងអស់ ព្រោះខ្ញុំដឹងថា បើវាដុះហើយ ខ្ញុំប្រហែលជាត្រូវធ្វើការមួយកន្លែងដល់ចាស់មិនខាន។
- កុំខ្ជិល និងកុំខ្លាចសាកល្បងការងារថ្មី។ ការសាកល្បងការងារថ្មី សម្រាប់យើងជាខ្ញុំគេ ប្រៀបដូចជាការពិសោធន៍របស់អ្នកវិទ្យាសាស្ត្រដែរ។ យើងគ្មានខួរក្បាលឆ្លាតដូចពួកអ្នកវិទ្យាសាស្ត្រ តែយើងអាចយកខ្លួនឯងមកសាកបាន។

យើងធ្វើការដោយមិនបាច់ភ័យខ្លាច នៅពេលយើងមានសេរីភាពក្នុងការដើរចេញ។ យើងមិនខ្លាចគេដេញចេញ ហើយក៏មិនខ្លាចខ្លួនឯងដើរចេញមិនរួចដែរ។ សេរីភាពបែបនេះ មិនស្មើនឹងសេរីភាពដែលបានមកពីការមានលុយច្រើន និងមានអំនាចមែន ប៉ុន្តែវាអាចធ្វើឱ្យយើងនិយាយលួងខ្លួនឯងថា “បានប៉ុណ្ណឹងហើយ ចង់បានអីទៀត”?

ត្រូវចាំ យើងជាខ្ញុំគេ ហេតុនេះសេរីភាពដែលយើងមាន ក៏ជាសេរីភាពបែបខ្ញុំគេដែរ ដូច្នេះកុំចង់បានហួសពីការពិត។ បើចង់បានសេរីភាពបែបផ្សេង សូមរកវិធីដោយខ្លួនឯង ព្រោះខ្ញុំគ្មានសមត្ថភាពប្រាប់ផ្លូវឱ្យចេញផុតពីខ្ញុំគេទេ។

# សេរីភាព ជារបស់មានតម្លៃ

បើសិនជាមានគេសួរខ្ញុំថា តើអ្វីដែលខ្ញុំចាត់ទុកថា មានតម្លៃបំផុត? ខ្ញុំនឹងឆ្លើយថា សេរីភាព។ មានតែសេរីភាពទេ ទើបជីវិត មានន័យពិតមែន។ អត្ថន័យនៃជីវិតជាច្រើន ត្រូវបានគេបង្កើតឡើងដើម្បីលួងខ្លួនឯង និងបោកប្រាស់អ្នកដទៃឱ្យជឿតាមមនោគមវិជ្ជារបស់ខ្លួន។ អត្ថន័យនៃជីវិត ស្ថិតលើកម្រិតនៃសេរីភាពដែលយើងទទួលបាន និងបង្កើតឡើងដោយខ្លួនឯង។

មនុស្សក្នុងសម័យនេះ ឱ្យតម្លៃទៅលើរបស់គ្រប់យ៉ាងដែលកាត់បន្ថយសេរីភាពរបស់ពួកគេ។ ពួកគេមើលមិនឃើញតម្លៃរបស់សេរីភាពទៀតទេ ព្រោះអ្នកដែលចង់បាន

សេរីភាពរបស់មនុស្សទូទៅ បានប្រើវិធីគ្រប់យ៉ាងដើម្បីពង្វក់ចិត្តមនុស្ស ឱ្យស្អប់សេរីភាព។ ត្រឹមតែប៉ុននេះ មិនទាន់អស់ចិត្តទេ គេនៅប្រើវិធីឱ្យមនុស្សទាំងអស់ស្អប់អ្នកដែលទាមទារសេរីភាពឱ្យខ្លួនឯងទៀតផង។ ចំពោះអ្នកដែលទាមទារសេរីភាពឱ្យអ្នកដទៃ មិនត្រូវរាប់បញ្ចូលទេ ព្រោះពួកគេច្រើនតែធ្វើដើម្បីបានមុខមាត់ និងផលប្រយោជន៍ពីក្រោយខ្នង ឬមានគេប្រើឱ្យធ្វើប៉ុណ្ណោះ។

ហេតុនេះ មិនថាយើងជាខ្ញុំគេ ឬជាអ្វីទេ កុំភ្លេចសេរីភាពរបស់ខ្លួនឯង។ សេរីភាពមានតម្លៃណាស់។ តម្លៃរបស់វា ស្ថិតក្រោមតម្លៃរបស់ពេលវេលា។ សេរីភាព អាចធ្វើឱ្យពេលវេលាដែលយើងមាន កាន់តែមានតម្លៃរាប់ដង។ សាកគិតទៅមើល បើយើងមានពេល៨ម៉ោង ហើយមិនមានសេរីភាពនិយាយ ឬគិតពីអ្វី តើពេល៨ម៉ោងនោះជាពេលដែលខាតបង់ ឬមានប្រយោជន៍?

បើការងារដែលយើងកំពុងធ្វើ មិនមានសេរីភាពគ្រប់គ្រាន់សម្រាប់យើង ត្រូវរកវិធីបង្កើតសេរីភាពឱ្យបាន។ បើនៅតែបង្កើតមិនបាន ត្រូវរកវិធីដើរចេញ។ ការងារដែលគ្មានសេរីភាព នឹងបំផ្លាញយើងនៅថ្ងៃណាមួយ។ ការងារបែបនេះ បានបំផ្លាញគ្រួសារខ្ញុំរួចហើយ ដូច្នេះបើជៀសបាន យើងគួរតែជៀសទៅ។

# ៧

# ការរាប់អានគ្នាក្នុងការងារ

យើងទៅធ្វើការជាមួយមនុស្ស តើមានវិធីណាជៀសផុតពីការរាប់អានគ្នាដែរទេ? ការរាប់អានក្នុងការងារ ក៏ជាផ្នែកមួយនៃការងារដែរ។ បើយើងធ្វើបានល្អ ការងាររបស់យើងអាចនឹងប្រសើរជាងមុន តែបើយើងធ្វើមិនបានល្អ ការងារក៏នៅតែទៅមុខដែរ គ្រាន់តែយើងមិនសូវសប្បាយប៉ុណ្ណោះ។ ខ្ញុំមិនថា ការរាប់អានក្នុងការងារមិនសំខាន់ទេ តែវាក៏មិនសូវសំខាន់។ ទោះបីជាមិនសូវសំខាន់ ក៏យើងត្រូវតែស្វែងយល់ពីវាដដែល។

នៅក្នុងការងារ អ្វីក៏មានដំណាក់កាលវាដែរ។ យើងត្រូវធ្វើឱ្យរួចក្នុងដំណាក់កាលមួយទើបអាចបន្តទៅមុខបាន។ ការរាប់អាន ក៏មិនខុសពីផ្នែកផ្សេងៗក្នុងការងារដែរ។ យើងត្រូវធ្វើម្តងមួយដំណាក់ ទើបទៅដល់ចំណុចកំពូលនៃការរាប់អាន។

អ្វីដែលខ្ញុំសរសេរក្នុងចំណុចនេះ មិនមែនជាសម្ដីរបស់អ្នកជំនាញទេ តែវាជាបទពិសោធន៍របស់ខ្ញុំ។ នៅពេលអ្នកទាំងអស់គ្នាអានចំណុចនេះរួច សូមព្យាយាមសម្គាល់ដោយខ្លួនឯង នៅពេលដែលចូលធ្វើការនៅកន្លែងណាក៏ដោយ។ វាអាចមានការប្រែប្រួលខ្លះ ប៉ុន្តែដំណាក់កាលរបស់ គឺនៅដដែល។ ខ្ញុំនឹងចាប់ផ្តើមពីដំណាក់កាលដំបូង បន្ទាប់ពីខាងក្រុមហ៊ុនប្រាប់យើងពីថ្ងៃដែលចូលធ្វើការ។

# ការស្វាគមន៍មកកាន់ការងារថ្មី

ការរាប់អានគ្នាចាប់ផ្តើមពីថ្ងៃថ្មីដែលយើងគិតថា ខ្លួនឯងនឹងធ្វើបានល្អ។ តាមទម្លាប់ និងក្បួនច្បាប់នៃការគោរពគ្នានៅកន្លែងធ្វើការ គេនឹងធ្វើការស្វាគមន៍យើងមកធ្វើការជាមួយបុគ្គលិកចាស់ៗ។ ការស្វាគមន៍នេះ ខុសពីការស្វាគមន៍គណៈរដ្ឋមន្ត្រី ដែលមានគេឈរចាំទទួលយើង។ យើងត្រូវដើរតាមបុគ្គលិកណាម្នាក់ដែលពូកែនិយាយ ដើម្បីទៅជួប ហើយសួស្តីបុគ្គលិកចាស់ៗដែលអង្គុយធ្វើការក្នុងទឹកមុខមិនសូវល្អ។

យើងត្រូវណែនាំឈ្មោះខ្លួនឯង ដើម្បីឱ្យបុគ្គលិកចាស់ៗស្គាល់យើង។ ពួកគេអាចនឹងចាំឈ្មោះយើងក្នុងរយៈពេលប៉ុន្មានម៉ោង ក្រោយមក ឈ្មោះយើងនឹងចេញតាមខ្យល់ផោមដែលគេពត់ខ្លួនចុះឡើង។

ក្រោយមក យើងត្រូវធ្វើការ add គ្នាទៅវិញទៅមក ដើម្បីទាក់ទងគ្នាតាមរយៈគ្រឿងអេឡិចត្រូនិច។ យើងជាបុគ្គលិកថ្មី ហេតុនេះត្រូវដាក់ខ្លួន ហើយ add ទៅគេគ្រប់គ្នា ដើម្បីឱ្យគេគិតថា យើងចង់រាប់អានគេ។ ទំនាក់ទំនងអនឡាញដែលកើតមុនទំនាក់ទំនងក្នុងជីវិតពិត ជាទំនាក់ទំនងក្លែងក្លាយ ឬទំនាក់ទំនងដែលសម្លឹងឃើញប្រយោជន៍។ វាមិនជាបញ្ហាទេ ព្រោះរឿងក្លែងក្លាយក្នុងទំនាក់ទំនងមានច្រើនជាងនេះទៀត។

ដំណាក់កាលដំបូង ជាដំណាក់គ្មានន័យ តែល្អមើល និងធ្វើឱ្យក្រុមហ៊ុនមានភាព professional។ ដំណាក់កាលនេះ ធ្វើឱ្យខ្ញុំគិតថាខាតពេល។ ពេលខ្ញុំចូលធ្វើការដំបូង គេបានផ្ញើសារមកខ្ញុំថា "ស្វាគមន៍មកកាន់គ្រួសារ Khalibre"។ ពេលនោះខ្ញុំភ្ញាក់ផ្អើលមែនទេ តែខ្ញុំមិនទាន់ជឿសារមួយឃ្លានេះទេ។ ការភ្លេចយកជំនឿពីផ្ទះមកដាក់ជាប់ខ្លួនរបស់ខ្ញុំ តែងតែជួយឱ្យខ្ញុំមើលអ្នកដទៃក្នុងផ្លូវកណ្តាលជានិច្ច។ ខ្ញុំមិនគិតថា គេជាមនុស្សអាក្រក់ទេ តែខ្ញុំក៏មិនសន្និដ្ឋានថាគេល្អដែរ។ ការសន្និដ្ឋានដោយគ្មានអ្វីជាសំអាង តែងតែនាំឱ្យមានការយល់ច្រលំ។

ក្រុមហ៊ុនដែលសំបូរបុគ្គលិកចាស់ៗធ្វើការច្រើន តែងតែប្រើពាក្យ "គ្រួសារ" ធ្វើជាដំណាងឱ្យបុគ្គលិកទាំងអស់ជានិច្ច។ គេធ្វើបែបនេះ ក្នុងគោលបំណងបីយ៉ាង គឺ

ផ្ចាប់ចិត្តថៅកែ បង្កើតទំនាក់ទំនងឱ្យឆាប់រហ័ស(តែផុយស្រួយ) និងនិយាយតាមគ្នា។ ការយកពាក្យ “គ្រួសារ” មកប្រើក្នុងកន្លែងការងារ ជារឿងមិនសមហេតុផលមួយ ក្នុងចំនោមរឿងមិនសមហេតុផលផ្សេងទៀត។ កន្លែងការងារ ជាកន្លែងប្រមូលផ្តុំមនុស្សខុសគ្នាមកធ្វើការជុំគ្នាដើម្បីប្រយោជន៍ ថៅកែ និងប្រយោជន៍បុគ្គលជាខ្ញុំគេ។ នេះជានិយមន័យដែលអាចជម្រះការសង្ស័យរបស់អ្នកដែលទើបនឹងចូលធ្វើការបាន។

កន្លែងការងារ ជាកន្លែងដែលយើងត្រូវជួបមនុស្សប្លែកមុខជាច្រើន។ យើងមិនដឹងថាគេជាមនុស្សបែបណា ហេតុនេះដំណាក់ស្វាគមន៍គ្នា ជាពេលវេលាបំផុតដែលយើងរៀនស្គាល់គេ។ បើយើងឆ្លាត យើងអាចស្គាល់គេមុនគេស្គាល់យើង។ កុំបញ្ចេញរឿងរបស់យើងច្រើនពេក បើយើងមិនទាន់ច្បាស់ថាស្គាល់គេ។ ចរិតពិតរបស់មនុស្សនឹងបញ្ចេញមកម្តងបន្តិចៗ ហេតុនេះការអត់ធ្មត់ និងការសង្កេតជាវិធីសាស្ត្រល្អក្នុងការរៀនពីមនុស្ស។

ដូច្នេះ ក្នុងដំណាក់កាលទីមួយ ត្រូវគិតថា អ្វីក៏អាចជាការបោកប្រាស់ដែរ។ ស្នាមញញឹម ការចាប់ដៃ ការនិយាយលេង ឬសូម្បីតែពាក្យថាគ្រួសារ សុទ្ធតែអាចជាការបំភាន់ភ្នែកយើងទាំងអស់។ យើងមិនចាំបាច់ធ្វើអ្វីច្រើនទេ ប្រាប់តែឈ្មោះ ហើយឡើងមកអង្គុយធ្វើការ ដោយមិនចាំបាច់ខ្វល់ពីអ្នកដែលទើបនឹងឃើញទៅបានហើយ។ កុំជំពាក់អារម្មណ៍ និងដាក់ទំនុកចិត្តទៅលើអ្នកណាម្នាក់ក្នុងពេលដែលយើងជួបគេដំបូងឱ្យសោះ។

# ការធ្វើការងាររួមគ្នា

ក្រុមហ៊ុន ជាកន្លែងដែលមនុស្សមានជំនាញខុសគ្នា ឬគ្មានជំនាញសោះ រួមគ្នាធ្វើកិច្ចការណាមួយដែលជាផ្នែកនៃគោលដៅរបស់ក្រុមហ៊ុន។ ក្នុងពេលដែលយើងធ្វើការផ្សេងគ្នានេះ ទំនាក់ទំនងនឹងកើតឡើងបណ្តើរៗ។ យើងអាចនឹងមិនចាប់អារម្មណ៍ថា ហេតុអ្វីបានជាយើងមានអារម្មណ៍ធូរស្រាលជាមួយអ្នកធ្វើការផ្សេងទៀត។ យើងចាប់ផ្តើមស្គាល់គេ ដោយមិនដឹងខ្លួន។

ដំណាក់កាលទីពីរនេះ ជាការចាប់ផ្តើមនៃការស្វែងយល់របស់យើង។ យើងរៀនពីអ្នកជុំវិញខ្លួនយើង ដើម្បីរីកចម្រើនខ្លួនឯង។ ការធ្វើបែបនេះ មិនហៅថា អាត្មានិយមទេ ព្រោះនៅពេលដែលយើងកំពុងរៀនពីគេ គេក៏បានរៀនពីយើងដូចគ្នាដែរ។ ការរៀនតាមគ្នាទៅវិញទៅមក ធ្វើឱ្យអ្នកធ្វើការជាមួយគ្នា អាចស្គាល់គ្នាបាន។

ដំណាក់កាលទីពីរ ជាដំណាក់កាលដែលខ្ញុំរំភើប។ ខ្ញុំចាប់ផ្តើមមើលថា តើអ្នកណាដែលមានសមត្ថភាពការងារជាងខ្ញុំ ហើយអ្នកណាឆ្លាតជាងខ្ញុំ។ ខ្ញុំចូលចិត្តធ្វើបែបនេះ ព្រោះបើដឹងថាអ្នកណាឆ្លាតហើយ ខ្ញុំនឹងប្រើពេលតាមដានអ្វីដែលគេធ្វើឱ្យបានច្រើន។ ខ្ញុំក៏ចង់ឆ្លាតដូចគេដែរ ព្រោះភាពឆ្លាត ជាកំណប់ដែលអាចប្រើបាននៅថ្ងៃក្រោយទៀត។ ភាពឆ្លាតវៃ អាចបណ្តុះបាន ជាពិសេស បើយើងមានឧទាហរណ៍ស្រស់ៗនៅនឹងមុខ។

សំណាងដែរ ដែលខ្ញុំបានធ្វើការជាមួយអ្នកដែលមានបទពិសោធន៍ច្រើនជាងខ្ញុំ។ ក្នុងបន្ទប់ធ្វើការរបស់ខ្ញុំ អ្នកដែលធ្លាប់ធ្វើក្នុងផ្នែក E-Learning នេះ យ៉ាងហោចក៏មានបទពិសោធន៍លើសពី ១ឆ្នាំដែរ ហើយច្រើនបំផុត គឺ៨ឆ្នាំ។ អ្វីដែលខ្ញុំមានលើសគេ គឺចំណេះដឹងផ្នែកក្រាហ្វិចឌីហ្សាញ និងវេបសាយប៉ុណ្ណោះ។

ពេលធ្វើការ ខ្ញុំតែងតែសួរគេនូវអ្វីដែលធ្វើមិនចេញ។ ការងារក៏ទៅមុខ ការរាប់អានរបស់ខ្ញុំក៏មានបន្តិចម្តង។ ក្រៅពីបទពិសោធន៍ ខ្ញុំក៏អាចដឹងពីការគិត និងចរិតរបស់គេផងដែរ។ ខ្ញុំដឹងតែអ្វីដែលគេចង់ឱ្យខ្ញុំដឹងប៉ុណ្ណោះ រឿងដែលគេប្រឹងលាក់ ខ្ញុំត្រូវតាមមើលដោយខ្លួនឯង។ ការរាប់អានមនុស្ស ជារឿងសំខាន់ ហេតុនេះ យើងមិនអាចធ្វើពើមិនសង្ស័យ ឬចង់ដឹងឱ្យបានច្រើននោះទេ។ ការធ្វើពើ មិនចង់ដឹង ធ្វើឱ្យយើងមានគ្រោះថ្នាក់ព្រោះការរាប់អាន។

មនុស្ស ជាសត្វដែលគួរឱ្យចាប់អារម្មណ៍ ព្រោះមានរឿងជាច្រើនដែលអាចយកមកគិតឡើងវិញបាន។ ពេលធ្វើការ យើងនឹងឃើញជាតុពិតរបស់ពួកគេ។ ជាតុពិតទាំងនោះនឹងបញ្ចេញនៅពេលជួបបញ្ហាដែលមិនបានគិតទុក ឬការសរសើរ។ យើងអាចនឹងដឹងថា តើគេជាមនុស្សដែលចូលចិត្តដោះស្រាយបញ្ហា ឬដើរចេញពីបញ្ហា។ យើងក៏អាចដឹងថាគេជាមនុស្សដែលស៊ីជោរ ឬមិនខ្វល់ពីពាក្យអ្នកដទៃដែរ។

បើមិនធ្វើការជាមួយគ្នា គឺមិនស្គាល់គ្នាទេ។

# សកម្មភាពខាងក្រៅ

ដំណាក់កាលបន្ទាប់ គឺការទៅខាងក្រៅ។ វាអាចជាញ៉ាំអីជុំគ្នា ការដើរកំសាន្ត ឬការចូលរួមកម្មវិធីអ្វីមួយ។ ខ្ញុំមិនសូវជាពេញចិត្តនឹងដំណាក់កាលទីបីប៉ុន្មានទេ ព្រោះវាធ្វើឱ្យខ្ញុំហត់។

ពេលខ្ញុំចូលធ្វើការដំបូង គេហៅខ្ញុំទៅសាកម្ហូបបួសបែបបរទេស ដើម្បីបានណែនាំគ្នា។ គេព្យាយាមនិយាយជាមួយខ្ញុំ ដើម្បីឱ្យទំនាក់ទំនងកើតឡើង។ ឱ្យតែមានបុគ្គលិកថ្មីចូលមកធ្វើការ គេនឹងធ្វើបែបនេះរហូត។ ខ្ញុំមិនច្បាស់ថា វាបានផលដល់កម្រិតណាទេ ប៉ុន្តែបើមិនទាន់មានដំណាក់កាលនេះទេ ការរាប់អានមិនទាន់អាចចាត់ទុកថាល្អទេ។

ការមានត្រឹមតែទំនាក់ទំនងនៅកន្លែងធ្វើការមួយមុខ មិនគ្រប់គ្រាន់ឱ្យមនុស្សបើកចិត្តទូលាយធ្វើការរួមគ្នាទេ។ សូម្បីថៅកែក្រុមហ៊ុន ក៏គាត់គិតដល់រឿងនេះដែរ ហេតុនេះរាល់ឆ្នាំ គេតែងរៀបចំដំណើរកំសាន្តទៅតាមខេត្តជានិច្ច ដើម្បីឱ្យបុគ្គលិករាប់អានគ្នាល្អជាងមុន។ បុគ្គលិកមិនត្រូវគ្នា ជាបញ្ហារាំងស្ទះដល់ការងារ។ ការងារត្រូវធ្វើត្រឹមតែ១អាទិត្យ អាចនឹងបន្លាយពេលដល់១ខែ ព្រោះបុគ្គលិកមិនចង់និយាយរកគ្នា។

ខ្ញុំមិនបានចូលរួមគ្រប់សកម្មភាពខាងក្រៅជាមួយគេទេ ព្រោះខ្ញុំមានរឿងផ្ទាល់ខ្លួនដែលត្រូវធ្វើ។ ការរាប់អានរបស់ខ្ញុំជាមួយអ្នកដទៃ ក៏មិនសូវល្អដែរ។ ខ្ញុំគ្មានបញ្ហាក្នុងការងារទេ តែមានបញ្ហាក្នុងផ្នែកទំនាក់ទំនង។ វាអាចមកពីខ្ញុំគ្មានជំនាញទំនាក់ទំនង ឬមកពីខ្ញុំមិនចង់មានតែម្តង។ ខ្ញុំស្គាល់ខ្លួនឯងច្បាស់ថា ខ្ញុំមិនចូលចិត្តភាពស្និទ្ធស្នាលជ្រុលពេកក្នុងការងារទេ ព្រោះវាធ្វើឱ្យអ្នកដទៃបានចិត្ត ហើយការងារខ្ញុំអាចនឹងយឺតយ៉ាវ។

ដំណាក់កាលទីបី អាចនឹងលួចយកពេលវេលារបស់យើងទៅទាំងអស់ បើយើងមិនចេះគិត និងមិនហ៊ានប្រកែក។ យើងអាចឆ្លងដំណាក់កាលនេះបាន ដោយដឹងឱ្យ

បានមុនពីគោលបំណងការអញ្ជើញរបស់គេ។ បើគេហៅដើម្បីពង្រឹងការរាប់អាន យើងគួរតែទៅខ្លះក៏បានដែរ តែបើគេហៅដើម្បីតែបានគ្នា បើសិនជាអត់បាន កាន់តែល្អសម្រាប់យើង។ គិតពីខ្លួនឯងមុនសិន មុននឹងចង់ធ្វើអ្វីមួយដើម្បីការរាប់អាន។ បើការរាប់អាន ទាមទារឱ្យយើងលះបង់ខ្លួនឯងចោល ខ្ញុំគិតថា វាមិនសមនឹងតម្លៃទេ។

# មិត្តភក្តិក្នុងការងារ

នេះជាដំណាក់កាលចុងក្រោយនៃការរាប់អានក្នុងការងារ។ មិត្តភាព មិនមែនបង្កើតឡើងដោយគ្រាន់តែចុចប៊ូតុងមួយនៅលើវេបសាយទេ។ មិត្តភាពក៏មិនមែនបង្កើតឡើងដោយការអង្គុយធ្វើការជាប់គ្នារាល់ថ្ងៃដែរ។ មិត្តភាព កើតឡើងពីការសម្រេចចិត្តរវាងភាគីទាំងសងខាងដែលយល់ព្រមឱ្យម្ខាងទៀត ចូលមកក្នុងជីវិតរបស់គេ។ មិត្តភាព មិនកើតឡើងក្នុងពេល១ខែ ឬ១ឆ្នាំទេ វាត្រូវការពេលយូរជាងនេះ។

ខ្ញុំមិនមានមិត្តភក្តិក្នុងការងារទេ ព្រោះខ្ញុំមិនដែលធ្វើការលើសពីពាឆ្នាំ។ ខ្ញុំមិនដឹងថាយកអ្នកណាមកធ្វើជាមិត្តភក្តិខ្ញុំទេ ព្រោះពេលខ្ញុំកាន់តែស្គាល់គេច្បាស់ ខ្ញុំកាន់តែជឿថា មិត្តភាពដែលខ្ញុំចង់បាន មិនអាចកើតឡើងទេ។ ខ្ញុំចង់បានមិត្តភក្តិ តែមិនមែនចង់បានដោយមិនគិតទេ។ ខ្ញុំមានមិត្តភក្តិតែប៉ុន្មាននាក់ប៉ុណ្ណោះ តែពួកគេអាចជួយខ្ញុំបានស្ទើរតែគ្រប់ពេល។ មិត្តភាព មិនគិតលើបរិមាណទេ តែគិតលើគុណភាព។

មិត្តភក្តិក្នុងការងារ ជារឿងល្អ តែក៏ជារឿងកម្រដែរ។ មានតែអ្នកធ្វើការក្នុងកន្លែងដដែលរាប់ឆ្នាំទេ ដែលអាចមានមិត្តភក្តិបាន។ ដំណាក់កាលនេះ ជារឿងផ្ទាល់ខ្លួន។ ខ្ញុំគ្មានអ្វីច្រើនដើម្បីបកស្រាយពីមិត្តភាពក្នុងការងារទេ ព្រោះខ្ញុំមិនធ្លាប់មាន។ ខ្ញុំគ្រាន់តែដឹងថាវាអាចទៅរួច តែមិនដឹងថាធ្វើវាបានដោយរបៀបណា។

# ការរាប់អាន និងការត្រឹមតែស្គាល់

ចំណុចខុសគ្នា រវាងការរាប់អាន និងការត្រឹមតែស្គាល់ គឺការខ្វល់។ បើយើងខ្វល់ពីអ្នកណាម្នាក់នៅកន្លែងធ្វើការ បានន័យថា យើងរាប់អានគេហើយ។ បុគ្គលិកនៅក្នុងក្រុមហ៊ុនមានប្រហែលជា ៤០នាក់ ខ្ញុំរាប់អានមិនបាន២០នាក់ផង តែខ្ញុំស្គាល់ទាំង

អស់។ ខ្ញុំដឹងថាអ្នកណាធ្វើការផ្នែកអី ឬជិះម៉ូតូអីទៀតផង តែខ្ញុំមិនដែលនិយាយជាមួយពួកគេ។ ពេលខ្លះ គ្រាន់តែញញឹមពេលដើរកាត់គ្នាប៉ុណ្ណោះ។

មិនមែនឱ្យតែយើងស្គាល់ គឺយើងរាប់អានគេនោះទេ។ ខ្ញុំស្គាល់ CEO របស់ខ្ញុំ តែខ្ញុំមិនដែលរាប់អានគាត់។ គ្រាន់តែសួរសុខទុក្ខគាត់ ក៏ខ្ញុំមិនដែលនឹកឃើញផង។ បើយើងបែងចែកចំណុចនេះបាន យើងប្រហែលជាស្រួលធ្វើការហើយ។

# ប្តូរយោបល់ ប្តូរបទពិសោធន៍

ចំណុចល្អពីរយ៉ាងដែលលាក់ទុកក្នុងការរាប់អាន គឺ យោបល់ និងបទពិសោធន៍។ ពេលយើងរាប់អានអ្នកណាម្នាក់កាន់តែយូរ គេនឹងបញ្ចេញយោបល់ និងបទពិសោធន៍របស់គេមកឱ្យយើងដោយមិនគិតថ្លៃ។ យោបល់ និងបទពិសោធន៍របស់អ្នកល្បីមួយចំនួន មានតម្លៃជាងការប្រកាសលក់ព្រហ្មចារី តាមអ៊ីនធឺណេតទៀតផង។ ខ្ញុំមិនឱ្យតម្លៃទៅលើយោបល់ គ្រប់ប្រភេទទេ ប៉ុន្តែសម្រាប់បទពិសោធន៍ជារឿងផ្សេង។

យោបល់ និងបទពិសោធន៍របស់អ្នកដទៃ អាចជួយរកកំហុសនៅក្នុងការងារយើងបាន។ បើគេមិនរាប់អានយើង គេក៏មិនខាតពេលឱ្យយោបល់យើងដែរ។ អ្នកចេះខ្លះចូលចិត្តលាក់ចំណេះណាស់ ហេតុនេះបើយើងមិនត្រូវជាអ្វីនឹងគេ មួយម៉ាត់ក៏គេមិននិយាយរកយើងដែរ។ មួយម៉ាត់របស់អ្នកចេះ អាចជួយយើងបានច្រើនជាងអង្គុយគិតខ្លួនឯងទៀត។

បើមានគេចេះច្រើនជាងខ្ញុំ គ្មានហេតុផលអីដែលខ្ញុំមិនរៀនតាមគេទេ។ ខ្ញុំអាចដឹងថាអ្នកណាចេះជាងខ្ញុំ ហើយអ្នកណាចេះក្រោមខ្ញុំ។ បើខ្ញុំគិតថា មិនសមនឹងស្តាប់ ខ្ញុំនឹងដើរចេញ។ ខ្ញុំមិនខាតពេលជាមួយយោបល់គ្មានបានការទេ ព្រោះយោបល់បែបនេះច្រើនតែចេញពីមនុស្សដែលគ្មានបទពិសោធន៍ ហើយគិតថាថាខ្លួនឯងមានបទពិសោធន៍។

ត្រូវចាំថា យើងមិនលួចយកប្រយោជន៍ម្នាក់ឯងពីការរាប់អានគ្នាទេ ព្រោះយើងប្តូរយោបល់ និងបទពិសោធន៍ឱ្យគ្នាទៅវិញទៅមក។ ខ្ញុំឱ្យយោបល់ទៅអ្នកធ្វើការ

ជាមួយខ្ញុំមិនតិចទេ ទោះបីគេមិនធ្វើតាមក៏ដោយ តែខ្ញុំធ្វើដើម្បីឱ្យមានភាពស្មើគ្នាប៉ុណ្ណោះ។ ខ្ញុំមិនមែនជាអ្នករកស៊ី ហេតុនេះភាពស្មើគ្នា ខ្ញុំអាចឱ្យទៅអ្នកដទៃបាន។

# ៨

# ការបែងចែកពេល

Brain Tracy បានសរសេរថា “ការរៀបចំពេលវេលា គឺជាការរៀបចំជីវិតរបស់យើង” ហើយយើងនឹងមើលឃើញការពិតនៅក្នុងឃ្លានេះកាន់តែច្បាស់ ពេលយើងធ្វើការកាន់តែយូរ។ ដើមទុនដ៏មានតម្លៃរបស់ខ្ញុំគេ គឺពេលវេលា។ ពួកគេយកដើមទុននេះទៅរកស៊ីដើម្បីបានប្រាក់មកចិញ្ចឹមខ្លួនឯង និងបានមុខមាត់ថ្លៃថ្នូរបន្តិចបន្តួចក្នុងសង្គម។

យើងមានពេលវេលា ២៤ម៉ោងក្នុងមួយថ្ងៃ។ យើងកាត់យក ៨ ទៅ១០ម៉ោង (រួមទាំងពេលធ្វើដំណើរ) ដើម្បីបំពេញការងារ។ ក្នុងរយៈពេលនេះ គឺជាពេលដែលយើងត្រូវបញ្ចេញស្នាដៃ។ យើងមិនបាច់គិតថា ធ្វើដើម្បីក្រុមហ៊ុន ឬដើម្បីក្រុមការងាររបស់យើងទេ ព្រោះវាអាចហួសពីការពិត។ យើងត្រូវគិតថា ៨ ទៅ១០ម៉ោង ជាពេលដែលយើងធ្វើដើម្បីអនាគតខ្លួនឯង។

សម្រាប់អ្នកដែលគេចេះប្រើពេលវេលា ៨ ទៅ១០ម៉ោង គឺល្មមនឹងឱ្យសម្រេចតាមគោលដៅរបស់គេហើយ។ អ្នកដែលមិនចេះប្រើ នឹងរត់តាមគេមិនទាន់។ តើយើងធ្វើការយ៉ាងម៉េចកើត បើតាមអ្នកដទៃមិនទាន់ផងហ្នឹង? គេធ្វើកិច្ចការមួយចំណាយពេលតែមួយថ្ងៃ តែយើងត្រូវចំណាយពេលបីថ្ងៃ តើវាមិនចម្លែកទេឬ?

ការបែងចែកពេលវេលា ជាជំនាញមួយដែលអ្នកធ្វើការគ្រប់គ្នាត្រូវតែចេះ។ យើងមិនធ្វើការដោយមិនគិតពីពេលវេលាទេ។ ពេលវេលា មិនចេះគ្រប់គ្រាន់សម្រាប់យើងទេ បើយើងមិនដឹងថា ពេលណាត្រូវធ្វើអី ឬការងារណាត្រូវធ្វើមុន។

ក្នុងចំណុចនេះ ខ្ញុំនឹងលើកឡើងពីវិធីមួយចំនួនដែលយើងគួរចេះ ដើម្បីប្រើពេលវេលាឱ្យមានប្រយោជន៍។ ការងារដែលយើងធ្វើ ស៊ីពេលយើងរួចទៅហើយ បើយើងស៊ីពេលទៅលើរឿងយឺតយ៉ាវថែមទៀត យើងនឹងគ្មានពេលវេលាសម្រាប់ខ្លួនឯងទេ។

# ការងារធ្វើមិនចេះអស់

កន្លែងធ្វើការ គឺកន្លែងធ្វើការ។ ការងារ នឹងហូរចូលមកយើងជានិច្ច ព្រោះយើងយកលុយពីគេ ហេតុនេះគេមិនឱ្យយើងអង្គុយស្ងៀមបានលុយស្រួលទេ។

ខ្ញុំអាចនឹងអង្គុយលេងបានមួយថ្ងៃ បើសិនជាការងាររបស់ខ្ញុំ ហើយមុនពេលកំណត់ ហើយគេមិនដឹងថា ឱ្យការងារអ្វីទៀតមកខ្ញុំ។ បើសិនថា អស់ការងារធ្វើ គឺមិនអាចទេ។ អ្នកគ្រប់គ្រងរបស់ខ្ញុំ បានរៀបចំផែនការការងាររួចសម្រាប់ពេលមួយឆ្នាំ។ បុគ្គលិកដែលនៅក្រោមបង្គាប់របស់គាត់ សុទ្ធតែមានការងារធ្វើពេញមួយឆ្នាំ។ គាត់លែលកពេលវេលាដែលត្រូវធ្វើរួច ហើយយកឈ្មោះបុគ្គលិកដាក់ចូលតែម្តង។

ការងារដែលខ្ញុំត្រូវធ្វើពេញមួយឆ្នាំ គឺត្រូវការពេលពេញមួយឆ្នាំ ឬអាចលើសពីនេះ ដើម្បីធ្វើឱ្យរួច។ ខ្ញុំមិនខ្លាចអត់ការងារធ្វើទេ តែខ្លាចខ្លួនឯងធ្វើមិនទាន់។ អ្នកផ្សេងទៀតក៏ដូចខ្ញុំដែរ។ បើសិនជាការងារមិនទាន់ធ្លាក់មកដល់ គេនឹងប្រាប់ឱ្យបុគ្គលិកទៅអង្គុយរៀនអ្វីថ្មីដោយខ្លួនឯង។ មេរៀនទាំងនោះ ក៏ត្រូវរាប់បញ្ចូលជាការងារដែរ ព្រោះវាចាំបាច់សម្រាប់កិច្ចការបន្ទាប់។

ការងារមានថ្មីរហូត ឬអាចជាការងារចាស់ដែលធ្វើមិនបានល្អ។ មិនថាការងារកើនឡើងប៉ុណ្ណាទេ ពេលវេលាដែលខ្ញុំអាចធ្វើបាន គឺ ៨ទៅ១០ម៉ោងក្នុងមួយថ្ងៃដដែល។ ខ្ញុំមិនធ្វើការថែមម៉ោងទេ បើសិនជាមិនចាំបាច់ខ្លាំង ព្រោះនេះជាគោលការណ៍ដែលខ្ញុំមាន។ ការងារថែមម៉ោង ជាការធ្វើបាបខ្លួនឯង។

នៅពេលដែលការងារមានច្រើនបែបនេះ ខ្ញុំត្រូវរៀបចំវិធីធ្វើការរបស់ខ្ញុំ ដើម្បីកុំឱ្យច្របូកច្របល់។ ដោយសារខ្ញុំធ្វើការក្នុងផ្នែក E-Learning ផង និងត្រូវជួយផ្នែក Marketing ទៀត ពេលខ្លះខ្ញុំភ្លេចថាខ្លួនឯងកំពុងធ្វើអី។ វិធីដោះស្រាយតែងតែមាន និងមិនអស់លុយទៀតផង។

# ការចាត់ចែងការងារ

ក្នុងការប្រជុំក្រុមមួយ ប្រធានក្រុមរបស់ខ្ញុំ បានលើកពីការបែងចែកពេលវេលាធ្វើការឡើង ដើម្បីកុំឱ្យត្រូវគេស្ដីឱ្យ។ គាត់បានបែងចែកការងារចេញជា ៤ប្រភេទ គឺ ៖

- ការងារសំខាន់ ហើយប្រញាប់
- ការងារមិនសំខាន់ តែប្រញាប់
- ការងារសំខាន់ តែមិនប្រញាប់
- ការងារមិនសំខាន់ ហើយមិនប្រញាប់

ការងារ ៤ប្រភេទនេះ មានអាទិភាពតាមលំដាប់របស់វា។ ប្រភេទទីមួយ ជាការងារដែលត្រូវធ្វើភ្លាមៗឱ្យរួច។ ការងារប្រភេទចុងក្រោយ ជាការងារដែលអាចទុកចោលបាន ដោយមិនមានផលប៉ះពាល់។

គាត់ប្រាប់ខ្ញុំថា នៅពេលមានការងារធ្លាក់មក ត្រូវមើលថា តើវានៅក្នុងប្រភេទទីប៉ុន្មាន ហើយចាប់ផ្ដើមធ្វើការងារណាដែលមានអាទិភាពខ្ពស់មុន។ បើសិនជាអាចគួរតែទិញកូនសៀវភៅមួយក្បាល ហើយដាក់ការងារទាំងអស់ចូលទៅក្នុងនោះតាមប្រភេទរបស់វា។ យើងប្រើពេលតែ១០នាទីប៉ុណ្ណោះដើម្បីបែងចែកការងារប្រចាំថ្ងៃ។

ការងារច្របូកច្របល់ ធ្វើឱ្យយឺតយ៉ាវ ហើយអ្នកដទៃនឹងគិតថាយើងមិនចេះធ្វើការ។ ប្ដូរទម្លាប់មិនចេះបែងចែកការងារចេញ យើងនឹងអាចចំណេញពេលក្នុងការងារបានច្រើនជាងមុន។ កុំភ្លេច ការចំណេញពេលវេលា ស្មើនឹងការចំណេញជីវិត។

# ការប្រើប្រាស់ To-do List

To-do List ជាជំនួយការរបស់យើងគ្រប់គ្នា។ វាជួយឱ្យយើងដឹងខ្លួនថាត្រូវធ្វើអ្វីក្នុងថ្ងៃនេះ ហើយអ្វីដែលត្រូវរុញទៅធ្វើថ្ងៃស្អែក។ To-do List ធ្វើឱ្យការងារយើងមានរបៀប និងមិនខាតពេលធ្វើរឿងដែលមិនបានព្រៀងទុក។

To-do List ជាតារាងការងារ។ យើងអាចសរសេរវាពីយប់ក៏បាន ឬមុនពេលចាប់ផ្តើមធ្វើការក៏បាន។ របៀបធ្វើការរបស់ខ្ញុំផ្លាស់ប្តូរច្រើន ក្រោយពេលខ្ញុំប្រើ To-do List។ ពីមុន ខ្ញុំធ្វើការតាមអារម្មណ៍។ ពេលនឹកឃើញចង់យកការងារណាមកធ្វើ ខ្ញុំក៏យកមកធ្វើភ្លាម។ ខ្ញុំមិនខ្វល់ពីភាពសំខាន់របស់វាទេ ព្រោះខ្ញុំគិតថាឱ្យតែបានធ្វើគឺល្អហើយ។ តាមពិតវាមិនមែនបែបនេះទេ។ ពេលខ្លះ យើងធ្វើការ១០មុខ មិនទាន់ស្មើការងារសំខាន់តែមួយផង។

To-do List ជួយតម្រង់ផ្លូវយើងទៅរកគោលដៅក្នុងការងារ។ ខ្ញុំលើកជាឧទាហរណ៍មួយទាក់ទងនឹងការបង្កើតមេរៀនសម្រាប់ E-Learning ដែលខ្ញុំធ្វើរាល់ថ្ងៃ។ មេរៀនមួយ ត្រូវចំណាយពេលយ៉ាងហោច ២ ទៅ៣ខែ ទើបចេញជារូបរាង។ មូលហេតុដែលវាត្រូវការពេលយូរ ព្រោះក្រុមហ៊ុនរបស់ខ្ញុំមានដំណាក់កាលច្រើន ហើយត្រូវចាំម្ចាស់មេរៀនគេថា Ok សិន ទើបអាចបញ្ចេញលក់បាន។

ក្នុងរយៈពេល ២ ទៅ៣ខែនេះ To-do List របស់សុទ្ធតែផ្តោតទៅលើមេរៀនថ្មីទាំងអស់។ ការងារក្នុងប្រចាំថ្ងៃ អាចនឹងខុសគ្នា ប៉ុន្តែវារត់ប្រដេញគ្នាទៅរកគោលដៅចុងក្រោយ គឺមេរៀនថ្មីមួយសម្រាប់លក់។

ខ្ញុំត្រូវបែងចែកឱ្យច្បាស់ថា ក្នុងមួយអាទិត្យ ខ្ញុំអាចធ្វើបានប៉ុន្មានភាគរយ ហើយទើបខ្ញុំចែកវាជាការងារប្រចាំថ្ងៃ។ កិច្ចការសំខាន់ក្នុងមួយថ្ងៃ អាចមានតែបីប៉ុណ្ណោះ ហេតុនេះ ខ្ញុំមានភាគរយច្រើនដែលអាចធ្វើចប់។ To-do List មិនចាំបាច់មានកិច្ចការ២០មុខឡើងទេ ព្រោះវាមិនចាំបាច់។ យើងយកតែការងារណាដែលសំខាន់មកធ្វើប៉ុណ្ណោះ។

ចំនួនល្អបំផុតសម្រាប់ To-do list គឺ ១-៣-៥។ ការងារសំខាន់បំផុត១ ការងារមិនសូវសំខាន់៣ និងការងារមិនសំខាន់៥។ បើធ្វើបែបនេះ កិច្ចការនៅក្នុងតារាងរបស់យើង មានតែ ៩ទេ។ ឱ្យតែយើងធ្វើបាន ៤មុខខាងលើ គឺគ្រប់គ្រាន់ហើយ។ ការងារមិនសំខាន់ យើងអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។

មានកម្មវិធីទូរស័ព្ទ និងកុំព្យូទ័រ ជាច្រើនដែលអាចឱ្យយើងធ្វើជា To-do list បាន តែខ្ញុំគិតថា ទិញតែកូនសៀវភៅមួយក្បាល គឺល្អបំផុត។ ទូរស័ព្ទ អាចធ្វើឱ្យភ្លេចខ្លួន

ហេតុនេះពេលធ្វើការ កុំឧស្សាហ៍ប៉ះវាពេក។ ការដាក់កូនសៀវភៅជាប់ខ្លួន មើលទៅដូចជាចាស់គម្រិលបន្តិច តែវាបានផលជាងការកាន់ទូរស័ព្ទសម្ញែង តែធ្វើអ្វីក៏មិនសម្រេច។ សៀវភៅ To-do List របស់ខ្ញុំ តម្លៃតែ ៩០០រៀលប៉ុណ្ណោះ អាចសរសេរបាន៣ខែ។

កំណត់ការងារលើ To-do List ជារឿងងាយស្រួល តែការដាក់ចិត្ត និងប្ដេជ្ញាធ្វើឱ្យចប់ទើបជារឿងពិបាក។ អ្នកខ្លះគ្មានវិន័យក្នុងខ្លួន ហេតុនេះពួកគេបានត្រឹមតែសរសេរកិច្ចការចោលក្នុង To-do List ប៉ុណ្ណោះ។ គ្មានវិន័យ ធ្វើឱ្យការងារមិនទៅមុខ ហើយខាតពេលទៀតផង។

## ការប្រើប្រាស់ Errand List

បើយើងមាន To-do List យើងក៏ត្រូវតែមាន Errand List ដែរ។ Errand List ជាតារាងកិច្ចការតូចតាចដែលមិនចំណាយពេលយូរ ហើយមិនចាំបាច់ត្រៀមច្រើន។ យើងមិនអាចយកកិច្ចការដែលត្រូវធ្វើទាំងអស់ទៅដាក់ក្នុង To-do List បានទេ ព្រោះវារញ៉េរញ៉ៃ ហើយយើងក៏មិនអាចធ្វើវាចប់ដែរ។ Errand  List ជាកន្លែងដែលយើងដាក់កិច្ចការទាំងនោះ។

នៅក្នុង Errand List របស់ខ្ញុំ មានកិច្ចការស្រួលៗដូចជា៖

- បំពេញម៉ោងចេញម៉ោងចូល
- ងើបដើរចេញពីបន្ទប់ក្នុងមួយម៉ោងម្ដង
- ឆែកមើលអ៊ីម៉េល
- បើកមើល forum ទាក់ទងនឹង E-Learning
- អានរឿងក្នុងម៉ោងធ្វើការ
- លួច copy របៀបឌីហ្សាញរបស់អ្នកដទៃលើអ៊ីនធឺណេត

- និងច្រើនមុខទៀត

កិច្ចការទាំងនេះមិនត្រូវការពេលវេលាយូរទេ ហេតុនេះវាមិនចាំបាច់លេចមុខក្នុង To-do List របស់ខ្ញុំឡើយ។ នៅពេលខ្ញុំសម្រាកពីកិច្ចការក្នុង To-do List ឬស្មុគ្រស្មាញពេក ខ្ញុំនឹងរើសកិច្ចការណាមួយពី Errand List មកធ្វើ។ ខ្ញុំមិនទុកពេលចោល ហើយក៏មិនបង្ខំខ្លួនឯងជ្រុលពេកដែរ ចំពោះការងារ។ Errand List អាចជាការសម្រាកខួរក្បាលរបស់ខ្ញុំ។

យើងសុទ្ធតែមានកិច្ចការនៅក្នុង Errand List ប៉ុន្តែបើយើងប្រឹងធ្វើវាតែមួយមុខ យើងនឹងគ្មានពេលធ្វើកិច្ចការក្នុង To-do List របស់យើងទេ។ To-do List សំខាន់ជាង Errand List តែបើមានទាំងពីរ កាន់តែល្អ។

ដើម្បីកុំឱ្យរញ៉េរញ៉ៃ យើងអាចប្រើកម្មវិធីទូរស័ព្ទដើម្បីកត់ត្រា Errand List របស់យើងបាន។ ពេលណាទំនេរ ចាំបើកយកវាមកធ្វើ។ ខ្ញុំសូមណែនាំឱ្យប្រើកម្មវិធី Wunderlist ព្រោះវាងាយស្រួលប្រើ ហើយម្យ៉ាងអាចប្រើបានទាំងលើទូរស័ព្ទ និងកុំព្យូទ័រទៀតផង។ Wunderlist ត្រូវបាន Microsoft ទិញយកបាត់ហើយ តែគេមិនទាន់ផ្តាច់សេវាកម្មកម្មវិធីនេះទេ ដូច្នេះយើងនៅអាចប្រើបាន។

# ការនិយាយជាមួយថ្នាក់លើ

បើសិនជាអ្នកទាំងអស់គ្នាមិនដឹងថា ត្រូវបែងចែកការងាររបៀបម៉េច ឬមិនដឹងប្រើពេលវេលាឱ្យត្រឹមត្រូវយ៉ាងណា វិធីមួយទៀត គឺសួរថ្នាក់លើរបស់យើង។ ពួកគេដឹងពីគោលដៅនៃការងារច្បាស់ជាងយើង ហើយក៏មានបទពិសោធន៍ក្នុងការងារយូរជាងយើងដែរ។

យើងអាចសួរយោបល់របស់គាត់ ឬឱ្យគាត់ចាត់ការងារសម្រាប់យើងតែម្តងក៏បានដែរ ព្រោះយ៉ាងហោច គាត់ក៏ដឹងថា យើងកំពុងធ្វើអ្វីដែរ។ ពេលខ្លះ ខ្ញុំមិនដឹងថាការងារណាប្រញាប់ខ្លាំង ខ្ញុំគ្រាន់តែសួរប្រធានក្រុមខ្ញុំមួយម៉ាត់ ក៏ដឹងថាត្រូវធ្វើអ្វីបន្តហើយ។ ការងារចេញមកពីលើ បើមិនសួរថ្នាក់លើ តើយើងចង់សួរអ្នកណា?

ការនិយាយជាមួយថ្នាក់លើ អាចជួយសម្រាលការងាររបស់យើង។ ជួនកាល ការងារខ្លះលែងចាំបាច់ហើយ តែគេមិនបានប្រាប់យើង ហេតុនេះ យើងនៅតែប្រឹង ធ្វើវាបន្តទៀត។ ទម្រាំដឹងថាគេឈប់ត្រូវការ យើងខាតពេលបាត់ទៅហើយ។ ការងារ ទាំងអស់ ត្រូវតែមានគោលបំណង មិនមែនធ្វើដើម្បីតែខ្លួនឯងរវល់នោះទេ។ បើចង់ ដឹងពីគោលបំណង ត្រូវហ៊ានសួរថ្នាក់លើ។

កុំទម្លាប់បិទមាត់ ឈ្ងោកមុខធ្វើដោយមិនដឹងរឿង។ យើងមិនអាចជោគជ័យក្នុង ការងារដោយមិនដឹងខ្យល់អ្វីសោះទេ។

# ៩

# ការលាក់ និងការបញ្ចេញ

កន្លែងការងារ ជាកន្លែងបញ្ចេញសមត្ថភាព និងភាពឆ្លាតវៃ តែមិនមែនបញ្ចេញគ្រប់ពេលនោះទេ។ ការបញ្ចេញ ដោយមិនចេះគិត នឹងធ្វើឱ្យយើងក្លាយជាមនុស្សទន់ខ្សោយក្នុងភ្នែកអ្នកដទៃ ព្រោះគេដឹងពីយើងច្រើនពេក។

សមត្ថភាព និងភាពវៃឆ្លាត របស់យើងត្រូវបានគេប៉ាន់ស្មានតាំងពីពេលគេយល់ព្រមឱ្យយើងចូលធ្វើការម្ល៉េះ។ ជួនកាល គេអាចនឹងដឹងច្បាស់ជាងយើងផងក្នុងរឿងនេះ។ យើងអាចគិតថា ខ្លួនយើងឆ្លាតក្នុងកម្រិតត្រឹមនេះ តែតាមពិតយើងមិនឆ្លាតដល់អ្វីដែលយើងគិតទេ។ យើងអាចគិតថា យើងធ្វើបានប៉ុននេះ តែពេលធ្វើមែនទែន វាមិនដូចអ្វីដែលយើងគិតទេ។

នៅក្នុងរឿងសាមកុក ឆាវឆាវ មានមន្ត្រីម្នាក់ឈ្មោះថា យ៉ាងសៀវ។ យ៉ាងសៀវ អាងខ្លួនឆ្លាត ចូលចិត្តទាយពីអត្ថន័យរបស់ទង្វើឆាវឆាវនៅចំពោះមុខមន្ត្រីដទៃទៀត។ យ៉ាងសៀវ ហ៊ានឱ្យនំដែលគេយកមកថ្វាយឆាវឆាវ ទៅអ្នកបម្រើទៀតផង ព្រោះឃើញសំបុត្រសរសេរថា “ម្នាក់ញុំាមួយដុំ”។

ឆាវភី ក៏សរសើរ យ៉ាងសៀវដែរ ថាជាមនុស្សឆ្លាតណាស់ តែត្រូវស៊ីម៉ាអ៊ីនិយាយថា “ឆ្លាតបែបនេះ រស់មិនបានយូរទេ”។ ចុងក្រោយយ៉ាងសៀវ ត្រូវគេយកទៅសម្លាប់ ព្រោះប៉ាន់ស្មានខុសថា ឆាវឆាវ ចង់ដកទ័ព ហើយប្រាប់ឱ្យទាហានរៀបបង្វិចត្រលប់

ទៅក្រុងវិញ។ យ៉ាងសៀវភៅថ្មីត្បិតតែឆ្លាត តែបញ្ចេញភាពឆ្លាតខុសទំនង ហេតុនេះក៏នាំទុក្ខដល់ជីវិតខ្លួនឯង។ តើឆ្លាតបានប្រយោជន៍អី បើចុងក្រោយត្រូវស្លាប់ខ្លួនព្រោះតែភាពឆ្លាតបែបនេះ?

ឧទាហរណ៍នេះ ត្រូវនឹងយើងដែលជាខ្ញុំគេតែម្តង។ យើងមានសមត្ថភាព និងមានភាពឆ្លាតវៃ ប៉ុន្តែបើយើងបញ្ចេញដោយមិនបានគិតមុន តើលទ្ធផលនឹងទៅជាយ៉ាងណា? គេមិនសម្លាប់យើងទេ តែគេអាចស្អប់យើង ឬដេញក្បាលយើងចោល ក៏ថាបាន។

ការមិនដឹងថាពេលណាត្រូវលាក់ ពេលណាត្រូវបញ្ចេញ បានក្លាយជាអំណួតរបស់ខ្ញុំគេ។ ខ្ញុំគេមានអំណួតលើខ្លួនឯងណាស់ ព្រោះនេះជាទម្លាប់។ អំណួតនេះ ច្រើនតែប្រើចំពោះខ្ញុំគេដទៃទៀតប៉ុណ្ណោះ ព្រោះមិនហ៊ានក្អកនឹងម្ចាស់លុយ។

# ការវាស់កម្រិតភាពឆ្លាត(IQ)

សមត្ថភាព និងភាពឆ្លាតវៃ ជាអាវុធមុខពីរ។ វាអាចធ្វើឱ្យយើងបានក្តីសុខ ហើយក៏នាំរឿងមកដល់យើងផងដែរ។ សមត្ថភាពខ្ពស់ពេក ក៏មិនល្អ ហើយទាបពេក ក៏មិនត្រូវនឹងការចំណាយលុយរបស់ក្រុមហ៊ុន។ ភាពឆ្លាតរបស់យើងខ្ពស់ពេក ក៏អាចត្រូវក្រុមហ៊ុនប្រយ័ត្នចំពោះយើងវិញដែរ។

នៅក្រុមហ៊ុនដែលខ្ញុំធ្វើការ ធ្លាប់ឱ្យបុគ្គលិកធ្វើតេស IQ ដើម្បីដឹងពីបុគ្គលិកឱ្យបានច្រើន។ ខ្ញុំចូលមិនទាន់ទេ តែអ្នកដែលធ្វើហើយប្រាប់ថា ក្រុមហ៊ុនមិនបានឱ្យលទ្ធផលតេសនោះមកបុគ្គលិកមើលទេ។ ក្រុមហ៊ុន ធ្វើដើម្បីប្រយោជន៍របស់គេប៉ុណ្ណោះ។ ជាទូទៅ អ្នកដែលមាន IQ ខ្ពស់ មានសមត្ថភាពមើលឃើញ pattern នៅក្នុងបញ្ហាផ្សេង ដូច្នេះបើជួបបញ្ហា គេអាចរកវិធីដោះស្រាយបានលឿនជាង និងត្រឹមត្រូវជាងអ្នកដែលមាន IQ ទាប។ អ្នកដែលមាន IQ ទាបក៏មិនអត់ប្រយោជន៍ព្រោះមានការងារជាច្រើនដែលអ្នក IQ ទាបអាចធ្វើបាន។

ក្រុមហ៊ុនធ្វើតេសនេះ ដើម្បីងាយស្រួលក្នុងការសម្រេចចិត្តរុញបុគ្គលិកណាឱ្យឡើងធ្វើមេ។ គេមិនចង់យកមនុស្ស IQ ទាបមកធ្វើធំទេ ព្រោះ IQ កាន់តែទាប ការបើក

ចិត្តឱ្យទូលាយ ក៏កាន់តែមិនអាចទៅរួចដែរ។ បើកចិត្តមិនចេញ រៀនអ្វីថ្មីទាន់ពេល តើមានប្រយោជន៍អ្វីដែលត្រូវយកមនុស្សបែបនេះ មកធ្វើជំក្នុងក្រុមហ៊ុននោះ។ ក្រុមហ៊ុន មិនមែនទ្បប់ដូចរចនាសម្ព័ន្ធរដ្ឋាភិបាល ដែលរុញមនុស្សល្ងង់ឱ្យឡើងធ្វើធំ ហើយដាក់អ្នកចេះនៅពីក្រោមទប់ជើងអ្នកមិនចេះទេ។ ក្រុមហ៊ុនត្រូវការប្រយោជន៍ ហេតុនេះត្រូវគិតពី IQ របស់បុគ្គលិក។

បុគ្គលិកដែលចូលធ្វើការមុនខ្ញុំ មិនអាចលាក់រឿងនេះពីថៅកែធំបានទេ។ តេស IQ ដែលគេយកមកធ្វើនោះ ជាតេសអន្តរជាតិ។ ក្រុមហ៊ុនសុខចិត្តចំណាយលុយដើម្បីធ្វើតេសផ្លូវការបែបនេះ ប្រាកដជាមានបំណងអ្វីនៅថ្ងៃក្រោយហើយ។

អ្វីដែលខ្ញុំចង់បង្ហាញ គឺក្រុមហ៊ុនខ្វល់ពីសមត្ថភាព និងភាពឆ្លាតរបស់បុគ្គលិក។ យើងក៏ត្រូវខ្វល់ពីរឿងនេះដូចគ្នាដែរ។ យើងអាចបន្តអភិវឌ្ឍវាជាបន្តបន្ទាប់ តែយើងក៏ត្រូវដឹងថាពេលណាត្រូវបញ្ចេញ និងពេលណាត្រូវលាក់ដូចគ្នា។

# ពេលណាដែលត្រូវលាក់

សូមបញ្ជាក់ យើងមិនមែនលាក់រហូតទេ។ ការលាក់សមត្ថភាព ប្រៀបដូចជាការលាក់ផ្លូវទៅសុភមង្គលខ្លួនឯងដែរ។ សមត្ថភាពដែលយើងមាន អាចជួយផ្លាស់ប្ដូរជីវិតយើងបាន តែបើយើងមិនដឹងថាពេលដែលត្រូវលាក់ វាក៏មិនអាចជួយយើងបានដែរ។ ខាងក្រោមនេះ ជាកាលៈទេសៈដែលយើងគួរលាក់៖

- **នៅពេលយើងមិនទាន់ស្គាល់អ្នកដទៃច្រើន៖** យើងមិនទាន់ស្គាល់គេ គេក៏មិនទាន់ស្គាល់យើង ហេតុនេះគេគ្មានចិត្តបើកឱកាសឱ្យយើងទេ។ បើយើងបញ្ចេញសមត្ថភាពច្រើនពេក គេនឹងផ្ទប់ផ្លូវយើងភ្លាម។ ខ្មែរយើងមានវប្បធម៌ក្តិចត្រួយ ហេតុនេះត្រូវប្រយ័ត្ន។ គេមិនទាន់ទុកយើងជាគ្នាគេ ហេតុនេះគេនឹងមើលឃើញយើងជាគ្រោះក្នុងភ្នែកគេ បើសមត្ថភាពដែលយើងមាន លើសពីអ្វីដែលគេអាចធ្វើបាន។

- **នៅពេលក្រុមហ៊ុនមិនទាន់ផ្តល់ឱកាសឱ្យយើង៖** គេមិនយកយើងមកធ្វើការដោយមិនឱ្យឱកាសយើងសោះនោះទេ។ គេផ្តល់ឱកាសឱ្យ

បុគ្គលិកម្តងម្នាក់ ហេតុនេះបើសិនជាកិច្ចការណាមួយ មិនមែនដាក់ឱ្យយើងធ្វើដោយផ្ទាល់ សូមកុំបញ្ចេញច្រើនពេក។ ឱកាសអ្នកដទៃ ត្រូវទុកឱ្យអ្នកដទៃគេចាប់យក។ ឱកាសនៅក្នុងក្រុមហ៊ុន សុទ្ធតែមានម្ចាស់ ហេតុនេះដណ្តើមគ្នាក៏គ្មានបានអ្វីដែរ។ បើយើងគិតថា គេមិនផ្តល់ឱកាសឱ្យយើងទេ យើងដាក់ពាក្យឈប់ទៅ។

- <u>នៅពេលការងារនោះមិនចាំបាច់</u>៖ ពេលណាក៏យើងអាចបញ្ចេញសមត្ថភាព និងភាពឆ្លាតឱ្យគេឃើញបានដែរ ប៉ុន្តែបើវាមិនមែនជាពេលសំខាន់ផង តើយើងនឹងបានអ្វីមកវិញ? គេអាចនឹងគិតថា យើងជាមនុស្សដែលធ្វើបានតែរឿងមិនសំខាន់ ឬជាមនុស្សដែលចូលចិត្តយកមុខ។ ទម្លាប់មនុស្សចូលចិត្តយកមុខ គឺផ្តើមពីរឿងកំប៉ិកកំប៉ុកទៅ។ យើងទៅធ្វើការដើម្បីខ្លួនឯងរីកចម្រើន មិនមែនដើម្បីយកមុខទេ។ ការប្រឹងយកមុខ ជារឿងខាតពេលប៉ុណ្ណោះ បើយើងគ្មានគម្រោងធ្វើការមួយកន្លែងដល់ចាស់។ មានតែអ្នកដែលគ្មានសមត្ថភាព និងភាពឆ្លាតទេ ទើបគេប្រឹងយកមុខ ដើម្បីមានមុខនៅបន្ត។

- **នៅពេលដែលការងារមិនពាក់ព័ន្ធនឹងសមត្ថភាពយើង**៖ យើងអាចនឹងមានសមត្ថភាពច្រើន តែយើងក៏មិនបាច់បញ្ចេញដែរ។ ខ្ញុំអាចសរសេរសៀវភៅបាន តែខ្ញុំមិនដែលយកវាទៅប្រើក្នុងការងារទេ។ ពេលគេត្រូវការអ្នកសរសេរពីអ្វីមួយ ខ្ញុំមិនរវល់ ព្រោះមិនមែនជាសមត្ថភាពដែលខ្ញុំត្រូវប្រើក្នុងកន្លែងធ្វើការ។ សមត្ថភាពចេញពីមនុស្សតែម្នាក់មែន តែការប្រើខុសគ្នា។

- **នៅពេលយើងមិនពេញចិត្តនឹងជួយ**៖ យើងមិនអាចចូលចិត្តមនុស្សទាំងអស់បានទេ ហេតុនេះបើយើងមិនពេញចិត្តនឹងជួយ កុំបង្ខំខ្លួនឯង។ ជួយគេហើយ មិនសប្បាយចិត្តខ្លួនឯងដដែល តើយើងប្រឹងជួយគេធ្វើអី? ខ្ញុំជឿថា ពេលយើងមិនពេញចិត្ត យើងតែងតែមានហេតុផលផ្ទាល់ខ្លួនមិនខាន ហើយហេតុផលនោះ គឺល្មមនឹងឱ្យលាក់សមត្ថភាព

គ្រប់ពេល។ យើងជាខ្ញុំគេទេ ហេតុនេះត្រូវគិតពីខ្លួនឯងមុនសិន ចាំធ្វើអ្វីដើម្បីអ្នកដទៃ ព្រោះគេប្រហែលជាមិនដែលខ្វល់ពីយើងទេ។

ក្រោយពេលអានចំណុចនេះហើយ អ្នកទាំងអស់គ្នាអាចនឹងគិតថា ខ្ញុំមានចិត្តចង្អៀត និងមិនចេះជួយអ្នកដទៃ។ អ្នកទាំងអស់គ្នាគិតបែបនេះ គឺត្រូវហើយ ព្រោះតាំងពីតូចមក គេបង្រៀនយើងមកបែបនេះរហូត។ គេបង្រៀនយើងឱ្យធ្វើល្អនឹងអ្នកដទៃ តែមិនដែលបង្រៀនយើងឱ្យធ្វើល្អនឹងខ្លួនឯងទេ។ គេបង្រៀនឱ្យគិតប្រយោជន៍រួម តែមិនឱ្យនិយាយពីប្រយោជន៍ខ្លួនឯងទេ។ គេបង្រៀនយើងប្រឹងធ្វើអ្វីដែលយើងអាចធ្វើបាន តែមិនដែលបង្រៀនយើងឱ្យចេះរកវិធីដកខ្លួនទេ។ សង្គមទាំងមូល បង្រៀនឱ្យមនុស្សឈប់ខ្វល់ពីខ្លួនឯង ហើយចុងក្រោយ នឹងរស់នៅដើម្បីអ្នកដទៃមួយជីវិត។

**ទស្សនៈខ្ញុំគេ** មិនមែនជាសៀវភៅដែលបង្រៀនអ្នកទាំងអស់គ្នាឱ្យក្លាយជាមនុស្សល្អទេ។ សៀវភៅនេះ បង្រៀនឱ្យអ្នកដែលជាខ្ញុំគេ ភ្ញាក់ខ្លួនពីអ្វីដែលគេធ្លាប់ប្រាប់យើងកន្លងមក ហើយចេះបង្កើតផ្នត់គំនិតដោយខ្លួនឯង។ យើងធ្វើការឱ្យគេ ព្រំដែននៃការខ្វល់ និងចិត្តល្អរបស់យើង គឺមានកម្រិត។

ការលាក់សមត្ថភាព និងភាពឆ្លាត ក៏អាចធ្វើឱ្យថៅកែយើងគិតថា យើងគ្មានផ្លូវចេញទៅធ្វើការផ្សេងទៀតដែរ។ បើគាត់គិតបែបនេះ យើងនឹងដឹងថា គេធ្វើយ៉ាងណាដាក់យើងហើយ។ ពេលគេគិតថាយើងគ្មានផ្លូវដើរ គេបញ្ចេញនឹងចរិតពិតឱ្យយើងឃើញ។ ពេលឃើញហើយ យើងអាចសម្រេចថានៅបន្ត ឬចាកចេញបានហើយ។

កុំធ្វើជាខ្ញុំគេងាប់ក្រឡា ហើយខ្លាចការហក់លោត។ អ្នករកស៊ីអាចហក់លោតតាមចិត្ត ព្រោះគេមិនខ្លាចខាត យើងជាខ្ញុំគេក៏អាចហក់លោតបានដែរ បើយើងមិនខ្លាចក្នុងការរៀនអ្វីថ្មី។

# ពេលណាដែលត្រូវបញ្ចេញ

យើងដឹងពីពេលដែលត្រូវលាក់ហើយ ឥលូវយើងមកមើលថា ពេលណាដែលយើងត្រូវបញ្ចេញសមត្ថភាព និងភាពឆ្លាតរបស់យើង។

- **នៅពេលដែលយើងមានស្នាដៃច្រើនគួរសមហើយ** ៖ ស្នាដៃដែលយើងមាន ជួយឱ្យអ្នកដទៃជឿលើយើង និងបើកចិត្តទទួលយើងជាគ្នាគេ។ យើងធ្វើស្នាដៃទាំងនោះដោយមិនបញ្ចេញសមត្ថភាពខ្លាំងពេក ហេតុនេះគេមិនគិតថា យើងចូលមកដើម្បីផ្ចាញ់គេទេ។ បុគ្គលិកថ្មី ត្រូវរៀនពីបុគ្គលិកចាស់ និងចាំមើលថាពេលណាគេបើកភ្លើងខៀវឱ្យយើងចូលរួមជាមួយគេ។

  ពេលធ្វើការ ត្រូវប្រឹងបង្កើតស្នាដៃឱ្យបានច្រើន ដោយមិនចាំបាច់បញ្ចេញសមត្ថភាពលើសពីអ្វីដែលត្រូវការ ហើយមិនបាច់ធ្វើឆ្លាតពេកទេ។ ពេលមានស្នាដៃហើយ យើងអាចបញ្ចេញមកបណ្ដើរៗបានហើយ អ្នកដទៃនឹងភ្ញាក់ផ្អើល ឬពួកគេអាចនឹងគិតថា យើងមានការអភិវឌ្ឍព្រោះបានធ្វើការជាមួយគេទៀតផង។ យើងដឹងហើយថា មនុស្សចូលចិត្តយកគុណសម្បត្តិដាក់ខ្លួនណាស់ ទោះបីមិនបានធ្វើអ្វីក៏ដោយ។

- **នៅពេលដែលគ្មានអ្នកណាអាចធ្វើបាន** ៖ នេះជាឱកាសរបស់យើងដើម្បីបញ្ចេញហើយ តែកុំភ្លេចធ្វើពុតផង។ យើងអាចធ្វើដូចជានឹកឃើញដោយចៃដន្យ ឬមានអ្នកណាគេប្រាប់យើង ហើយមិនចាំបាច់ប្រឹងប្រមូលគុណសម្បត្តិដាក់ខ្លួនម្ដងហ្នឹងខ្លាំងពេកទេ។ គេដឹងថាយើងធ្វើបាន ហើយក៏មិនច្រណែននឹងយើងដែរ។

- **នៅពេលដែលក្រុមហ៊ុនផ្ដល់ឱកាសឱ្យយើង** ៖ វេនអ្នកណា ឱកាសរបស់អ្នកនោះ។ បើឱកាសមកដល់ទៅហើយ យើងត្រូវតែបញ្ចេញដើម្បីឱ្យក្រុមហ៊ុនដឹងថា សមត្ថភាពយើងក៏មានដែរ។

- **នៅមុនពេលយើងសម្រេចចិត្តឈប់**៖ យើងមិនបញ្ចេញសមត្ថភាពឱ្យគេស្ដាយយើងទេ តែកុំឱ្យគេនិយាយដើមយើងថា គ្មានសមត្ថភាពធ្វើការ។ ក្រុមហ៊ុនមិនដែលស្ដាយបុគ្គលិកទេ។ គេស្ដាយដើមទុន ស្ដាយពេលវេលា និងស្ដាយឱកាសចាប់យកទីផ្សាររបស់គេប៉ុណ្ណោះ។

ខ្ញុំគិតបែបនេះ បានជាខ្ញុំប្តូរការងារដោយគ្មានអ្វីជំពាក់ក្នុងអារម្មណ៍។ គេមិនស្តាយខ្ញុំ ខ្ញុំក៏មិនស្តាយនឹងដើរចេញដូចគ្នា។ អ្វីដែលយើងធ្វើចុងក្រោយ តែងតែជាការចងចាំរបស់អ្នកដទៃ។ ខ្លួនយើងក៏ចាំដែរ។ បទពិសោធន៍ការងារ ក្លាយជាការចងចាំ។

ខ្ញុំបញ្ចេញសមត្ថភាពម្តងបន្តិច ដើម្បីខ្ញុំប្រាកដខ្លួនឯងថា អាចធ្វើបាន និងមិនបំបាក់មុខខ្លួនឯង។ មុននឹងគេយល់ព្រមឱ្យខ្ញុំចែកពេលមកធ្វើការងារ Marketing គេសួរខ្ញុំច្រើនដងណាស់។ គេខ្លាចខ្ញុំធ្វើមិនទាន់ ហើយខ្លាចធ្វើមិនត្រូវចិត្តគេ។ ក្រោយខ្ញុំធ្វើបានម្តងមក គេក៏ចាប់ផ្តើមទុកចិត្តលើសមត្ថភាពថ្មីដែលខ្ញុំទើបនឹងបង្ហាញ ហើយរុញការងារឱ្យខ្ញុំបន្តទៀត។

# ការចែករំលែកក្នុងក្រុមការងារ

នៅមានចំណុចមួយទៀតដែលយើងត្រូវចែកឱ្យដាច់ពីការបញ្ចេញសមត្ថភាព និងភាពឆ្លាត គឺការចែករំលែកជាមួយអ្នកក្នុងក្រុម។ ការចែករំលែក ធ្វើឡើងក្នុងគោលបំណងឱ្យអ្នកដទៃចេះអ្វីដែលយើងចេះដែរ។ វាខុសគ្នាពីការបញ្ចេញ ព្រោះនោះគឺយើងគ្រាន់តែឱ្យគេឃើញថាយើងចេះតែប៉ុណ្ណឹង។

ការចែករំលែកក្នុងក្រុមការងារ ជាមធ្យោបាយមួយដែលជួយឱ្យយើងធ្វើការដោយពេញដៃស្មើគ្នា និងគ្មានការប្រណែន។ គេក៏ចេះ យើងក៏ចេះ។ បើយើងធុញនឹងអង្គុយធ្វើការជាមួយអ្នកដែលមិនចេះ ជួយបង្រៀនឱ្យគេចេះទៅ គេលែងមករំខានយើងទៀតហើយ។

កិច្ចការបន្ទាប់បន្សំរបស់ខ្ញុំ នៅក្នុងក្រុម គឺជួយគូសក្រាហ្វិចសម្រាប់អ្នកដទៃយកទៅធ្វើមេរៀន។ ខ្ញុំធុញនឹងគូសរូបដដែលៗ ហើយម្យ៉ាងខ្ញុំក៏មានមេរៀនផ្ទាល់ខ្លួនដើម្បីធ្វើដែរ។ ខ្ញុំរវល់តែជួយគេ ការងារខ្ញុំក៏យឺត ហេតុនេះខ្ញុំត្រូវរកដំណោះស្រាយ។

ខ្ញុំប្រាប់ឱ្យពួកគេតម្លើងកម្មវិធីគូសរូបម្នាក់មួយ ហើយខ្ញុំបង្រៀនរបៀបប្រើដែលចាំបាច់មួយចំនួនទៅពួកគេ។ ខ្ញុំប្រាប់ពីកន្លែងដែលអាចស្រាវជ្រាវបន្តបាន។ ប្រហែលជា២អាទិត្យ ពួកគេក៏អាចគូសបានដោយខ្លួនឯង ហើយខ្ញុំក៏លែងពិបាកទៀតដែរ។

ខ្ញុំចែករំលែកអ្វីដែលខ្ញុំចេះ ទៅអ្នកដទៃ ដូច្នេះការងារក្នុងក្រុម ក៏ទៅមុខឆាប់ជាងមុន ហើយគ្មានអ្នកណាថាខ្ញុំចង់អួតពីសមត្ថភាពខ្លួនឯងដែរ។

Allen Partridge បានសរសេរអត្ថបទមួយឱ្យវេបសាយរបស់ក្រុមហ៊ុន Adobe ដោយបានលើកឡើងពីបញ្ហានៃការចែករំលែកចំណេះដឹងក្នុងការងារ។ បើសិនជាបុគ្គលិកណាម្នាក់គិតថា “បើគេចេះអ្វីមួយតែម្នាក់ឯង ហើយអ្នកដទៃមិនអាចធ្វើបាន ក្រុមហ៊ុននឹងមិនអាចដេញគេចោលបានទេ”។ ការគិតបែបនេះ ជាការគិតចង្អៀតចង្អល់។ ការចេះពីរនាក់ ប្រសើរជាងការចេះម្នាក់ឯង ព្រោះយ៉ាងហោចណាស់ យើងមានគ្នាជជែកពីប្រធានបទដែលយើងចេះដូចគ្នា។

ខ្ញុំគាំទ្រការចែករំលែកចំណេះដឹងក្នុងការងារយ៉ាងអស់ពីចិត្ត ព្រោះនេះជាវិធីរៀនលឿនបំផុត។ បើចាំក្រុមហ៊ុនរៀបចំថ្នាក់បង្រៀន គឺយូរណាស់។ ការទ្រាំធ្វើការទាំងមិនចេះ អាចធ្វើឱ្យខ្ញុំធុញ ហើយរត់ចោលការងារ។ ពេលខ្ញុំចូលធ្វើការដំបូង គេមកបង្រៀនខ្ញុំ។ ដល់ពេលគេចង់ចេះអ្វីដែលខ្ញុំចេះស្រាប់វិញ ខ្ញុំក៏បង្រៀនគេវិញ។ ការបង្រៀនស្មើភាពគ្នាបែបនេះ អាចជួយយើងគោរពគ្នាទៅវិញទៅមក និងជៀសវាងជម្លោះអត់ប្រយោជន៍ដែលកើតពីការមិនយល់គ្នាក្នុងការងារទៀតផង។

ប្រធានក្រុមខ្ញុំ ក៏ធ្លាប់លើករឿងចែកគ្នាចេះនេះ មកនិយាយក្នុងម៉ោងប្រជុំដែរ។ ពេលមានអ្វីថ្មីទាក់ទងនឹងការងារ ឬព័ត៌មានទាក់ទងនឹងបច្ចេកវិទ្យាកំពុងប្រើ ពួកខ្ញុំនឹងចែកគ្នារៀនឱ្យទាន់ពេល។ គ្មានអ្នកណាប្រមូលចំណេះដឹងទុកម្នាក់ឯងទេ ព្រោះវាគ្មានន័យ។ បើក្រុមមួយ មានអ្នកចេះតែម្នាក់ បញ្ជាក់ថា ម្នាក់នោះ មិនចង់ឱ្យអ្នករួមក្រុមចេះដែរ។

ការចែករំលែកចំណេះដឹងនៅកន្លែងណាក៏ដោយ សុទ្ធតែជារឿងល្អទាំងអស់។ បើគេចង់ចេះ ហើយយើងក៏ចេះដែរ ហេតុអ្វីមិនជួយបង្រៀនគេផង?

# កុំភ្លេចសួរថ្នាក់លើយើងផង

ដូចខ្ញុំបានលើកឡើងពីចំណុចមុនហើយ ថ្នាក់លើរបស់យើង ដឹងរឿងច្រើនជាងយើង ហេតុនេះរាល់អ្វីដែលយើងមិនច្បាស់ យើងត្រូវតែហ៊ានសួរពួកគាត់។ មុននឹងសួរ

ចេះរើសពេលផង។ កុំឃើញគេរវល់ ឬកំពុងតែក្រពុលមុខ ហើយទៅសួរនាំច្រើនទៀត នាំតែខាតការខ្លួនឯងទេ។

ខ្ញុំធ្លាប់ណាត់ជួបអ្នកគ្រប់គ្រងផ្នែករបស់ខ្ញុំ ដើម្បីសួរថា តើពេលណាទើបខ្ញុំមានឱកាសបានបញ្ចេញស្នាដៃក្នុងក្រុមហ៊ុន? ខ្ញុំទៅនិយាយតែពីរនាក់គាត់ ហេតុនេះខ្ញុំអាចសួរបានច្រើន។ គាត់ភ្ញាក់ផ្អើលដែលខ្ញុំមកសួរគាត់បែបនេះ។ ខ្ញុំក៏ភ្ញាក់ផ្អើលដែរដែលគាត់ព្រមនិយាយជាមួយខ្ញុំ។ គាត់ឆ្លើយប្រាប់ថា ចាំមើលថាខ្ញុំអាចធ្វើការទាន់ឬអត់សិន។ បើទាន់ គាត់នឹងបន្ថែមការងារផ្សេងទៀតឱ្យ។

ក្រោយពីនោះមក ខ្ញុំក៏មានការងារក្នុងផ្នែក Marketing ធ្វើ លើរូបភាព និងវីដេអូសម្រាប់ផ្សព្វផ្សាយពីសេវាកម្មរបស់ក្រុមហ៊ុន។ ខ្ញុំពេញចិត្តនឹងការងារបែបនេះ ព្រោះវាបញ្ជាក់ថា សមត្ថភាពខ្ញុំពត្រូវបានគេមើលឃើញ ដោយមិនចាំបាច់ប្រឹងយកមុខ។ ខ្ញុំគ្រាន់តែទៅនិយាយជាមួយអ្នកគ្រប់គ្រង ខ្ញុំក៏បានឱកាសធ្វើកិច្ចការផ្សេងទៀត។

ការនិយាយជាមួយថ្នាក់លើ អាចជួយកាត់បន្ថយពេលវេលាដែលយើងអង្គុយឆ្ងល់ម្នាក់ឯងបាន។ យើងមិនបាច់ខំគិតថា ពេលណាទើបយើងអាចបញ្ចេញសមត្ថភាពបានទេ។ គេប្រាប់ថា ពេលណា គឺពេលហ្នឹងហើយ។ ភារកិច្ចរបស់យើង គឺត្រៀមខ្លួនឱ្យបានល្អប៉ុណ្ណោះ។

បុគ្គលិកខ្លះ មិនហ៊ាននិយាយជាមួយថ្នាក់លើខ្លួនឯងទេ ព្រោះខ្លាចនិយាយ ហើយនាំរឿងដាក់ខ្លួន។ ការខ្លាចបែបនេះ មិនអាចជួយយើងឱ្យរីកចម្រើនបានទេ។ យើងជាខ្ញុំគេ កុំទាន់អាលភ្លេចពីឋានៈខ្លួនឯង។ យើងត្រូវការភាពរីកចម្រើន ដើម្បីមានឱកាស ធ្វើជាខ្ញុំគេដែលមានសេរីភាពនៅពេលចាស់ទៅ។

យើងអាចនឹងយល់ខុសថា ថ្នាក់លើរបស់យើងមិនចង់ឱ្យយើងសួរច្រើនពីរឿងបែបនេះ តែតាមពិតពួកគេចង់ឱ្យយើងសួរដោយខ្លួនឯង។ ពួកគេចង់ដឹងថា យើងចេះខ្វល់ពីការរីកចម្រើនក្នុងការងាររបស់ខ្លួនឯងឬអត់។ ពួកគេចង់ដឹងថា យើងជាមនុស្សដែលចង់បានឱកាស ឬខ្លាចឱកាស។ ការសួររបស់យើង នឹងបំបាត់ចម្ងល់ទាំងសងខាង។ ពួកគេក៏ដឹងថាយើងខ្វល់ ហើយយើងក៏ដឹងថាគេត្រៀមផ្លូវឱ្យយើងដើរ ឬអត់ដែរ។

ថ្នាក់លើខ្ញុំ ជាមនុស្សស្រួលនិយាយគ្នា ហេតុនេះគ្មានអ្វីពិបាកទេ។ ពេលសួរហើយ ខ្ញុំធូរចិត្ត និងត្រៀមខ្លួនជាស្រេចសម្រាប់កិច្ចការថ្មីដែលគេព្រមដាក់ឱ្យ។ ពេលគេឱ្យខ្ញុំបានន័យថា គេចង់ឱ្យខ្ញុំបញ្ចេញសមត្ថភាពហើយ។ ខ្ញុំបញ្ចេញសមត្ថភាពតាមបញ្ជារបស់ថ្នាក់លើ ហេតុនេះគ្មានអ្នកណាហ៊ានថាអីឱ្យទេ។ ខ្ញុំធ្វើតាមគេប៉ុណ្ណោះ ហើយការងារខ្ញុំក៏ទៅមុខម្តងមួយជំហាន។ កុំប្រកាន់នឹងជំហានខ្លីៗ ព្រោះវាស្រណុកខ្លួនជាងការសម្រុកលឿនពេក។

# ១០

# ការលើកជើង នៅកន្លែងការងារ

ខ្ញុំសុំមិនប្រើពាក្យ “ទ្រពង” ឬ “លិទពង” នៅក្នុងចំណុចនេះទេ ព្រោះពាក្យនេះជាពាក្យអត់ Professional។ ការលើកជើង ឬការអែបអប បានក្លាយជាវិធីសាស្ត្រមួយដែលគេយកមកប្រើនៅតាមកន្លែងការងារ ដើម្បីសម្រេចគោលបំណង។ ការលើកជើង មានច្រើនរូបភាពណាស់ ហើយវានឹងបំបែករូបភាពបន្តទៅទៀត បើគ្មានអ្នកណាយកបញ្ហានេះមកនិយាយ។

ការលើកជើង ជាបញ្ហាមួយ ប៉ុន្តែបើវាអាចសម្រេចគោលបំណងរបស់មនុស្សបាន មនុស្សក៏មិនទុកវាជាបញ្ហាទៀតដែរ។ អ្នកខ្លះថែមទាំងបង្រៀនកូនចៅខ្លួនឯងឱ្យរៀនលើកជើងគេនៅកន្លែងធ្វើការទៀតផង។ ការបង្រៀនតគ្នាបែបនេះ នឹងរុញការលើកជើងទៅក្នុងវប្បធម៌ខ្មែរ ហើយមិនយូរទេ យើងនឹងក្លាយជាជនជាតិដែលពូកែខាងលើកជើងហើយ។

ខ្ញុំក៏ចេះលើកជើងដែរ តែខ្ញុំមិនធ្វើ ព្រោះគិតថា វាមិនចាំបាច់។ មានបុគ្គលិកជាច្រើនលើកជើងមេខ្លួនឯង ដើម្បីទទួលបានការចូលចិត្ត និងការទុកចិត្ត។ ខ្ញុំមិនជឿថា ការទុកចិត្ត អាចបានមកពីការលើកជើងទេ តែនេះជាយល់ឃើញរបស់ពួកគេ។ ប៉ុន្តែការចូលចិត្តវិញ គឺច្បាស់ណាស់។ អ្នកដែលចេះអែបអប ឬប្រើពាក្យសមរម្យថា “យល់

ចិត្តមេ” តែងតែក្លាយជាជំនិត ឬបុគ្គលិកដែលមានឱកាសច្រើនជាងគេ។ អ្នកខ្លះអែបអបរហូតដល់បានធ្វើកូនប្រសារថៅកែ ឬប្រពន្ធលួចលាក់ទៀតផង។

ការលើកជើង អាចកើតមានចំពោះមនុស្សគ្រប់គ្នា មិនថាអ្នកនោះមានគោលដៅច្បាស់ ឬរស់តាមគេទេ។ គោលដៅខ្លះធំពេក ដូច្នេះត្រូវការឱ្យមនុស្សលះបង់ភាពថ្លៃថ្នូរ និងការតាំងចិត្ត ហើយងាកទៅចាប់ការលើកជើងវិញ។ ការលើកជើងមួយចំនួន អាចកើតឡើងដោយមិនដឹងខ្លួន។ អ្នកខ្លះលើកជើងគេអស់ចិត្តហើយ តែបែរជាមិនទទួលស្គាល់ថាខ្លួនឯងបានធ្វើទៀត។

ខ្ញុំផ្លាស់ប្តូរកន្លែងធ្វើការប៉ុន្មានដង ក៏នៅតែជួបមនុស្សលើកជើង។ មិត្តភក្តិក៏តែងរអ៊ូប្រាប់ខ្ញុំពីអ្នកលើកជើងដែលធ្វើការជាមួយពួកគេ។ បើការងាររដ្ឋវិញ រឹតតែសម្បូរមនុស្សប្រភេទនេះ ព្រោះវាជាទម្លាប់។ ពួកគេយល់ថា ការលើកជើង ជាការគោរពដល់ថ្នាក់លើ ឬបុគ្គលិកចាស់ៗ។ ការយល់បែបនេះ រុញឱ្យអ្នកដែលមិនចេះលើកជើង គ្មានឱកាសបញ្ចេញស្នាដៃលើរឿងចាំបាច់ ហើយចុងក្រោយ រដ្ឋក៏ធ្វើការមិនបានមួយចំណិតក្រុមហ៊ុនឯកជនទៅ។

ក្នុងចំណុចនេះ ខ្ញុំគ្រាន់តែយកការលើកជើងនៅកន្លែងធ្វើការ មកឱ្យអ្នកទាំងអស់គ្នាគិតប៉ុណ្ណោះ។ ខ្ញុំមិនបង្ខំឱ្យលើកជើង ឬមិនលើកជើងទេ។ ជម្រើសស្ថិតលើការសម្រេចចិត្តក្រោយពេលអានចប់។

# ការលើកជើងក្នុងសៀវភៅ

តើអ្នកទាំងអស់គ្នាធ្លាប់ឆ្ងល់ដែរទេថា ហេតុអីសៀវភៅដែលនិយាយពីគន្លឹះជោគជ័យជាច្រើន មិនដាក់បញ្ចូលការលើកជើងក្នុងនោះ? តើការលើកជើង មិនមែនអាចជួយមនុស្សឱ្យជោគជ័យទេឬ?

សៀវភៅដែលព្យាយាមផ្តោតលើតែរឿងល្អខ្លាំងពេក អាចធ្វើឱ្យបាត់ការពិតដែលអ្នកអានត្រូវដឹង។ ភាពវិជ្ជមានរបស់អ្នកនិពន្ធមានតម្លៃណាស់ ប៉ុន្តែបើភាពវិជ្ជមានទាំងនោះជារឿងមិនពិត ឬមិនអាចកើតឡើងក្នុងពេលបច្ចុប្បន្ន វាក៏គ្មានន័យអ្វីដែរ។

អតីតអ្នកគ្រប់គ្រងខ្ញុំម្នាក់ បានអានសៀវភៅរបស់ខ្ញុំហើយ គិតថា សៀវភៅខ្ញុំមានចំណុចអវិជ្ជមានច្រើន។ គាត់សរសេរដៀមដាមឱ្យខ្ញុំនៅលើអ៊ីនធឺណេត ហើយយកសៀវភៅរបស់ខ្ញុំទៅប្រៀបធៀបនឹងអ្នកនិពន្ធផ្សេងទៀត។ គាត់នៅនិយាយថា សៀវភៅខ្ញុំសរសេររបៀបនេះ ទើបខ្ញុំលក់ក្នុងតម្លៃ ១ដុល្លារ។ គាត់សរសើរសៀវភៅរបស់មានគំនិតវិជ្ជមានច្រើន គ្រាន់តែឃើញគឺចង់អានបន្ត។

ការដៀមដាមរបស់គាត់នេះ ធ្វើឱ្យខ្ញុំភ្ញាក់ខ្លួន។ ខ្ញុំសួរខ្លួនឯងថា តើនេះអាចជាទំនោរនៃការអានសៀវភៅរបស់ខ្មែរយើងដែរទេ? តើនេះអាចជាមូលហេតុដែលរោងពុម្ពក្នុងស្រុក បោះពុម្ពតែសៀវភៅក្នុងប្រភេទស្រដៀងគ្នាដែរទេ? មនុស្សរៀនចេះលើកជើងអ្នកដទៃ ហើយត្រូវការអ្នកដទៃលើកជើងវិញ។ ពួកគេត្រូវការការលើកជើងគ្រប់ពេលដើម្បីឱ្យខ្លួនឯងយល់ថា ជីវិតរបស់ខ្លួនមានភាពល្អប្រសើរ ហើយមានវាសនាក្លាយជាមនុស្សជោគជ័យ។ ពួកគេហៅសៀវភៅដែលសរសេរលើកជើងថា “សៀវភៅលើកទឹកចិត្ត”។

អ្នកដែលអានសៀវភៅលើកទឹកចិត្ត ច្រើនតែជាមនុស្សខ្ជិលដែលមិនចង់ធ្វើអ្វី ហើយយកការអានមកធ្វើជាលេសដើម្បីកុំឱ្យហត់នឹងគិតរកវិធីធ្វើ។ ពួកគេ លើកទឹកចិត្តខ្លួនឯង ទាល់តែខ្ជិល ហើយទៅរកទិញសៀវភៅថ្មីទៀតមកអាន។ អ្នកអានបែបនេះជាម៉ូយដែលរោងពុម្ពចូលចិត្ត។

រោងពុម្ព បោះពុម្ពសៀវភៅបែបនេះ ដើម្បីទាក់ចិត្តអ្នកអានឱ្យទិញសៀវភៅក្រោយៗទៀត។ សៀវភៅទាំងនោះគ្រាន់តែធ្វើឱ្យអ្នកអានសប្បាយចិត្ត ឬបានធូរចិត្តមួយពេលប៉ុណ្ណោះ តែលទ្ធផលរយៈពេលវែង និងការផ្លាស់ប្តូរ ប្រហែលជាមិនមានទេ។ ឱ្យតែហ៊ានលើកទឹកចិត្តជ្រុលបន្តិច វានឹងក្លាយជាការលើកជើងភ្លាម។

សៀវភៅប្រភេទនេះ ទទួលបានភាពជោគជ័យខ្លាំងណាស់ ព្រោះមានការនិយមច្រើន។ ពីមុន ខ្ញុំក៏ចូលចិត្តអានសៀវភៅប្រភេទនោះដែរ ព្រោះខ្ញុំគិតថា វាជួយឱ្យខ្ញុំមានចិត្តប្រឹងប្រែង។ ក្រោយមក ខ្ញុំយល់ថា ខ្ញុំអានដើម្បីពង្រីកចំណេះដឹង និងការគិតរបស់ខ្ញុំ មិនមែនអានដើម្បីធូរចិត្តទេ។ បើចង់ធូរចិត្ត ខ្ញុំទៅឱ្យគេបោកក្នុងផ្លូវ

សាសនាបាត់ហើយ។ គេប្រាប់ខ្ញុំថាមានជាតិក្រោយទៀត ដូច្នេះជាតិនេះខ្ញុំមិនបាច់ប្រឹងធ្វើអីទេ ទុកពេលធ្វើ To-do list សម្រាប់ជាតិក្រោយតែម្ដង។

ការលើកជើងមានប្រសិទ្ធិភាពណាស់ សូម្បីតែអាជីវកម្មសៀវភៅ ឬអ្នកនិពន្ធ ក៏រៀនយកវិធីនេះមកប្រើជាមួយអ្នកអានដែរ។ ការលើកជើង ធ្វើឱ្យអ្នកដទៃមានអារម្មណ៍ល្អចំពោះខ្លួនឯង តែមិនបានបន្ថែមតម្លៃអ្វីឱ្យអ្នកដទៃទេ។ ការលើកជើង ជាការជួយក្លែងក្លាយ។

ខ្ញុំធ្លាប់សរសេរសៀវភៅលើកជើងមួយក្បាល ដែលខ្ញុំយកគោលគំនិតពីសៀវភៅរបស់ លោកឧកញ៉ា គួច ម៉េងលី។ ខ្លឹមសារភាគច្រើន គឺលើកជើងអ្នកអានឱ្យគិតថាខ្លួនឯងអស្ចារ្យ ដោយមិនចាំបាច់ធ្វើអ្វី។ ខ្ញុំសរសេរបែបនេះ ដើម្បីឱ្យវាស្របគ្នានឹងគោលគំនិតរបស់ម្ចាស់ដើម និងដើម្បីឱ្យគាត់ឃើញថា សៀវភៅដែលខ្ញុំសរសេរ មានភាពវិជ្ជមានច្រើនប៉ុណ្ណោះ។ កាលនោះ ខ្ញុំរំពឹងលើការបោះពុម្ពផ្សាយ និងដាក់លក់ដោយមានអ្នកណាម្នាក់នៅពីក្រោយខ្នង។ ខ្ញុំយកការលើកជើងមកប្រើ ព្រោះក្រោយពេលជួបនិយាយផ្ទាល់ជាមួយគាត់ប៉ុន្មានដងមក ខ្ញុំឃើញថា ជាមនុស្សចូលចិត្តគេសរសើរ។

តែវាមិនដូចខ្ញុំគិតទេ ព្រោះសៀវភៅនោះមិនបានបោះពុម្ពជាមួយរោងពុម្ពគាត់។ ខ្ញុំក៏យកសៀវភៅនោះមកសរសេរឡើងវិញបន្តិច ហើយលក់ឱ្យរោងពុម្ពដាំដើមជីវិតទៅ។ បងប្រាជ្ញ វិជ័យមើលហើយ ថាល្អណាស់ ស្រដៀងគ្នានឹងសៀវភៅរបស់គាត់។ ខ្ញុំក៏មិននិយាយអ្វីដែរ ព្រោះខ្ញុំដឹងពីខ្លឹមសារខាងក្នុងច្បាស់ហើយ។

ចាប់ពីសៀវភៅនោះមក ខ្ញុំលែងសរសេរលើកជើងអ្នកណាទាំងអស់។ ខ្ញុំបកមកសរសេររែកញែកអ្វីដែលខ្ញុំមើលឃើញ ហើយភាគច្រើន មានភាពអវិជ្ជមានបង្កប់ក្នុងនោះ។ សូមកុំច្រឡំ ខ្ញុំជាមនុស្សវិជ្ជមាន ដែលមើលឃើញភាពអវិជ្ជមាន ហើយយករឿងទាំងនោះមកសរសេរ។ ខ្ញុំមិនបោកខ្លួនឯងថា គ្រប់យ៉ាងជារឿងវិជ្ជមាន ឬបញ្ហាទាំងអស់សុទ្ធតែជាឱកាសទេ។ ខ្ញុំសរសេរតាមអ្វីដែលខ្ញុំយល់ថា ជាការពិត។ អ្នកអានដែលអាចទទួលបាន មិនប្រកាន់នឹងខ្ញុំទេ តែពួកគេនឹងទៅរកមើលរឿងអវិជ្ជមានទាំងនោះដោយខ្លួនឯង។

សម្រាប់អ្នកនិពន្ធ ត្រូវប្រយ័ត្ននៅពេលសរសេរ ព្រោះការលើកជើងនេះ អាចកើតឡើងដោយចៃដន្យ ពេលយើងព្យាយាមប្រើពាក្យលើកទឹកចិត្តអ្នកអានខ្លាំងពេក។ ខ្ញុំប្រយ័ត្នចំណុចនេះ ព្រោះខ្ញុំធ្លាប់ធ្វើម្ដង ហើយដូចជាអៀនដៃខ្លួនឯង។ ខ្ញុំពេញចិត្តសរសេរសៀវភៅដែលត្រូវនឹងចរិតខ្លួនឯង គ្រាន់បើជាងលើកជើងអ្នកអានដើម្បីឱ្យគេគាំទ្រ។

# ភាពជោគជ័យដែលបានមកពីការលើកជើង

បើគ្មានអ្នកណាធ្លាប់ប្រាប់អ្នកទាំងអស់គ្នាទេ ចាំខ្ញុំប្រាប់ **ភាពជោគជ័យបានពីការលើកជើង ជារឿងពិត**។ មានមនុស្សជាច្រើនលើកជើងបានសម្រេច ហើយទទួលបានលាភច្រើនជាងអ្នកដែលប្រឹងធ្វើការ និងអ្នកមានជំនាញច្បាស់ទៀត។ ភាពជោគជ័យរបស់មនុស្សលើកជើង អាចនឹងបិទផ្លូវរបស់អ្នកដែលមិនចេះលើកជើង។

កាលខ្ញុំធ្វើការក្នុងក្រុមហ៊ុន E-Commerce មានបុគ្គលិកម្នាក់ត្រូវជាមិត្តភក្ដិរបស់ប្អូនម្ចាស់ក្រុមហ៊ុន។ ម្នាក់នេះ មិនមានជំនាញអ្វីច្បាស់ទេ តែអាចធ្វើការបាន។ អ្វីដែលគួរឱ្យខ្លាច គឺការលើកជើង និងយកមុខ។ ឱ្យតែមេមានគំនិតអី ម្នាក់នេះយល់ស្របទាំងអស់ ហើយជួយរកហេតុផលឱ្យគំនិតរបស់មេ សមហេតុផលទៀត។ ដោយសារតែបែបនេះ ម្នាក់នេះត្រូវបានមេចូលចិត្ត និងផ្ដល់សិទ្ធិឱ្យធ្វើរឿងជាច្រើនក្នុងក្រុមហ៊ុន។ កិច្ចការដែលម្នាក់ចូលចិត្តធ្វើ គឺដើរមើលការងារគេ ហើយបញ្ចេញយោបល់ មានពេលខ្លះ ស្ដីឱ្យគេទៀតផង។

ការលើកជើង បានធ្វើឱ្យម្នាក់នេះ រីកចម្រើនជាងបុគ្គលិកដទៃ។ ម្នាក់នេះប្រឹងធ្វើការតែនៅចំពោះមុខមេប៉ុណ្ណោះ។ គេសួរខ្ញុំពីការងាររហូត ឱ្យតែមានមេនៅជាមួយ តែបើគ្មានមេវិញ គេនិយាយរឿងផ្សេង ពេលខ្លះ យករូបសិចមកឱ្យខ្ញុំមើលទៀតផង។ ខ្ញុំមិនភ្ញាក់ផ្អើលនឹងចរិតបែបនេះទេ ព្រោះខ្ញុំដឹងថា គេមានបំណងរបស់គេ។ គេក៏ចង់បានភាពជោគជ័យក្នុងការងារដូចខ្ញុំដែរ គ្រាន់តែវិធីដែលគេប្រើ ខុសគ្នាពីខ្ញុំ។

អ្នកដែលចេះលើកជើង ធ្វើគ្រប់យ៉ាងដើម្បីផ្គាប់ចិត្តមេ។ ពួកគេមិនខ្វល់ថា កិច្ចការនោះអាចប៉ះពាល់ដល់ក្រុមហ៊ុនឬអត់ទេ សំខាន់មេពេញចិត្ត។ បើកិច្ចការនោះ មាន

លទ្ធផលមិនល្អ ក៏គ្មានអ្នកណាទៅបន្ទោសគេដែរ ព្រោះចាំតែស្របតាមមេប៉ុណ្ណោះ។ អ្នកដែលចេះលើកជើង យករួចខ្លួនបានគ្រប់ពេល ដូច្នេះបើសិនជាមានបញ្ហាជាមួយមនុស្សប្រភេទនេះ ត្រូវរកជំនួយ ឬត្រៀមផ្លូវក្រោយដើរឱ្យហើយ។

ភាពជោគជ័យរបស់ពួកគេ រួមមាន ថៅកែពេញចិត្ត រក្សាការងារបានយូរ មានគ្រួសារមុនអ្នកដទៃ និងមិនចាំបាច់មានសញ្ញាបត្រធំពេកទេ។ ភាពជោគជ័យរបស់ពួកគេមើលទៅដូចជាធម្មតា ប៉ុន្តែអ្នកប្រឹងធ្វើល្មមៗមិនអាចប្រៀបបានឡើយ។

នៅពេលអ្នកទាំងអស់គ្នាទៅធ្វើការកន្លែងណា ត្រូវចោលភ្នែករកមនុស្សដែលពូកែលើកជើងប្រចាំក្រុមហ៊ុន។ បើរកមិនឃើញទេក៏មិនអីដែរ ព្រោះមិនយូរទេនឹងមានគេនិយាយប្រាប់ហើយ។ មនុស្សលើកជើង មិនសូវមានអ្នកណាចូលចិត្តទេ ព្រោះគេច្រណែននឹងភាពជោគជ័យដែលបានមកដោយមិនសមរម្យ។ រៀនសម្គាល់អ្វីដែលគេធ្វើចំពោះអ្នកដទៃ ព្រោះមិនយូរទេ គេនឹងយកប្រយោជន៍ពីយើងទៅផ្គាប់ចិត្តថៅកែទៀតហើយ។ មនុស្សលើកជើង ចាំតែទទួលយកផលប៉ុណ្ណោះ។ ពេលណាគេបានផលក្នុងដៃហើយ ភាពជោគជ័យនឹងរត់រកគេយ៉ាងងាយ។

កត្តានៃភាពជោគជ័យក្នុងការងារមានច្រើនណាស់ តែក្នុងនោះ ការលើកជើង ជារឿងមួយដែលគួរឱ្យចាប់អារម្មណ៍ជាងគេ។ បើអ្នកទាំងអស់គ្នាគិតដូចខ្ញុំ ថាមិនចង់ធ្វើកន្លែងដដែលច្រើនឆ្នាំ ការលើកជើង ជារឿងមិនចាំបាច់ទេ។

# ការលើកជើង មិនមែនជាការងារទេ

ទោះបីជាការលើកជើង ត្រូវបានគេប្រើនៅក្នុងការងារគ្រប់ប្រភេទក៏ដោយ ប៉ុន្តែវាមិនមែនជាការងារទេ។ វាក៏មិនមែនជាផ្នែកនៃការងារដែរ។ វាជាវិធីសាស្ត្រធ្វើការរបស់បុគ្គលរៀងខ្លួន។ អ្នកដែលគេចេះគិតត្រឹមត្រូវ និងមានសមត្ថភាព ធ្វើការដោយមិនខ្វល់ពីការលើកជើងទេ។ គេជឿលើសមត្ថភាពរបស់គេ។ អ្នកដែលមិនចេះ ឬចេះស្ទើរហើយខ្ជិល តែងតែយកការលើកជើងមកធ្វើជាជំនួយជានិច្ច។ គ្មានអ្នកណាប្រកាសរើសបុគ្គលិកផ្នែកលើកជើងទេ។

ខ្ញុំនៅចាំការលើកជើងមួយរបស់អ្នកធ្វើការជាមួយខ្ញុំ។ ពេលនោះក្រុមហ៊ុនរបស់ខ្ញុំសម្រេចបើកសាលាបង្រៀនកុំព្យូទ័រ។ គេបានឱ្យខ្ញុំទៅធ្វើជាអ្នកបង្រៀនផ្នែកក្រាហ្វិចឌីហ្សាញ។ ខ្ញុំបង្រៀនបានប្រហែលជាពីរខែ ស្រាប់តែមេខាងលើ ប្រាប់ថា ចង់បិទថ្នាក់ចុងសប្តាហ៍ចោល ព្រោះមិនសូវមានសិស្សមករៀន និងសិស្សរៀនមិនចេះ។ ម្នាក់ដែលពូកែលើកជើងនោះ ក៏ចូលមកបញ្ចេញមតិគាំទ្រភ្លាម។ ម្នាក់នោះមិនដែលចូលបង្រៀនទេ តែគេលើកហេតុផលបានច្រើនជាងខ្ញុំដែលជាអ្នកបង្រៀនទៀត។

ចុងក្រោយ ថ្នាក់ចុងសប្តាហ៍របស់ខ្ញុំ ក៏ត្រូវគេបិទ ហើយខ្ញុំមិនពេញចិត្តក៏ដាក់ពាក្យឈប់។ ការងារដែលខ្ញុំត្រូវធ្វើ គឺបង្រៀន ហេតុនេះបើទាក់ទងនឹងការងារ គេគួរតែមកសួរខ្ញុំ មិនមែនសួរអ្នកដែលមិនធ្វើការទេ។ ការលើកជើង មិនពាក់ព័ន្ធនឹងការងារទេ។

ខ្ញុំមិនដែលចង់ធ្វើជាមនុស្សលើកជើងទេ ហេតុនេះអ្វីដែលខ្ញុំរៀនដើម្បីមានការងារធ្វើ សុទ្ធតែជាជំនាញដែលកំពុងមានតម្រូវការលើទីផ្សារ។ ខ្ញុំរៀនជំនាញថ្មីរាល់ឆ្នាំ ព្រោះចង់តេសសមត្ថភាពខ្លួនឯងផង និងការពារខ្លួនកុំឱ្យក្លាយជាអ្នកលើកជើងគេដើម្បីបានលុយចាយផង។

ដោយសារតែកម្មវិធីសិក្សារបស់ខ្មែរយើង មិនទាន់មានការផ្លាស់ប្តូរ ការរកការងារធ្វើ និងចំណេះដឹងសិស្សនិស្សិតទាក់ទងនឹងការងារ ក៏មានកម្រិត យើងមានឱកាសរកការងារល្អបានធ្វើច្រើនណាស់។ ការងារល្អ សំដៅលើការងារដែលអាចជួយបណ្តុះបណ្តាលយើងបន្ថែម ហើយបានលុយចាយគ្រប់គ្រាន់។ ការងារល្អ ឱ្យតែមានជំនាញច្បាស់លាស់ គឺអាចរកបានហើយ។ កុំរំពឹងលើការលើកជើង។

បើយើងឱ្យនិយមន័យការងារ ជាតម្លៃរបស់មនុស្ស យើងមិនអាចយកការលើកជើងមកលាយឡំបានទេ។ ការលើកជើង ជាការបំបាក់មុខខ្លួនឯង និងធ្វើឱ្យអ្នកដទៃមើលមិនឃើញតម្លៃរបស់យើង។ ហេតុនេះហើយ ទើបអ្នកដែលលើកជើងគេបានសម្រេច ប្រឹងបង្កើតរឿងផ្សេងៗដើម្បីកុហកគេថាខ្លួនឯងប្រឹងធ្វើការដោយសមត្ថភាពពិត។ គ្មានអ្នកណាហ៊ានប្រាប់គេថា “ខ្លួនឯងលើកជើងគេរាល់ថ្ងៃ ទើបមានការងារធ្វើ” ទេ ព្រោះវាជារឿងអាម៉ាស។ កុំឃើញអ្នកដែលពូកែលើកជើង ធ្វើ

ឬកដូចជាមិនខ្វល់ តាមពិតពួកគេក៏ខ្មាសខ្លួនឯងដែរ តែមិនដឹងធ្វើយ៉ាងណា បើមិនចេះអ្វីសោះ ហើយខ្ជិលទៀត។

ខ្ញុំគេ ជាការបាត់បង់តម្លៃមួយផ្នែកទៅហើយ បើសិនជាយើងលើកជើងនៅក្នុងការងារ តម្លៃយើងនឹងបាត់បង់កាន់តែច្រើន។ ការបាត់តម្លៃ ធ្វើឱ្យយើងរស់នៅមិនពេញលេញ។ បើគ្មានសមត្ថភាពធ្វើការ កុំធ្វើ ដេកផ្ទះទៅ។ បើគ្មានសមត្ថភាព ហើយចង់ធ្វើការ ត្រូវរកកន្លែងរៀន។ កុំនៅស្ងៀម ទ្រាំល្ងង់ក្នុងសម័យអ៊ីនធឺណេត។ ប្រឹងពីមិនចេះ ទៅជាចេះ ល្អជាងធ្វើការលើកជើងគេ។

# អ្នកលើកជើងគេ មិនមែនជាមនុស្សឆ្លាតទេ

យើងអាចនឹងច្រលំថា អ្នកដែលលើកជើងគេជាមនុស្សឆ្លាត។ ពួកគេមិនអាចឆ្លាតបានទេ ព្រោះគេអាចរកវិធីយកចិត្តចៅហ្វាយបាន ហើយបោកអ្នកដទៃឱ្យជួយធ្វើការ ដើម្បីគេយកមុខបានទៀត។ ពួកគេអាចនឹងមាន ភាពឆ្លាតខាងអារម្មណ៍ (EQ) ខ្ពស់ជាងយើងផងក៏ថាបាន។ ពួកគេចេះស្វែងយល់ពីមនុស្ស ហើយពូកែប្រើពាក្យល្បួងលោមអ្នកដទៃ។

ពួកគេមិនឆ្លាតទេ តែល្ងង់។ ពួកគេមិនចេះអ្វីមួយដែលការងារទាមទារឱ្យធ្វើ ហេតុនេះទើបប្រឹងលើកជើង ដើម្បីយករួចខ្លួន ដោយមិនបាត់ការងារ។ មូលហេតុដែលពួកគេល្ងង់ គឺមកពីខ្ជិល។ គេយល់ថា ភាពជោគជ័យ អាចមានផ្លូវកាត់ និងមិនចាំបាច់អង្គុយចាំយូរដូចអ្នកដទៃទៀត។ ភាពឆ្លាតដែលពួកគេមាន ពង្វក់គេឱ្យដើរលើផ្លូវផ្សេងពីអ្នកដទៃ។ ពេលដែលគេបានជោគជ័យបណ្ដើរៗ គេនឹងគិតថា អ្វីដែលគេធ្វើជារឿងត្រឹមត្រូវ ហើយក៏កាន់តែខ្ជិលជាងមុនទៀត។

ពួកគេមានភាពឆ្លាត តែគ្មានចំណេះដឹង ដូច្នេះភាពឆ្លាតរបស់គេ ប្រើយូរទៅ ក៏អស់។ ឆ្លាត តែមិនរៀន មិនអាចជួយមនុស្សឱ្យឆ្លងផុតសម័យបច្ចេកវិទ្យាទេ។

អ្នកដែលលើកជើងគេ អាចឈប់ធ្វើបែបនោះបាន ដរាបណាគេលះបង់ទម្លាប់ខ្ជិល ហើយប្រឹងរៀនអ្វីមួយឱ្យចេះ។ នៅពេលគេចេះហើយ គេក៏មិនចាំបាច់លើកជើងអ្នកណាទៀតដែរ។ មនុស្សដែលចេះច្បាស់ ជឿលើសមត្ថភាពខ្លួនឯង ហើយជឿថា

អ្នកដទៃត្រូវការសមត្ថភាពនោះ។ ពួកគេអាចមានអំណួតបន្តិច តែវាជាអំណួតដែលអាចចេញជាលទ្ធផល។ ពេលដែលយើងឈប់លូង់ យើងនឹងមើលឃើញផ្លូវដើរផ្សេងទៀត។ បើរួមផ្សំនឹងមនុស្សឆ្លាតផង អ្វីដែលយើងរៀនចេះ កាន់តែមានតម្លៃ។ អ្នកខ្លះរៀនចេះ តែមិនសូវឆ្លាត ដូច្នេះពួកគេក៏ពិបាកនឹងធ្វើឱ្យខ្លួនឯងរីកចម្រើនដែរ។

បើសិនជាអ្នកទាំងអស់គ្នា មើលឃើញថាខ្លួនឯងពូកែលើកជើងគេ ហើយចង់ឈប់ ខ្ញុំមានវិធីមួយ។ ចុះឈ្មោះរៀនជំនាញនៅលើអ៊ីនធឺណេត ឬរៀនអ្វីដែលមាន free លើ Youtube ក៏បានដែរ ហើយប្រឹងរៀនឱ្យចេះ។ ក្នុងរយៈពេល ៣ខែ ទៅ៦ខែ យើងនឹងអាចធ្វើការដោយខ្លួនឯងបានហើយ។ យើងក៏មិនបាច់លើកជើងអ្នកណានៅកន្លែងធ្វើការទៀតដែរ។

បើសិនជាក្នុងពេល៥ឆ្នាំ យើងនៅតែបន្តរៀនបែបនេះទៀត យើងអាចក្លាយជាអ្នកជំនាញក្នុងផ្នែកណាមួយមិនខាន។ ពេលនោះ យើងនឹងឃើញអ្នកដទៃមកលើកជើងយើង ដើម្បីឱ្យយើងជួយធ្វើកិច្ចការឱ្យគេ។ ជោគជ័យពិតប្រាកដ កើតឡើងពេលអ្នកដទៃមកលើកជើងយើង មិនមែនយើងជាអ្នកលើកជើងគេទេ។

បើយើងនៅតែលើកជើងគេ យើងនៅតែមិនទាន់ស្គាល់ភាពជោគជ័យ។ បើថ្ងៃណាមួយគេធុញនឹងការលើកជើង យើងប្រាកដជាអត់ផ្លូវដើរ ឬត្រូវទៅកន្លែងផ្សេងហើយចាប់ផ្ដើមលើកជើងពីដំបូងទៅទៀត។ ការលើកជើងគេ មិនមែនជាកំហុសធ្ងន់ពេកទេ ដូច្នេះបើយើងមានខ្លួនដែរ សូមបកក្រោយឱ្យបានលឿនបំផុត។

# ថៅកែដែលចូលចិត្តការលើកជើង

ថៅកែណាក៏ចូលចិត្តគេសរសើរ និងយល់ស្របតាមគំនិតខ្លួនដែរ ប៉ុន្តែថៅកែដែលចូលចិត្តតែការលើកជើង ហើយស្អប់អ្នកដែលនិយាយត្រង់ ជាមនុស្សដែលមិនស្គាល់ខុសត្រូវ។ ការចូលចិត្តជារឿងផ្សេង ការយកពាក្យសរសើរមកបាំងភ្នែកជារឿងផ្សេងមួយទៀត។

ខ្ញុំចាំថា ពាក្យចុងក្រោយដែលខ្ញុំនិយាយទៅកាន់ប្រធានក្រុមហ៊ុនចាស់របស់ខ្ញុំ គឺគាត់ចូលចិត្តតែបុគ្គលិកអែបអប ដូច្នេះទើបបុគ្គលិកមិនចេះអែបអបចេញពីគាត់

អស់។ ខ្ញុំនិយាយដោយខឹង តែមានបង្កប់ការពិត។ គាត់ពិតជាចូលចិត្តឱ្យគេអែបអប មែន។ បើអ្នកណាជំទាស់គំនិតគាត់ គាត់មិនសប្បាយចិត្ត ហើយមិនធ្វើតាមគេទៀតផង។

សម្រាប់ខ្ញុំ ថៅកែ គួរតែផ្តោតតែលើប្រាក់ចំណេញ និងឱកាសទីផ្សារ មិនមែនផ្តោតលើអ្នកណាសរសើរខ្លួនឯងទេ។ ក្រុមហ៊ុន អាចបន្តអាយុបាន ដោយសារលុយ និងមានមនុស្សជួយ មិនមែនដោយសារការអែបអប និងអារម្មណ៍ល្អរបស់ថៅកែទេ។ ដូច្នេះបើមានអ្នកណាលើកឡើងពីគំនិតល្អ ឬជួយបដិសេធគំនិតមិនល្អរបស់ខ្លួន ថៅកែ គួរតែយកទៅគិត មិនមែនវែកញែកតាមការខឹងទេ។

ពេលដែលខ្ញុំដឹងថា ថៅកែខ្ញុំជាអ្នកចូលចិត្តការអែបអប ខ្ញុំត្រៀមខ្លួនឈប់ឱ្យហើយ។ ខ្ញុំចេះធ្វើការជាមួយមនុស្សលើកជើង តែមិនចូលចិត្ត ដូច្នេះ ខ្ញុំមិនទ្រាំធ្វើការឱ្យហត់ចិត្តខ្ញុំទេ។ ខ្ញុំអាចរកការងារថ្មីធ្វើបាន ហេតុអីត្រូវទ្រាំធ្វើការជាមួយអ្នកមិនចេះអ្វីសោះ? ខ្ញុំគេរបៀបខ្ញុំ គិតលើប្រយោជន៍ឱ្យលើសពីពីរឡើងទៅ។ ប្រាក់ខែ និងចំណេះដឹង គឺត្រូវតែយក ហើយរកអ្វីមកសរសេរក្នុងសៀវភៅ ក៏សំខាន់ដែរ។

កុំធ្វើការជាមួយថៅកែដែលចូលចិត្តមនុស្សលើកជើង បើយើងមិនមែនជាមនុស្សលើកជើង ហើយគ្មានបំណងចង់ចេះលើកជើង។ ថៅកែបែបនេះ មើលមិនឃើញសមត្ថភាពយើងទេ។

# កុំច្រណែនមនុស្សលើកជើង

ខ្ញុំច្រណែនអ្នកនិពន្ធផ្សេងទៀតដែលអាចសរសេរសៀវភៅបានល្អជាងខ្ញុំ។ ខ្ញុំច្រណែនអ្នកដែលអាចកាត់តវីដេអូបានល្អជាងខ្ញុំ។ ខ្ញុំច្រណែនអ្នកដែលចេះក្បាច់គុណ។ ខ្ញុំច្រណែនអ្វីដែលខ្ញុំចង់បានដូចគេ។ ខ្ញុំមិនត្រឹមតែច្រណែនទេ តែប្រឹងធ្វើឱ្យបានដូចគេទៀតផង។

បើខ្ញុំច្រណែននឹងអ្នកលើកជើង បានន័យថា ខ្ញុំចង់បានដូចពួកគេដែរ។ ជោគជ័យដែលពួកគេទទួល មិនអាចជួយលាងខ្លួនគេបានទេ។ ជោគជ័យបែបនេះ មិនត្រូវនឹងតម្រូវការខ្ញុំទេ។

កុំប្រណែននឹងពួកគេ។ យើងអាចមើលសកម្មភាពគេ ដើម្បីថ្ងៃក្រោយ យើងអាចសម្គាល់មនុស្សប្រភេទនេះបានឆាប់។ បើយើងមានសំណាងក្លាយជាចៅកែគេ យើងក៏អាចដេញក្បាលពួកគេចោលទាន់ពេលដែរ។ ក្រុមហ៊ុនដែលមានមនុស្សលើកជើងច្រើន ដើរទៅណាមិនរួចទេ ព្រោះជើងលើកឡើងលើអស់ហើយ។

# ១១

# ការងារពីរ

តើមានអ្វីដែលធ្វើឱ្យយើងពេញចិត្តជាង ការមានការងារមួយជាប់លាប់? ចម្លើយ គឺការមានការងារពីរក្នុងពេលតែមួយ។ ការងារ ជាផ្នែកនៃជីវិតរបស់យើង ហេតុនេះបើយើងមានការងារពីរ យើងក៏បង្កើតបានផ្នែកពីរទៀតនៅក្នុងជីវិតយើងដែរ។ យើងមានការងារកាន់តែច្រើន ផ្នែកនៃជីវិតយើងកាន់តែសម្បូរបែប។ ការងារ បំពេញភាពជាមនុស្សរបស់យើង ជាពិសេសការងារដែលធ្វើឱ្យយើងរីករាយ។

អ្នកដែលមានការងារពីរ អាចនឹងត្រូវរវល់ច្រើន ប៉ុន្តែលទ្ធផលដែលទទួលបានមកវិញ ក៏មិនអន់ដែរ។ សំខាន់ជាងគេ គឺបានធ្វើអ្វីដែលខ្លួនត្រូវធ្វើ។ វាពិបាក តែវាសមនឹងតម្លៃដែលយើងលះបង់។ ខ្ញុំមានការងារពីរ ម៉ាក់ខ្ញុំមានការងារពីរ មនុស្សដែលខ្ញុំស្គាល់មួយចំនួន ក៏មានការងារពីរដូចគ្នា។ ពួកគេប្រៀបដូចជាមនុស្សពីរផ្សេងគ្នានៅក្នុងការងារទាំងពីរនោះ។

ក្នុងចំណុចនេះ យើងនិយាយពីការងារដែលខ្ញុំគេត្រូវធ្វើ។ យើងទៅធ្វើការឱ្យគេ គឺជាការងារមួយរួចហើយ តែនៅមានការងារមួយទៀតដែលយើងគួរតែឆ្លៀតធ្វើដែរ។ ការងារដែលយើងឆ្លៀតនេះ អាចជួយកែប្រែជីវភាពយើងនៅថ្ងៃណាមួយ ឬអាចធ្វើឱ្យយើងបរាជ័យទាំងស្រុងក៏ថាបាន។ គ្មានអ្នកណាអាចទាយដឹងមុនទេ ប៉ុន្តែតើចង់ដឹងមុនធ្វើអី? ជីវិត ជាការភ្ញាក់ផ្អើល បើយើងដឹងមុនអស់ យើងរស់នៅគ្មានន័យហើយ។

សុខចិត្តដើរលើផ្លូវជីវិតដែលពោរពេញដោយភាពភ្ញាក់ផ្អើលល្អជាង។

# ការងារ និងក្ដីស្រមៃ

បើយើងកើតមកក្នុងត្រកូលអ្នកមាន ក្ដីស្រមៃរបស់យើង មិនពិបាកនឹងសម្រេចទេ ប៉ុន្តែបើយើងមិនមានសំណាងបែបនោះ យើងត្រូវរកវិធីដើរទៅរកក្ដីស្រមៃដោយខ្លួនឯង។ ជួនកាល យើងដើរខុសផ្លូវ តែអាចរកផ្លូវបកក្រោយវិញបាន។ ការមានក្ដីស្រមៃជាជំហានដំបូងដែលយើងសម្រេចចិត្តថា រស់នៅដើម្បីអ្វី។

ទំនាក់ទំនងរវាងការងារ និងក្ដីស្រមៃ មិនពិបាកយល់ទេ។ បើយើងមានក្ដីស្រមៃ យើងមានការងារធ្វើ។ ការងារដែលធ្វើដើម្បីក្ដីស្រមៃ អាចមិនទាន់មានលទ្ធភាពផ្គត់ផ្គង់យើងឱ្យរស់នៅក្នុងពិភពលោកនេះបានទេ ដូច្នេះយើងត្រូវរកការងារផ្សេងទៀត ដើម្បីរស់សិន។ បើយើងរស់មិនបាន ឬរស់មិនស្រួល ក្ដីស្រមៃយើងក៏មិនប្រាកដថាអាចសម្រេចដែរ។

យើងទៅធ្វើការឱ្យអ្នកដទៃ ដើម្បីចិញ្ចឹមខ្លួនឯង និងចិញ្ចឹមក្ដីស្រមៃរបស់យើង។ បើយើងអាចបង្កើតប្រយោជន៍ឱ្យអ្នកដទៃបាន យើងក៏អាចបង្កើតប្រយោជន៍ឱ្យខ្លួនឯងបានដូចគ្នា។ ការងារពីរ បែងចែកផលប្រយោជន៍រៀងខ្លួន។ មួយ ហុចផលឱ្យអ្នកដទៃ មួយទៀត ហុចផលមកខ្លួនយើង។

ខ្ញុំមានការងារត្រឹមត្រូវ ហើយក្រុមហ៊ុនដែលជួលខ្ញុំក៏បើកលុយឱ្យទាន់ពេល ហេតុនេះ ធ្វើឱ្យខ្ញុំគ្មានបញ្ហារឿងឋានៈសង្គម និងលុយកាក់។ លុយដែលខ្ញុំរកបាន គ្រប់នឹងឱ្យខ្ញុំរស់ម្នាក់ឯង ហើយលួចសម្រេចក្ដីស្រមៃខ្លួនឯង។ ក្ដីស្រមៃរបស់ខ្ញុំ គឺធ្វើជាអ្នកនិពន្ធសៀវភៅ។ តាមពិត ខ្ញុំលែងស្រមៃហើយ ព្រោះខ្ញុំមានសៀវភៅខ្លួនឯង ហើយក៏មានគេជួយទិញទៀតផង។

ទោះបីជាលែងស្រមៃ វានៅតែជាក្ដីស្រមៃរបស់ខ្ញុំដដែល។ បើខ្ញុំហ៊ានឈប់ធ្វើការ ហើយបកមកសរសេរសៀវភៅពេញម៉ោង ខ្ញុំប្រាកដជាដាច់បាយមិនខាន ហើយអាចនឹងក្លាយជាបន្ទុកដល់គ្រួសារខ្ញុំម្ដងទៀត។ អ្នកនិពន្ធជាច្រើន គិតខុសត្រង់ចំណុចនេះ។ ពួកគេលះបង់គ្រប់យ៉ាងដើម្បីសម្រេចក្ដីស្រមៃ ដល់ពេលអ្វីៗមិនទៅ

តាមការគិតទុក ពួកគេក៏បោះបោលក្ដីស្រមៃតែម្ដង។ ខ្ញុំស្រលាញ់ក្ដីស្រមៃរបស់ខ្ញុំ ហេតុនេះខ្ញុំមិនភ្លើធ្វើរឿងដែលនាំទុក្ខដល់វាទេ។

បងប្រាជ្ញវិជ័យ ម្ចាស់រោងពុម្ពដាំដើមជីវិត ធ្លាប់ប្រាប់ខ្ញុំឱ្យឈប់ទៅធ្វើការទៅ ហើយយកពេលទាំងអស់ផ្ដោតលើការសរសេរសៀវភៅ។ គាត់នឹងផ្គត់ផ្គង់លុយកាក់ឱ្យខ្ញុំ។ ខ្ញុំមិនជឿគាត់ទេ។ បើខ្ញុំពឹងគាត់ ខ្ញុំនឹងត្រូវធ្វើការដើម្បីគាត់មួយជីវិត ហេតុនេះខ្ញុំមិនបោះបោលការងារ ហើយក៏មិនបោះបោលក្ដីស្រមៃខ្លួនឯងដើម្បីគាត់បានប្រយោជន៍ដែរ។ អ្វីដែលខ្ញុំត្រូវបោះបោល គឺកុងត្រាជាមួយរោងពុម្ពគាត់។ ឥលូវសៀវភៅរបស់ខ្ញុំស្ថិតក្រោមឈ្មោះរបស់ខ្ញុំទាំងអស់ (Samanh EBooks)។ សាកគិតទៅមើលថា តើយើងពេញចិត្តប៉ុណ្ណា នៅពេលស្នាដៃខ្លួនឯង គ្មានឈ្មោះអ្នកដទៃមកលូកលាន់?

ពេលព្រឹក ខ្ញុំទៅធ្វើការឱ្យគេ។ ពេលយប់ ខ្ញុំធ្វើការដើម្បីខ្លួនឯង។ ខ្ញុំមិនមែនជាសហគ្រិន ឬអ្នករកស៊ីទេ តែខ្ញុំជាអ្នកនិពន្ធ។ ខ្ញុំត្រៀមសៀវភៅសម្រាប់សរសេរ ជាបន្តបន្ទាប់ និងប្រឹងផ្សព្វផ្សាយពីខ្លួនឯង។ ខ្ញុំមិនចេះធ្វើទីផ្សារមែន តែខ្ញុំអាចរៀនធ្វើបន្តិចម្ដងបាន។ តាមពិត ខ្ញុំបានដើរលើក្ដីស្រមៃខ្លួនឯងរួចទៅហើយ គ្រាន់តែគេមិនទាន់ទទួលស្គាល់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំធ្វើម្នាក់ឯង គ្មានអ្នកនៅពីក្រោយ ហេតុនេះវាដើរយឺត ក៏មិនចម្លែកដែរ។

មានគេធ្លាប់សួរខ្ញុំថា បើចង់ធ្វើជាអ្នកនិពន្ធ ត្រូវធ្វើដូចម្ដេច? ខ្ញុំឆ្លើយប្រាប់គេថា "ជំហានដំបូង គឺត្រូវមានការងារជាប់លាប់មួយសិនី"។ ក្រពះមិនឃ្លាន ហើយរស់នៅមិនក្រោមស្តង់ដារសង្គម ទើបយើងអាចដើរតាមក្ដីស្រមៃបាន។ បើយើងមិនអាចពឹងខ្លួនឯងបាន ក្ដីស្រមៃរបស់យើងក៏មិនអាចពឹងយើងបានដូចគ្នា។ កុំធ្វើបាបខ្លួនឯង ដោយយកក្ដីស្រមៃមកបាំងមុខ ហើយមិនគិតពីជីវភាពខ្លួនឯង។ ចង់បានលុយមែនទេ? រៀនអ្វីមួយឱ្យចេះ ហើយរកការងារធ្វើទៅ គឺបានហើយ។

អ្នករៀនអាយធីជាមួយខ្ញុំម្នាក់ ទៅធ្វើការនៅក្រុមហ៊ុនគេដើម្បីឱ្យគេបង្រៀនពីរបៀបធ្វើវេបសាយ។ បន្ទាប់មក គេឆ្លៀតរកអតិថិជនដោយខ្លួនឯង ហើយបង្កើតជា Agency មួយដើម្បីរកលុយ។ គេបានប្រាក់ខែមកបង់ថ្លៃផ្ទះ ហើយក៏អាចរកលុយបន្ថែមទៀតបាន។

ការងារដែលយើងធ្វើ ជាឈ្នាន់ទៅរកក្ដីស្រមៃរបស់យើង។ ខ្ញុំមិនទាន់និយាយដល់ជំនាញ បទពិសោធន៍ និងទំនាក់ទំនងដែលបានមកពីការងារផង។ ជីវភាពយើងមិនពិបាក ប្រៀបដូចជាឧបសគ្គមួយត្រូវបានដកចេញពីផ្លូវរបស់យើង។ យើងធ្វើការឱ្យគេ ដើម្បីយើងអាចធ្វើការឱ្យខ្លួនឯង។

សូមបញ្ជាក់៖ គ្រប់សៀវភៅរបស់ខ្ញុំទាំងអស់ មិនសរសេរដើម្បីអ្នកមានស្រាប់ទេ។ កូនអ្នកមាន មានផ្លូវដើរស្រួលហើយ ហេតុនេះមិនត្រូវការជំនួយទេ។ គោលដៅអ្នកអានរបស់ខ្ញុំ គឺអ្នកក្រលំបាក ហើយចង់រើខ្លួនឱ្យស្រណុកជាងហ្នឹង។ ខ្ញុំមិនដឹងពីវិធីក្លាយជាអ្នកមានមែន តែខ្ញុំដឹងពីវិធីដកខ្លួនពីភាពក្រីក្រ។ អ្វីដែលខ្ញុំសរសេរ មិនទាក់ទងនឹងការវិនិយោគ ឬធ្វើជំនួញធំដុំទេ ព្រោះខ្ញុំគ្មានសមត្ថភាព។

# គោលដៅវែង គោលដៅខ្លី

គោលដៅក្នុងជីវិត បែកចេញជាពីរ គឺគោលដៅវែង និងគោលដៅខ្លី។ គោលដៅវែង គឺជាគោលដៅដែលយើងកំណត់ទុកសម្រាប់ ៣ឆ្នាំ ៥ឆ្នាំ ១០ឆ្នាំ ឬរហូតដល់យើងស្លាប់តែម្ដង។ គោលដៅនេះ ជាកម្លាំងចិត្តក្នុងការរស់នៅ។ ចំណែកគោលដៅខ្លីវិញ គឺជាគោលដៅដែលមានយើងក្នុងពេលបច្ចុប្បន្ន ហើយលទ្ធផលវាជះផលក្នុងការរស់នៅប្រចាំថ្ងៃ។

សាកលវិទ្យាល័យ Minnesota State បានកំនត់រយៈពេល ១២ខែ ឬតិចជាងនេះ សម្រាប់គោលដៅរយៈពេលខ្លី។ គេបានលើកឡើងដែរថា “គោលដៅរយៈពេលខ្លីអាចជួយបង្កើតការផ្លាស់ប្ដូរធំបាន”។ ការផ្លាស់ប្ដូរនោះ ពាក់ព័ន្ធដល់គោលដៅវែង។ យើងប្រឹងសម្រេចគោលដៅខ្លីៗ ដើម្បីរត់ទៅរកគោលដៅរយៈពេលវែងរបស់យើង។

គោលដៅខ្លីរបស់ខ្ញុំ គឺរៀនអ្វីថ្មី ដើម្បីបានការងារធ្វើ និងជួយរកលុយឱ្យខ្ញុំកាន់តែច្រើន។ គោលដៅវែងរបស់ខ្ញុំ គឺការនិពន្ធសៀវភៅ។ តើវាមានអ្វីទាក់ទងគ្នា? ការងារថ្មី ផ្ដល់បទពិសោធន៍ថ្មី ហើយបទពិសោធន៍ថ្មី ផ្ដល់ប្រធានបទថ្មីសម្រាប់សរសេរ។ ការសរសេរសៀវភៅច្រំដែល មិនត្រឹមតែធ្វើឱ្យអ្នកអានធុញទេ សូម្បីខ្ញុំដែលជាអ្នកសរសេរ ក៏ធុញដែរ។ ក្រៅពីនេះ លុយ និងកម្រិតជីវភាពរបស់ខ្ញុំ អាចធ្វើឱ្យអ្នកអាន

ជឿថា អ្វីដែលខ្ញុំសរសេរ មិនមែនជាទ្រឹស្តីអាចម៍ឆ្កែ។ សាកគិតទៅមើល អ្នកនិពន្ធក្រម្នាក់ អាចធ្វើឱ្យអ្នកអានព្រមទទួលយកគំនិតទាក់ទងនឹងការរស់នៅយ៉ាងម៉េចបាន? យើងមិនវាយតម្លៃមនុស្សពីសម្បកក្រៅទេ តែអ្នកនិពន្ធត្រូវតែមានភស្តុតាងជានិច្ច។

ខ្ញុំមានគោលដៅច្រើន ដូច្នេះការដឹងថា គោលដៅណាត្រូវសម្រេចមុន និងមួយណាត្រូវធ្វើតាមសម្រួល ជារឿងចាំបាច់។ ការមានគោលដៅច្រើនពេក ធ្វើឱ្យយើងស្មុគស្មាញ និងមិនអាចផ្តោតអារម្មណ៍បានទេ។ បើខ្ញុំគិតតែលើការចង់ធ្វើជាអ្នកនិពន្ធដែលជាគោលដៅវែង ហើយបំភ្លេចគោលដៅខ្លីៗចោលអស់ ខ្ញុំក៏មិនអាចទៅដល់គោលដៅវែងនោះបានដែរ។ តើវាមានប្រយោជន៍អ្វីដែលប្រឹងដាក់គោលដៅហើយតែមិនអាចទៅដល់?

ឧទាហរណ៍៖ ក្រុមហ៊ុនរបស់ខ្ញុំចង់បានអ្នកប្រើប្រាស់វេបសាយ ១លាននាក់ក្នុងរយៈពេល ៣ឆ្នាំ។ នេះជាគោលដៅវែង ចុះគោលដៅខ្លីមានអ្វីខ្លះ? ការត្រៀមបុគ្គលិកថ្មី និងពង្រីកសមត្ថភាពបុគ្គលិកចាស់ ជារឿងចាំបាច់ទីមួយ។ បើបុគ្គលិកមិនអាចធ្វើវេបសាយបានល្អ តើមានអ្នកណាទ្រាំប្រើ។ បន្ទាប់មកនៅមានការរកដៃគូ និងការផ្សព្វផ្សាយ។ ការរកលុយមកទប់ចំណាយដែលមិនទាន់មានចំណូល ក៏ជាគោលដៅរបស់ថៅកែដែរ។ បើក្រុមហ៊ុនមិនមានគោលដៅខ្លី ហើយមិនប្រឹងសម្រេចគោលដៅទាំងនោះទេ គោលដៅវែងដែលបានដាក់មក នឹងគ្មានអ្វីកើតឡើង។

គោលដៅខ្លី ភ្ជាប់ទៅគោលដៅវែង។ ក្រុមហ៊ុនណាក៏ដោយ ឱ្យតែមានគោលដៅវែងច្បាស់ជាមានគោលដៅខ្លីដើម្បីជួយហើយ។ គោលដៅខ្លីអាចមានច្រើន ដើម្បីទៅដល់គោលដៅវែងមួយ។

យើងជាខ្ញុំគេពិតមែន ប៉ុន្តែការមានគោលដៅខ្លី និងគោលដៅវែង នៅតែមានប្រយោជន៍។ រាល់ចុងឆ្នាំ ខ្ញុំតែងតែដាក់គោលដៅខ្លួនឯងសម្រាប់ឆ្នាំថ្មី។ គោលដៅប្រចាំឆ្នាំរបស់ខ្ញុំ ជាគោលដៅវែង ដូច្នេះខ្ញុំត្រូវមានគោលដៅខ្លីៗប្រចាំខែដែលខ្ញុំត្រូវធ្វើឱ្យបាន។ ខ្ញុំមិនអាចសម្រេចបានគោលដៅទាំងអស់ទេ តែក៏មិនអត់ប្រយោជន៍រស់មួយឆ្នាំហើយមួយឆ្នាំទៀតដោយគ្មានអ្វីផ្លាស់ប្តូរដែរ។

គោលដៅវែងដែលខ្ញុំមាន គឺក្លាយជាអ្នកនិពន្ធសៀវភៅ។ អ្នកទាំងអស់គ្នាអាចគិតថា វាគ្មានអីពិបាក គ្រាន់តែសរសេរសៀវភៅនោះ។ ប៉ុន្តែការចេញសៀវភៅជាបន្តបន្ទាប់ ដើម្បីរក្សាឈ្មោះជាអ្នកនិពន្ធ ទើបជារឿងពិបាក។ អ្នកណាក៏អាចសរសេរសៀវភៅ មួយក្បាល ឬពីរក្បាលបានដែរ។ ពួកគេក៏អាចហៅខ្លួនឯងជាអ្នកនិពន្ធបានដូចគ្នា ប៉ុន្តែតើវាសមដែរទេ? បើយើងចូលបួសមួយឆ្នាំ ហើយសឹកមកវិញ តើយើងអាចហៅខ្លួនឯងថា សង្ឃ អស់មួយជីវិតដែរទេ? បើយើងមានស្នេហាតែម្តង ហើយក៏អត់លិតរហូត តើយើងអាចហៅខ្លួនឯងថា មនុស្សសម្បូរស្នេហ៍ដែរទេ?

អ្វីដែលយើងធ្វើជាប្រចាំ ទើបកំណត់ថាយើងជាអ្នកណា។ ខ្ញុំទៅធ្វើការឱ្យគេរាល់ថ្ងៃ ហេតុនេះខ្ញុំ ជាខ្ញុំគេ។ ខ្ញុំសរសេរសៀវភៅថ្មីជាបន្តបន្ទាប់ ហេតុនេះខ្ញុំជាអ្នកនិពន្ធ។ ពាក្យថា “បន្តបន្ទាប់” នេះហើយ ដែលធ្វើឱ្យខ្ញុំចាត់ទុក ការនិពន្ធ ជាគោលដៅវែង។ វានឹងបន្តរហូតដល់ពេលដែលខ្ញុំសរសេរលែងកើត។ គោលដៅវែងបែបនេះ ត្រូវការគោលដៅខ្លីជាច្រើនដូចជា សុខភាព លុយកាក់ មុខមាត់ បទពិសោធន៍ ភាពឆ្លាតវៃ ទំនាក់ទំនងជាមួយអ្នកដទៃ និងការគាំទ្រ។ នៅពេលខ្ញុំសម្រេចបានគោលដៅខ្លីមួយ បានន័យថា ខ្ញុំទៅជិតដល់គោលដៅវែងមួយជំហានទៀត។

មិនថាគោលដៅខ្លី ឬវែងទេ សុទ្ធតែទាមទារឱ្យយើងប្តេជ្ញាចិត្តធ្វើ។ បើយើងកំណត់គោលដៅចោលដើម្បីតែល្អមើល ឬដើម្បីអួតគេ យើងនឹងគ្មានបានអ្វីទាំងអស់។ អ្នកដែលមិនទាន់មានគោលដៅ ត្រូវកំណត់ឱ្យហើយ កុំឱ្យខាតពេល។ ការរស់នៅគ្មានគោលដៅ នឹងធ្វើឱ្យយើងក្លាយជាខ្លួនជាកូនអុកដើម្បីសម្រេចគោលដៅអ្នកដទៃ។ ក្រឡេកមើលកូនអុកនយោបាយ ដែលប្រឹងស្រែកដើម្បីមេដឹកនាំគេទៅ យើងនឹងឃើញថា ការគ្មានគោលដៅខ្លួនឯង ធ្វើឱ្យយើងក្លាយជាមនុស្សប្រភេទណា។

ការគ្មានគោលដៅខ្លួនឯង នឹងធ្វើឱ្យយើងតែលតោល ហើយចុងក្រោយដោយសារយើងល្ងង់ផង ក៏យកគោលដៅអ្នកដទៃមកធ្វើជាគោលដៅខ្លួនឯង ហើយស៊ូស្លាប់ដើម្បីជួយសម្រេចគោលដៅគេ។ គេចង់ធ្វើមេដឹកនាំ យើងមិនដឹងខ្លួន ក៏ចូលទៅឱ្យគេដឹកនាំយ៉ាងងាយ។ រៀនរស់តាមគោលដៅខ្លួនឯងទៅ យ៉ាងហោចណាស់ក៏យើងបានស្គាល់រសជាតិជោគជ័យបន្តិចបន្តួចពីខួរក្បាលខ្លួនឯងដែរ។

គោលដៅវែង និងគោលដៅខ្លីរបស់យើងត្រូវតែជាប់ទាក់ទងគ្នាជានិច្ច។ កុំដាក់គោលដៅដោយមិនចង់បានលទ្ធផល។

# ធ្វើការដើម្បីជកបទពិសោធន៍

បទពិសោធន៍ក្នុងការងារដែលយើងធ្វើដើម្បីអ្នកដទៃ អាចជួយយើងដើម្បីធ្វើការងារខ្លួនឯង។ ប្រយោជន៍មួយដែលយើងបានមកពីការងារ គឺបទពិសោធន៍។ វាជារបស់មានតម្លៃ ហេតុនេះបានជាអ្នកជំនាញជាច្រើនអាចយកវាទៅលក់ក្នុងសិក្ខាសាលាវីដេអូ ឬសៀវភៅបាន។

អ្នកជំនាញទាំងនេះ មានត្រឹមតែបទពិសោធន៍រាប់ឆ្នាំប៉ុណ្ណោះ ក៏ជួយឱ្យពួកគេរស់នៅបានយ៉ាងងាយស្រួលទៅហើយ។ ខ្ញុំប្រើពាក្យ “ត្រឹមតែ” នេះ ប្រហែលជាខុសបន្តិច ព្រោះឱ្យតែមានបទពិសោធន៍ យើងអាចដឹងផ្លូវដើរខ្លះហើយ។ ពួកគេមិនក្លាយជាអ្នកជំនាញដោយគ្មានអ្វីសោះជាប់ខ្លួនទេ។

បទពិសោធន៍ ជាផ្លូវដើរ។ អ្នកដែលមានបទពិសោធន៍ អាចជៀសវាងកំហុសបានច្រើនជាងអ្នកដែលមិនធ្លាប់ធ្វើអ្វីសោះ។ បើសិនជាយើងធ្លាប់ធ្វើជាគ្រូបង្រៀន យើងអាចនឹងដឹងពីវិធីទាក់ទាញគេមករៀនជាមួយយើងបាន។ ជួនកាល យើងអាចមានលទ្ធភាពបើកមជ្ឈមណ្ឌលសិក្សាដោយខ្លួនឯងទៀត។ មិនខ្វះទេអ្នកដែលយកបទពិសោធន៍ក្នុងការងារមកធ្វើការខ្លួនឯងនោះ។

ម៉ាក់ខ្ញុំយកបទពិសោធន៍បង្រៀនក្មេងនៅសាលារដ្ឋ មកប្រើដើម្បីរកលុយដោយខ្លួនឯងនៅផ្ទះ។ គាត់បើកបង្រៀនក្មេងៗ រាល់ល្ងាច ហើយសិស្សដែលស្គាល់នៅតាមសាលា ក៏មករៀនបន្តជាមួយគាត់នៅផ្ទះ។ បើគាត់មិនធ្លាប់បានបង្រៀនក្នុងសាលា គាត់ក៏មិនដឹងថា សាលារដ្ឋបង្រៀនសិស្សយ៉ាងម៉េច ហើយក៏មិនដឹងពីកំហុសក្នុងការបង្រៀនដែរ។ គាត់បង្រៀនខុសពីសាលារដ្ឋ ហើយសិស្សក៏បានផលខុសពីសាលារដ្ឋដូចគ្នា។ ម៉ាក់ខ្ញុំបង្រៀនសាលារដ្ឋជិត ៤០ឆ្នាំហើយដូច្នេះ សម្រាប់គាត់ ការបង្រៀនក្មេង ជារឿងធម្មតា។ គាត់មិនចាំបាច់រៀបមេរៀនអ្វីទាំងអស់ ព្រោះ

អ្វីដែលត្រូវបង្រៀនមានក្នុងខួរក្បាលគាត់ស្រាប់។ បើយើងធ្វើអ្វីមួយ ៤០ឆ្នាំ យើងក៏ធ្វើបានដូចគាត់ដែរ។

ការងារពីរដែលយើងត្រូវមាន គឺការងារសម្រាប់អ្នកដទៃ និងសម្រាប់ខ្លួនឯង។ យើងធ្វើការឱ្យគេ ដើម្បីយកបទពិសោធន៍ ហើយបន្ទាប់មកយកបទពិសោធន៍នោះមកធ្វើការខ្លួនឯងវិញ។ បើយើងមានក្តីស្រមៃដែលត្រូវការបទពិសោធន៍ គួររកការងារធ្វើទៅ យើងអាចសន្សំពេលដើម្បីកែកំហុស ហើយបានលុយទៀត។ នៅតាមកន្លែងធ្វើការ តែងតែមានការបង្រៀន ដូច្នេះយើងអាចរៀនចេះបានលឿនជាងការប្រឹងស្មានដោយខ្លួនឯង។ កុំភ្លេចថា ការងារបង្រៀនមនុស្សបានល្អជាងក្នុងសាលា។ យើងធ្វើការ៤ឆ្នាំ យើងអាចក្លាយជាអ្នកជំនាញម្នាក់ហើយ តែបើរៀនក្នុងសាលា៤ឆ្នាំ យើងមិនប្រាកដថាអាចរកការងារធ្វើបានផង។

បទពិសោធន៍ នឹងជួយយើងពេលជួបនឹងបញ្ហាក្នុងការងារផ្ទាល់ខ្លួន។ យើងមិនអាចដោះស្រាយបញ្ហាបានទេ បើយើងមិនដឹងថាវាជាបញ្ហា ឬក៏មិនធ្លាប់លឺអ្នកណានិយាយពីមុន ប៉ុន្តែនៅពេលយើងទៅធ្វើការ យើងប្រាកដជាស្គាល់ថាអ្វីដែលអាចក្លាយជាបញ្ហា។

ការងាររបស់ខ្ញុំទាក់ទងនឹង E-Leaning ដូច្នេះវាបង្រៀនខ្ញុំពីរបៀបធ្វើមេរៀនដើម្បីកុំឱ្យអ្នករៀនធុញ។ ខ្ញុំយកវិធីទាំងនោះមកប្រើជាមួយការសរសេរសៀវភៅរបស់ខ្ញុំ ព្រោះចង់បានលទ្ធផលដូចគ្នា។ វាអាចមានផលខុសគ្នា ព្រោះនៅកន្លែងការងារ ខ្ញុំមានក្រុមការងារជួយមើល ប៉ុន្តែនៅផ្ទះ ខ្ញុំត្រូវធ្វើគ្រប់យ៉ាងម្នាក់ឯង។ អ្វីដែលខ្ញុំធ្លាប់ធ្វើនៅកន្លែងការងារ សុទ្ធតែអាចយកមកប្រើក្នុងការងារផ្ទាល់ខ្លួនបាន។

បទពិសោធន៍ការងារ នឹងធ្វើឱ្យយើងមានទំនុកចិត្តលើខ្លួនឯង ហើយហ៊ានធ្វើអ្វីដែលយើងយល់ថាមានប្រយោជន៍ដល់ខ្លួន។ ពីមុន ខ្ញុំក៏មិនហ៊ានលក់សៀវភៅខ្លួនឯងដែរ ព្រោះខ្ញុំគិតថា គ្មានអ្នកណាចង់អាន ហើយក៏គ្មានអ្នកណាសុខចិត្តចំណាយលុយទិញសៀវភៅពីអ្នកនិពន្ធថ្មីទេ។ ក្រោយមក ក្រុមហ៊ុនដែលខ្ញុំធ្វើការ បានសាកល្បងលក់សៀវភៅអនឡាញ។ ខ្ញុំជាអ្នកលក់។ ខ្ញុំពិនិត្យសៀវភៅដែលខ្ញុំទិញមក ហើយមើលឃើញថា សៀវភៅខ្លះសរសេររញ៉េរញ៉ៃជាងសៀវភៅខ្ញុំទៀត។ បើខ្ញុំអាចលក់

សៀវភៅអ្នកដទៃបាន ខ្ញុំក៏អាចលក់សៀវភៅខ្លួនឯងដែរ។ ខ្ញុំចាប់ផ្តើមលក់សៀវភៅខ្លួនឯង។ បទពិសោធន៍ការងារមួយ ជួយការងារមួយទៀតឱ្យដើរទៅមុខ។

# ភាពរីករាយក្នុងការងារ

សម្រាប់អ្នកដែលមានការងារពីរ ពួកគេដូចជាលះបង់ពេលវេលាទាំងស្រុងទៅលើការងារ ហើយអាចនឹងបាត់ភាពរីករាយក្នុងការរស់នៅ។ ការគិតបែបនេះមិនអាចថាត្រូវទាំងស្រុង ឬខុសទាំងស្រុងទេ។ ខ្ញុំឃើញមនុស្សជាច្រើន មានភាពរីករាយនៅកន្លែងការងារច្រើនជាងនៅជាមួយគ្រួសារខ្លួនឯងទៀតផង។ ការងារអាចផ្តល់ភាពរីករាយឱ្យយើងបាន ប្រសិនបើយើងចេះទទួល។

ខ្ញុំរីករាយនឹងការងារដែលខ្ញុំមាន ហើយក៏ពេញចិត្តនឹងការងារផ្ទាល់ខ្លួនរបស់ខ្ញុំដែរ។ អ្នកគ្រប់គ្រងរបស់ខ្ញុំតែប្រាប់បុគ្គលិកថ្មីថា "ខ្ញុំមកធ្វើការឱ្យគាត់ ជាការងារក្រៅម៉ោងប៉ុណ្ណោះ ការងារពេញម៉ោងរបស់ខ្ញុំ គឺសរសេរសៀវភៅនៅផ្ទះទេ"។ គាត់និយាយត្រូវណាស់ ព្រោះខ្ញុំមានការងារខ្លួនឯងមុនខ្ញុំចូលធ្វើការនៅក្រុមហ៊ុនគាត់ទៀតផង ហើយគាត់ក៏ដឹងថា ខ្ញុំប្រឹងរកវិធីលក់សៀវភៅផ្ទាល់ខ្លួនដែរ។

គាត់ពេញចិត្តនឹងឱ្យខ្ញុំចូលធ្វើការ ហេតុនេះខ្ញុំក៏ពេញចិត្តធ្វើការឱ្យគាត់ តែមិនពេញចិត្តរហូតទេ ព្រោះការងារដើម្បីអ្នកដទៃ មិនអាចធ្វើឱ្យរីករាយបានយូរទេ។ ដល់ពេលដែលខ្ញុំធុញ ខ្ញុំនឹងត្រូវរកការងារផ្សេងទៀតមិនខាន។ ការងារដែលខ្ញុំរីករាយរហូត គឺការនិពន្ធសៀវភៅខ្លួនឯង។ ខ្ញុំកាន់តែធ្វើ កាន់តែសប្បាយ ជាពិសេសឃើញចំនួនសៀវភៅខ្លួនឯងកើតឡើង។

បើអ្នកទាំងអស់គ្នាទទួលស្គាល់ថា ខ្លួនឯងជាខ្ញុំគេ ហើយចង់បានភាពរីករាយក្នុងការងារ សូមសាកល្បងបង្កើតការងារផ្ទាល់ខ្លួន។ វាអាចជាការចាប់ផ្តើមគម្រោងអ្វីមួយ ឬជំនួញក្នុងក្តីស្រមៃរបស់យើង។ យើងនឹងរីករាយធ្វើវារាល់ថ្ងៃ ដោយមិនចាំបាច់មានផលតបស្នងច្រើនទេ។ មិនថាយើងរវល់ប៉ុណ្ណា យើងនៅតែរកពេលមកធ្វើការងារផ្ទាល់ខ្លួនបាន បើសិនយើងច្បាស់ជាមួយខ្លួនឯង។

កុំធ្វើការងារអ្វីដែលនាំយើងឱ្យមិនសប្បាយចិត្ត។ តែបើវាអាចរកលុយបានច្រើន ទ្រាំធ្វើទៅ ហើយឆ្លៀតពេលដែលនៅសល់ធ្វើការងារមួយទៀត ដែលយើងជឿថា អាចជួយយើងបាននៅថ្ងៃក្រោយ។ ការងារខ្លួនឯង ជាភាពរីករាយ។ យើងអាចនឹងមានអារម្មណ៍ថា ដូចជាមានសេរីភាព និងភ្ញាក់ផ្អើលរាល់ពេលដែលមានការវិវត្តម្តងៗ។

យើងអាចមិនភ្ញាក់ផ្អើលនៅពេលក្រុមហ៊ុនដែលយើងធ្វើការទទួលបានជោគជ័យ ប៉ុន្តែយើងមិនអាចនៅស្ងៀមពេលឃើញការងារផ្ទាល់ខ្លួនយើងរីកចម្រើនទេ។ ខ្ញុំមិនដែលភ្លេច អារម្មណ៍ដែលខ្ញុំលក់សៀវភៅបានដំបូងទេ។ ខ្ញុំធ្លាប់គិតថា វាទៅមិនរួច ស្រាប់តែមានអ្នកទិញ ធ្វើឱ្យខ្ញុំនៅស្ងៀមទៅវិញ។

យើងជាខ្ញុំគេទេ ហេតុនេះត្រូវមានភាពរីករាយក្នុងការងារឱ្យបានច្រើន។ កុំតប់ប្រមល់ ព្រោះមិនផ្តល់ជម្រើសដល់ខ្លួនឯងក្នុងការងារ។ បើការងារមួយ មិនអាចឱ្យរីករាយបាន រកមួយទៀត។

# ១២

# ការលាឈប់ពីការងារ

ល្ងាចមួយ មុនពេលខ្ញុំចេញមកផ្ទះ ខ្ញុំបានទៅឈរនិយាយលេងជាមួយអ្នកធ្វើការក្នុងបន្ទប់របស់ខ្ញុំ។ ខ្ញុំនិយាយពីរឿងប្ដូរការងារ។ បុគ្គលិកម្នាក់បានប្រាប់ខ្ញុំថា "ត្រូវចាំ គ្មានអ្នកណាធ្វើការមួយកន្លែងរហូតទេ"។ ខ្ញុំក៏តបវិញថា "ចាំខ្ញុំយកសៀវភៅមកកត់ទុក កុំឱ្យភ្លេច"។ និយាយចប់ ខ្ញុំក៏រៀបកាតាបមកផ្ទះ។ មនុស្សបែបនេះ ទើបមានកំណើត និងស្គាល់ថាអ្វីជាការសាកល្បងថ្មី។

ខ្ញុំធ្លាប់ធ្វើការនៅកន្លែងមុនៗ ដែលបុគ្គលិកម្នាក់ៗប្រឹងធ្វើការដើម្បីឡើងដំណែងជាបន្តបន្ទាប់។ ពួកគេព្យាយាមយកចិត្តមេ ព្រោះមិនចង់បាត់បង់ការងារ។ នៅពេលគេលឺខ្ញុំចង់ដាក់ពាក្យឈប់ គេក៏ប្រាប់ថា "កុំហាក់លោតពេក ប្រយ័ត្នអ្វីក៏មិនសល់"។ ខ្ញុំមិនយល់សោះ ហេតុអ្វីបានជាម្នាក់ៗគិតថា ការលាឈប់ពីការងារ ជារឿងមិនល្អ។ ជួនកាល វាអាចជាការសម្រេចចិត្តល្អបំផុតរបស់យើងក៏ថាបាន។

ខ្ញុំឈប់ពីការងារចាស់ ហើយរកការងារថ្មីធ្វើ ហើយខ្ញុំគិតថា ការធ្វើបែបនេះ ប្រៀបដូចជាការរៀនចប់មួយថ្នាក់ ហើយឡើងមួយថ្នាក់ទៀតដែរ។ ការងារ ជាការរៀនដែលបានលុយ។ ពេលខ្ញុំរៀនចប់ហើយ តើខ្ញុំនៅធ្វើអីទៀត? ខ្ញុំមិនសូវជាពូកែរឿងរកស៊ីប៉ុន្មានទេ តែខ្ញុំក៏មិនពេញចិត្តនឹងការងារងាប់ក្រឡាដែរ។

ឪពុកម្ដាយខ្ញុំធ្វើការនៅកន្លែងដដែលលើសពី២០ឆ្នាំ។ វាជារឿងខាតបង់ដែលយើងយកពេល២០ឆ្នាំ ទៅធ្វើរឿងដដែល ហើយជារឿងដែលយើងដឹងលទ្ធផលទៀតផង។ គម្រូមិនល្អរបស់ឪពុកម្ដាយខ្ញុំ ជួយខ្ញុំឱ្យប្ដេជ្ញាចិត្តថា មិនធ្វើក្នុងកន្លែងមួយលើសពី៣ឆ្នាំ។ ខ្ញុំមិនមែនកំណត់ពេល៣ឆ្នាំដោយចៃដន្យទេ។ រយៈពេល ២ទៅ

៣ឆ្នាំ គឺល្មមនឹងឱ្យយើងធ្វើការបានស្ទាត់ជំនាញហើយ។ ការងារនឹងអស់ភាពរីករាយ នៅពេលវាគ្មានអ្វីថ្មីសម្រាប់រៀន។ ខ្ញុំដាក់កំណត់បែបនេះមែន តែមិនដែលទប់ចិត្តធ្វើការឱ្យចប់៣ឆ្នាំទេ។

ការលាឈប់ពីការងារ ជាសញ្ញាបត្ររបស់យើងដែលបញ្ជាក់ថា យើងធ្វើការឆ្អែតឆ្អន់ក្នុងកន្លែងមួយហើយ ដូច្នេះត្រូវការកន្លែងថ្មីទៀត។ ទីផ្សារការងារប្រហែលជាចង្អៀត តែសម្រាប់អ្នកដែលមានបទពិសោធន៍ស្រាប់ វាមិនអីទេ។

# ពាក្យមុនឈប់

នៅពេលខ្ញុំចូលធ្វើការក្នុងក្រុមហ៊ុនថ្មីបានប៉ុន្មានខែ ស្រាប់តែមានបុគ្គលិកម្នាក់ដាក់ពាក្យឈប់។ គេធ្វើការឱ្យក្រុមហ៊ុន៥ឆ្នាំ ហើយចង់ទៅរកស៊ីដោយខ្លួនឯង ដូច្នេះគេក៏ឈប់។ តាមទម្លាប់របស់ក្រុមហ៊ុននេះ ពេលមានបុគ្គលិកឈប់ គេនឹងរៀបចំកម្មវិធីលាគ្នា ដោយមានអ្នកឡើងនិយាយ និងនំចំណីបន្តិចបន្តួច។ ខ្ញុំក៏នៅក្នុងនោះដែរ ព្រោះចង់ដឹងថាគេនិយាយអ្វីខ្លះ។

ប្រធានផ្នែករបស់គេបានឡើងមកនិយាយដើម្បីបើកកម្មវិធី។ គាត់និយាយថា “ការលាឈប់នេះ ជាការចាប់ផ្ដើមថ្មីរបស់ប្រុស(ម្នាក់នោះឈ្មោះប្រុស)”។ គាត់ជូនពរឱ្យជោគជ័យនឹងមុខជំនួញថ្មី ហើយក៏ចាប់ផ្ដើមដណ្ដើមគ្នាស៊ីចុក។ ខ្ញុំក៏ដើរទៅផ្ទះ។

ពាក្យរបស់គាត់នេះ ធ្វើឱ្យខ្ញុំចាំរហូតដល់ពេលដែលគាត់ត្រូវគេបញ្ឈប់ពីការងារ។ គាត់និយាយត្រូវណាស់ ព្រោះចំណុចបញ្ចប់ក្នុងរឿងមួយ ជាចំណុចចាប់ផ្ដើមនៅក្នុងរឿងថ្មីទៀត។ ចំណុចបញ្ចប់ ជារឿងល្អ បើយើងមើលវាក្នុងពេលអនាគត។ ខ្ញុំបញ្ចប់ការងារជាអ្នកបង្រៀនក្រាហ្វិចឌីហ្សាញ ហើយចាប់ផ្ដើមការងារជាធ្វើ E-Learning វិញ។ ខ្ញុំបញ្ចប់ការងារក្នុងក្រុមហ៊ុនមួយ ហើយចាប់ផ្ដើមការងារក្នុងក្រុមហ៊ុនមួយទៀត។ តើត្រង់ណាដែលថាមិនល្អ?

ក្រោយខ្ញុំធ្វើការបានជិតមួយឆ្នាំ ក៏មានគេដាក់ពាក្យឈប់ម្នាក់ទៀត ព្រោះគ្រប់លុយបើកហាងដោយខ្លួនឯង។ មុននឹងទៅ គាត់បានប៉ាវបាយថ្ងៃត្រង់ដល់បុគ្គលិកមួយក្រុមហ៊ុន។ គាត់ថានេះជាការអរគុណចំពោះអ្នកដែលបានធ្វើការជាមួយគាត់។ គាត់

មិននិយាយអ្វីច្រើនទេ ប៉ុន្តែការលាឈប់របស់គាត់ ក៏ជាការចាប់ផ្ដើមថ្មីរបស់គាត់ដូចគ្នា។ គាត់ចាប់ផ្ដើមជីវិតជាអ្នកជំនួញ។ ខ្ញុំជឿថា គាត់នឹងមិននឹកជីវភាពជាខ្ញុំគេទៀតទេ។

ការលាឈប់ ជាចំណុចបញ្ចប់របស់ក្រុមហ៊ុន ព្រោះយើងនឹងមិនមកធ្វើការទៀតទេ។ វាជាចំណុចចាប់ផ្ដើមរបស់យើង ព្រោះយើងនៅតែទៅធ្វើការដូចមុនដដែល គ្រាន់តែខុសកន្លែងប៉ុណ្ណោះ។

ពេលយើងសម្រេចថាបិទទ្វារណាមួយក្នុងជីវិត ទើបយើងឃើញទ្វារមួយទៀតដែលយើងអាចបើកបាន។ បើយើងមិនបោះបោលការងារចាស់ យើងក៏មិនមានការងារថ្មីដែរ។ វាជារឿងវេទនាមួយ ដែលទ្រាំធ្វើកិច្ចការដដែលៗ ព្រោះមិនចង់អត់ការងារធ្វើ។ យើងមិនអាចរស់នៅដោយខ្លាចការចាប់ផ្ដើមថ្មីនោះទេ។ ចំណុចបញ្ចប់ តែងតែជាចំណុចចាប់ផ្ដើម។ បើសិនជាយើងគិតច្បាស់ហើយ ត្រូវដាច់ចិត្តបញ្ចប់ការងារចាស់ ហើយចាប់ផ្ដើមការងារថ្មី។

# តើការប្ដូរការងារច្រើន ជារឿងល្អដែរទេ?

អ្នកគ្រប់គ្រងចិនម្នាក់ដែលខ្ញុំធ្លាប់ធ្វើការជាមួយ ប្រាប់ខ្ញុំថា “យើងជាមនុស្សប្រុស បើសិនជាអាយុ៣០ហើយ មិនទាន់មានការងារច្បាស់លាស់ធ្វើទៀត ជីវិតយើងគឺចោលម្សៀតហើយ”។ គាត់ប្រាប់ខ្ញុំក្រោយពេលខ្ញុំដាក់ពាក្យឈប់ពីកាស៊ីណូ។ គាត់មិនថា ការងារដែលខ្ញុំធ្វើថ្មីមិនល្អទេ ព្រោះគាត់ក៏មិនដឹងច្បាស់ដែរ ប៉ុន្តែគាត់ប្រាប់ខ្ញុំពីអាយុដែលត្រូវមានការងារច្បាស់លាស់។ គាត់មិនមែនជំនាញអ្វីក្រៅពីចេះបកប្រែភាសាចិន និងទទួលភ្ញៀវទេ ប៉ុន្តែគាត់មានបទពិសោធន៍ក្នុងរឿងការងារ។

ក្រោយពីពេលនោះមក ខ្ញុំយកពាក្យនេះមកគិតជានិច្ច។ បើខ្ញុំអាយុមិនទាន់ ៣០ឆ្នាំ ការប្ដូរការងារ នៅតែជាជម្រើសរបស់ខ្ញុំ។ ខ្ញុំមិនច្បាស់ថា តើការងារចុងក្រោយរបស់ខ្ញុំ ជាអ្វីទេ ហើយខ្ញុំក៏មិនបារម្ភដែរ។ ការងារបច្ចុប្បន្ន ទើបជាអ្វីដែលខ្ញុំត្រូវប្រឹងធ្វើ។ ពេលធ្វើអស់ចិត្តហើយ ខ្ញុំត្រូវរកមើលកន្លែងផ្សេងទៀតដែលខ្ញុំអាចផ្ញើខ្លួនបានមួយរយៈ និងយកលុយពីគេមកចាយសិន។

ការងារ ជាអ្នកជួយឱ្យយើងរស់បាន។ យើងគ្មានការងារ យើងគ្មានចំណូល ដល់ចុងក្រោយយើងនឹងចូលរួមជាមួយអ្នកដែលគ្មានការងារធ្វើ ទៅបន្ទោសរដ្ឋាភិបាល។ ការធ្វើបែបនេះ ជាចរិតពេលមនុស្សទាល់ច្រកប៉ុណ្ណោះ។ បើយើងធ្លាប់រៀនសុភាសិតខ្មែរ “ខ្លួនទីពឹងខ្លួន” យើងនឹងកាន់តែយកចិត្តទុកដាក់លើការងារមិនខាន។

ការប្តូរការងារច្រើនអាចជារឿងល្អ ហើយក៏អាចមិនល្អដែរ។ ពេលយើងធ្លាប់ធ្វើការនៅកន្លែងផ្សេងគ្នា យើងមានបទពិសោធន៍ច្រើន ស្គាល់អ្នកដទៃ និងមានចំណេះដឹងថ្មីច្រើន។ យើងក៏ប្រហែលជាអាចបានលុយច្រើនដែរ បើសិនជាបទពិសោធន៍ដែលយើងមាន អាចប្រើការបាននៅកន្លែងផ្សេង។ យើងមិនចាំបាច់ព្រួយចិត្តថាខ្លាចគេដេញចោល ព្រោះយើងមិនជាប់ជំពាក់នឹងកន្លែងណាមួយច្បាស់លាស់។ យើងក៏មិនបាច់លើកជើងអ្នកណាដើម្បីរក្សាការងារដែរ។ ចំណុចល្អទាំងនេះ អាចឱ្យពិចារណាប្តូរការងារបាន។ យើងក៏អាចបញ្ជាក់ប្រាប់ខ្លួនឯងបានដែរថា យើងមានសេរីភាពគ្រប់គ្រាន់។

ប៉ុន្តែមានពេលខ្លះ ការប្តូរការងាររច្រើន អាចនឹងក្លាយជាផលវិបាកដែរ។ ពេលគេឃើញ ប្រវត្តិការងារយើងច្រើន គេអាចនឹងគិតទុកមុនថា យើងមិនអាចធ្វើការឱ្យគេបានយូរទេ ហេតុនេះគេអាចនឹងមិនរើសយកយើងឱ្យចូលធ្វើការ។ គេគិតពីប្រយោជន៍របស់ក្រុមហ៊ុនគេ គឺត្រឹមត្រូវណាស់។ យើងមិនអាចបន្ទោសគេបានទេ។ អ្នកខ្លះ យល់ថាយើងជាមនុស្សមិនស្មោះត្រង់ ហេតុនេះគេមិនសូវទុកចិត្តយើង។ ពួកគេគិតបែបនេះ ព្រោះគេច្រលំពាក្យថា ស្មោះត្រង់ និងស្មោះស្ម័គ្រប៉ុណ្ណោះ។ រឿងមួយទៀត គឺទំនាក់ទំនង។ យើងអាចនឹងមិនសូវមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដទៃទេ។

បើសួរថា តើវាល្អឬអត់ យើងត្រូវមើលលើចរិតមនុស្សហើយ។ សម្រាប់ខ្ញុំ គឺល្អ។ ខ្ញុំចូលចិត្តប្តូរការងារ ហើយខ្ញុំត្រៀមខ្លួនប្តូរជានិច្ច។ បើមានសមត្ថភាពអាចប្តូរបាន ហេតុអ្វីមិនសាកប្តូរទៅ? តែមុននឹងប្តូរ យើងត្រូវគិតជាមុនសិន។ ខួរក្បាលមានត្រូវតែយកមកប្រើ ជាពិសេសបើការសម្រេចចិត្តនោះទាក់ទងនឹងជីវភាពរបស់យើង។ ខ្ញុំនឹងប្រាប់ពីអ្វីដែលខ្ញុំធ្លាប់គិតមុនពេលសម្រេចចិត្តឈប់ពីកន្លែងណាមួយ។

# តើពេលណាដែលយើងត្រូវដើរចេញ?

មុនពេលយើងសរសេរមួយ ត្រូវគិតពីចំណុចបញ្ចប់ឱ្យហើយ។ នេះជាដំបូន្មានល្អក្នុងការសរសេរ ព្រោះបើយើងមិនដឹងពីចំណុចបញ្ចប់ យើងក៏មិនដឹងចាប់ផ្ដើមយ៉ាងណាឱ្យល្អដែរ។ ក្នុងការងារក៏មិនខុសគ្នាដែរ យើងត្រូវគិតដល់ថ្ងៃដែលយើងលាឈប់ឱ្យបានមុន។ បើយើងមិនគិតទេ យើងនឹងជាប់ផុងក្នុងការងារតែមួយអស់រាប់សិបឆ្នាំ ទម្រាប់តែដល់ពេលចូលនិវត្តន៍ ឬត្រូវគេដេញចោល។

**ករណីបន្ទាន់ គឺការងារដែលយើងកំពុងធ្វើប៉ះពាល់ដល់សុខភាពរបស់យើង។** មិនថាយើងឃ្លានចង់បានលុយប៉ុណ្ណា ក៏មិនត្រូវភ្លេចគិតពីសុខភាពដែរ។ ពេលដែលយើងកំពុងធ្វើ វាអាចមិនទាន់អីទេ ប៉ុន្តែប៉ុន្មានឆ្នាំទៀត រាងកាយយើងនឹងទ្រុឌទ្រោម ហើយយើងនឹងឃើញរោគសញ្ញាដោយខ្លួនឯង។ ខ្ញុំឈប់ធ្វើការក្នុងកាស៊ីណូ ដោយសារតែផ្សែងបារីខ្លាំងពេក ហើយខ្ញុំត្រូវឈរយូរម៉ោង។ ខ្ញុំមិនមានហេតុផលអ្វីដើម្បីលះបង់ខ្លួនឯងដើម្បីកាស៊ីណូដើរទៅមុខទេ ហេតុនេះ ខ្ញុំដាក់ពាក្យឈប់ដោយប្រាប់ថា ខ្ញុំត្រូវទៅរៀនពេលល្ងាចវិញ។

ខ្ញុំដឹងថា ក្មេងៗមិនខ្វល់ពីសុខភាពខ្លួនឯងទេ។ ដល់ពេលឈឺ ទើបយើងចេះប្រកបពាក្យថា ស្ដាយក្រោយ។ កាលពីមុន ខ្ញុំក៏មិនខ្វល់ដែរ។ ខ្ញុំធ្វើការដល់ម៉ោង ២យប់ ឬទល់ភ្លឺក៏មានដែរ ហើយខ្ញុំអួតគេថា សុខភាពខ្ញុំល្អណាស់ មិនងាយឈឺផ្ដាសទេ។ តែដល់ពេលឈឺ ទើបខ្ញុំដឹងថា អ្វីដែលខ្ញុំធ្វើពីមុន គឺខុសទាំងអស់។ ខ្ញុំធ្វើបាបខ្លួនឯងព្រោះខ្ញុំល្ងង់។ គ្រូពេទ្យពន្យល់ខ្ញុំពីមូលហេតុដែលខ្ញុំឈឺហើយ ទើបខ្ញុំភ្ញាក់ខ្លួន។ ការភ្ញាក់ខ្លួននេះ មិនអាចជួយអ្វីឱ្យខ្ញុំរួចពីជម្ងឺបានទេ តែវាអាចឱ្យខ្ញុំរំលឹកអ្នកដែលមិនទាន់ឈឺបាន។

ការងារណាក៏ដោយ ឱ្យតែប៉ះពាល់ដល់សុខភាពយើង ត្រូវតែរកផ្លូវប្ដូរចេញ ជាពិសេសការងារពេលយប់។ យើងអត់ដេកយប់យូរទៅ នឹងប៉ះពាល់ខួរក្បាលយើងមិនខាន។ ខួរក្បាលខូចហើយ យើងរស់ក៏គ្មានន័យដែរ។ បើសិនជាមានពេលទំនេរស្រាវជ្រាវទាក់ទងនឹងសុខភាពឱ្យបានច្រើន ក៏ល្អដែរ ដើម្បីយើងអាចសម្រេចចិត្ត

បានលឿន។ មនុស្សយើងខ្លាចស្លាប់ តែមិនខ្លាចខូចសុខភាពទេ។ ខ្ញុំខ្លាចស្លាប់ ទើបខ្ញុំខ្លាចខូចសុខភាព។

**ករណីទីពីរ គឺ ការងារដែលយើងធ្វើ គ្មានអនាគតល្អ។** “គ្មានការងារណាថោកទាបទេ” ជាឃ្លាដែលគេនិយមប្រើ ជាពិសេសអ្នកដែលចូលចិត្តលួងខ្លួនឯង។ សាកគិតទៅដល់តារាកំប្លែងពាក់មី និងបងប្អូនរបស់គាត់ទៅមើល ថាការងារមុនចូលសិល្បៈ និងការងារក្នុងសិល្បៈ មួយណាធ្វើឱ្យពួកគាត់ស្គាល់ភាពថ្លៃថ្នូរ? ការងារថ្លៃថ្នូរ នឹងនាំយើងឱ្យស្គាល់ភាពថ្លៃថ្នូរ ហើយការងារថោកទាប នាំយើងឱ្យមើលឃើញត្រឹមភាពថ្លៃថ្នូររបស់អ្នកដទៃប៉ុណ្ណោះ។ ខ្ញុំមិនចង់ឱ្យយើងនាំគ្នាយកភាពវិជ្ជមានដាក់គ្រប់កន្លែងទេ ព្រោះវាធ្វើឱ្យយើងគិតខុស ហើយគេចវេសពីការពិត។

ការងារមានថោកទាប និងថ្លៃថ្នូរ។ ការងារថ្លៃថ្នូរ អាចធ្វើឱ្យយើងមានអនាគតល្អ។ វាអាច តែខ្ញុំមិនប្រាកដថាយើងនឹងមានឬអត់ទេ។ ប៉ុន្តែការងារថោកទាបវិញ នឹងធ្វើឱ្យយើងអស់អនាគត។ ខ្ញុំមិនលើកឧទាហរណ៍ឱ្យចំទេ កុំឱ្យអ្នកទាំងអស់គ្នាគិតថា ខ្ញុំរើសអើងការងារ និងមើលងាយអ្នកដែលមានការងារមិនល្អ។ ខ្ញុំជឿថា យើងអាចស្គាល់ការងារថោកទាបបានដោយខ្លួនឯង។ កុំរាប់តែរឿងឆក់ប្លន់ ជួនកាលការងារត្រឹមត្រូវតាមច្បាប់ ក៏ជាការងារថោកទាបដែរ។ ការងារដែលខ្ញុំកំពុងធ្វើរាល់ថ្ងៃ ចេញផុតពីថោកទាបបន្តិចប៉ុណ្ណោះ ព្រោះវាមានទាក់ទងនឹងសាសនា។

យើងធ្វើការ ដើម្បីអនាគត ចុះបើការងារនោះគ្មានអនាគតឱ្យយើងផង តើយើងធ្វើវាដើម្បីអី? យកគោលដៅរយៈពេលវែងរបស់យើង មកប្រៀបធៀបនឹងការងារដែលយើងកំពុងធ្វើ យើងនឹងដឹងថា វាមានអនាគតឬអត់ហើយ។ បើយើងមិនកុហកខ្លួនឯង ឬមិនលួងខ្លួនឯងទេ យើងនឹងអាចស្គាល់ការងារគ្មានអនាគតកាន់តែឆាប់រហ័ស។

**ករណីទីបី គឺយើងមិនពេញចិត្តនឹងការងារ។** វាអាចបណ្ដាលមកពីថៅកែ ឬអ្នកធ្វើការរួមគ្នា។ យើងមិនអាចទៅធ្វើការដោយចងចិញ្ចើមរាល់ថ្ងៃទេ ហេតុនេះ បើជួបករណីនេះ យើងប្ដូរចេញក៏ល្អដែរ។ ក្រុមហ៊ុនខ្លះធ្វើរឿងខុសច្បាប់ ឬលក់ផលិតផល

ដែលប៉ះពាល់សុខភាពអ្នកប្រើ តើយើងអាចទ្រាំធ្វើការក្នុងក្រុមហ៊ុនបែបនេះបានទេ? យើងចង់បានគុណសម្បត្តិក្នុងរឿងអស់នេះដែរមែនទេ?

**ករណីទីបួន គឺ យើងមានការងារថ្មីដែលល្អជាង។** គោលការណ៍សំខាន់សម្រាប់ខ្ញុំគេ គឺកុំមានចិត្តស្មោះស្ម័គ្រនឹងក្រុមហ៊ុន ឬថៅកែណាទាំងអស់។ រស់ដើម្បីខ្លួនឯង សាកល្បងឱ្យចិត្ត ហើយកុំលង់ជឿទ្រឹស្តីគ្រប់គ្រងបុគ្គលិក។ ឱ្យតែកន្លែងណាយើងគិតថាល្អជាង ទៅធ្វើចុះ។ ការសម្រេចចិត្តរបស់យើងមិនខុសទេ ទោះបីយើងបានផល ឬមិនបានក៏ដោយ។ យើងចេះកាន់តែច្រើន ការងារថ្មីដែលយើងនឹងទទួលបានក៏កាន់តែល្អ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ស្មោះត្រង់បាន តែកុំស្មោះស្ម័គ្រ។

**ករណីទីប្រាំ គឺយើងអាចបើករបររកស៊ីខ្លួនឯង។** របររកស៊ីល្មមៗ អាចឱ្យយើងចិញ្ចឹមគ្រួសារបានហើយ។ របររកស៊ី មិនសំដៅដល់ការបើកក្រុមហ៊ុនធំៗទេ។ ជួនកាលត្រឹមតែកន្លែងលក់បាយធម្មតា ក៏អាចរកលុយឱ្យយើងស្មើនឹងការងារដែលយើងធ្លាប់ធ្វើដែរ។

ករណីនេះ ជាពេលដែលយើងដកខ្លួនពីខ្ញុំគេ ហើយសាកធ្វើខ្ញុំខ្លួនឯងម្តងហើយ។ មានមនុស្សច្រើនដែលប៉ងចង់ឱ្យខ្លួនឯង ជួបករណីចុងក្រោយនេះ។ ភាពជាម្ចាស់លើវាសនាខ្លួនឯង គួរតែជាក្តីស្រមៃរបស់ខ្ញុំគេទាំងឡាយ។

ខ្ញុំអាចឱ្យជាយោបល់បានតែប៉ុននេះទេ។ បើសិនជាយើងអាចមានហេតុផលផ្សេងទៀត ដើម្បីលាឈប់ សូមធ្វើតាមចិត្តចុះ។ អ្វីដែលយើងគិតថាត្រូវ ធ្វើវាទៅ ហើយបើខុស ទទួលកំហុសខ្លួនឯងផង។

# មុនពេលលាឈប់

មុនពេលយើងសម្រេចចិត្តលាឈប់ យើងត្រូវធ្វើកិច្ចការមួយចំនួនសិន។ ខាងក្រោមនេះ ជាអ្វីដែលខ្ញុំធ្លាប់ធ្វើកន្លងមក៖

- **រកការងារថ្មីឱ្យបាន៖** ដោយសារខ្ញុំមិនចង់ឱ្យអ្នកផ្ទះខ្ញុំពិបាក ទើបខ្ញុំត្រូវមានការងារថ្មីជានិច្ចដើម្បីទប់ចំណាយខ្លួនឯង។ ខ្ញុំរកការងារថ្មី យ៉ាងតិច៣ខែមុន ដើម្បី

មានពេលគ្រប់គ្រាន់ធ្វើកិច្ចការផ្សេងទៀតឱ្យហើយ។ យើងងាយនឹងរកការងារថ្មី នៅពេលយើងកំពុងមានការងារធ្វើ។ អ្នកដែលអត់ការងារធ្វើ ពិបាករកការងារធ្វើណាស់។

- **ធ្វើកិច្ចការឱ្យរួច៖** ត្រង់នេះទាក់ទងនឹងទំនួលខុសត្រូវរបស់យើង។ មុនពេលឈប់ ត្រូវបញ្ចប់កិច្ចការទាំងអស់ និងប្រគល់អ្វីដែលនៅសល់ទៅឱ្យដែលមកជំនួសយើង។ បើសិនជាគ្មានអ្នកជំនួសទេ អាចប្រគល់ទៅឱ្យអ្នកគ្រប់គ្រង។
- **កុំមានរឿងជាមួយអ្នកណា៖** យើងត្រូវប្រយ័ត្នខ្លួនឯងមុនពេលលាឈប់។ ជួនកាល យើងគិតថា យើងនឹងអស់រឿងហើយ ព្រោះយើងគង់តែឈប់ដដែល។ ការគិតបែបនេះមិនត្រូវទេ ព្រោះយើងមិនដឹងថា បញ្ហាដែលបង្កើតអាចនឹងរីកធំ។ កុំបង្កើតដំបៅដោយមិនចាំបាច់។

ការលាឈប់ មិនពិបាកដូចយើងគិតទេ។ ខ្ញុំធ្វើដំបូង មានអារម្មណ៍ថាភ័យ ហើយគិតថា ខ្លួនឯងធ្វើមិនត្រូវនឹងអ្នកគ្រប់គ្រងខ្ញុំ។ អ្នករួមការងារប្រឹងបង្រៀនខ្ញុំឱ្យចេះធ្វើការ ហេតុនេះ ពេលខ្ញុំដាក់ពាក្យឈប់ ពួកគេហាក់ដូចជាមិនពេញចិត្ត។

ត្រូវចាំ គ្រប់យ៉ាងក្នុងការងារមិនទាក់ទងនឹងរឿងផ្ទាល់ខ្លួនទេ។ យើងឈប់ដោយសារយើងត្រូវដើរផ្សេងទៀត។ យើងមិនអាចឱ្យអារម្មណ៍គ្រប់គ្រងយើងទេ បើមិនចង់ធ្វើការងាប់ក្រឡា។ យើងធ្វើអ្វីមិនដាច់ស្រេច ព្រោះតែអារម្មណ៍។ ឱ្យតែយើងចេះបែងចែកឱ្យដាច់ យើងលែងពិបាកហើយ។

ក្រោយយើងដាក់ពាក្យឈប់ហើយ អ្វីដែលយើងត្រូវធ្វើ គឺរង់ចាំថ្ងៃឈប់មកដល់ប៉ុណ្ណោះ។ យើងធ្វើការធម្មតា ឬអាចបន្ថយពេលវេលាខ្លះ ដោយកាត់យកថ្ងៃឈប់មកប្រើឱ្យអស់ក៏បានដែរ។ យើងនឹងធូរចិត្តច្រើន ពេលជិតឈប់បែបនេះ។

# ទំនាក់ទំនងក្រោយពេលឈប់

តើយើងអាចរក្សាទំនាក់ទំនងជាមួយមិត្តរួមការងារបានដែរទេ ក្រោយពេលឈប់? សំណួរនេះ ធ្វើឱ្យខ្ញុំត្រូវទាស់សម្តីជាមួយសង្សារខ្ញុំជាច្រើនដង។ សង្សារខ្ញុំ ជា

មនុស្សជឿលើមិត្តភាព ខ្ញុំជឿលើការប្រែប្រួល។ នៅពេលមានអ្វីមួយប្រែប្រួល អ្វីផ្សេងទៀតដែលជាប់ពាក់ព័ន្ធគ្នា ក៏អាចប្រែប្រួលដែរ។ ទំនាក់ទំនងដែលកើតឡើងនៅពេលធ្វើការជាមួយគ្នា ក៏អាចបាត់បង់នៅពេលឈប់ធ្វើការជាមួយគ្នាដែរ។

យើងត្រូវមើលលើកត្តាដែលអាចរក្សាទំនាក់ទំនងបានជាមុនសិន។ ពេលវេលា ការពិភាក្សា និងសកម្មភាពសប្បាយ តើយើងអាចធ្វើជាមួយគ្នាបានទៀតទេ? បើបាន ទំនាក់ទំនងរបស់យើង អាចនៅដដែល។ បើមិនបាន វានឹងសាបបន្តិចម្តង។

នៅមានមួយចំណុចទៀត គឺការគិតរបស់ពួកគេមកលើយើង។ អ្នកដែលមិនឈប់ អាចមកពីគេមិនទាន់ដល់ពេលឈប់ ឬមិនចង់ឈប់តែម្តង។ បើគេស្មោះស្ម័គ្រនឹងក្រុមហ៊ុន ហើយចង់ធ្វើការរហូតដល់ចាស់ ការលាឈប់របស់យើង ប្រៀបដូចជាការក្បត់ក្រុមហ៊ុន។ គេអាចនឹងគិតថា យើងជាមនុស្សមិនស្មោះត្រង់។ ដូចខ្ញុំប្រាប់ហើយ មនុស្សច្រើនណាស់ប្រើពាក្យស្មោះត្រង់ និងស្មោះស្ម័គ្រច្រឡំគ្នា។ ភាពស្មោះត្រង់ ជាកាតព្វកិច្ចរបស់មនុស្ស តែភាពស្មោះស្ម័គ្រមិនមែនទេ។

ទំនាក់ទំនងក្រោយពេលលាឈប់ អាចមិនល្អដូចមុនទេ ហេតុនេះយើងគួរតែដឹងឱ្យហើយ។ វាអាចនឹងបាត់បង់នៅថ្ងៃណាមួយ។ ខ្ញុំអាចនឹងខុសត្រង់ចំណុចនេះ តែមិនអីទេ ព្រោះខ្ញុំមិនប្រកាន់នឹងសរសេរខុសទេ ឱ្យតែអ្វីដែលខ្ញុំសរសេរ ចេញពីបទពិសោធន៍ខ្លួនឯង។ យ៉ាងហោចណាស់ ខ្ញុំមិនបាច់ធ្វើពុតដឹង ទាំងខ្លួនមិនធ្លាប់ឆ្លងកាត់។

# ទំព័រចុងក្រោយ

អ្នកទាំងអស់គ្នាអានចប់សៀវភៅមួយក្បាលទៀតហើយ។ តើទទួលបានអ្វីខ្លះ? តើមានគំនិតប្រឆាំងដែរទេ? តើមានកន្លែងមិនយល់ដែរទេ? តើយល់ថាសៀវភៅនេះល្អដែរទេ? សំណួរទាំងនេះ ឆ្លុះបញ្ចាំងពីប្រយោជន៍នៃការអានសៀវភៅ។

ខ្ញុំមិនរំពឹងថា សៀវភៅរបស់ខ្ញុំសរសេរត្រូវគ្រប់ចំណុចទេ តែវាអាចជាដើមទុនខ្លះដល់អ្នកដែលធ្វើការឱ្យគេ។ យើងត្រូវធ្វើការឱ្យឆ្លាត និងកុំឱ្យខ្លួនឯងជំពាក់ក្នុងមហិច្ឆតារបស់អ្នកដទៃ។ យើងមិនមែនកើតមកដើម្បីអ្នកដទៃទេ។

ខ្ញុំសូមអរគុណអ្នកដែលបានជួយទិញសៀវភៅរបស់ខ្ញុំ និងគាំទ្រស្នាដៃផ្សេងទៀតរបស់ខ្ញុំ។ ខ្ញុំធ្លាប់សរសេរនៅក្នុងសៀវភៅមុនៗរបស់ខ្ញុំថា "ការគាំទ្ររបស់អ្នកទាំងអាន ជាកម្លាំងចិត្តដែលធ្វើឱ្យខ្ញុំប្រឹងសរសេរសៀវភៅថ្មីទៀត"។ ការគាំទ្រ ជារឿងល្អ តែកម្លាំងចិត្តដែលបានមកពីការគាំទ្រ មិនអាចនៅបានយូរទេ។ បើថ្ងៃណាមួយ ខ្ញុំសរសេររិះគន់ពីរឿងអ្វីមួយដែលគេមិនពេញចិត្ត គេក៏ឈប់គាំទ្រខ្ញុំដែរ។ ខ្ញុំច្បាស់ថា ថ្ងៃណាមួយខ្ញុំនឹងសរសេរសៀវភៅបែបនោះ។ បើអស់ការគាំទ្រ តើខ្ញុំអស់កម្លាំងចិត្តក្នុងការសរសេរទេ? មិនអស់ទេ ព្រោះកម្លាំងចិត្តខ្ញុំ ចេញពីខ្លួនខ្ញុំ។

ការគាំទ្រអ្នកអាន ជាកម្លាំងចិត្តរបស់អ្នកអាន។ ពួកគេគាំទ្រអ្នកនិពន្ធ ក៏ដូចជាគាំទ្រការអានរបស់ខ្លួនឯងដែរ។ ខ្ញុំមិនចង់យកការគាំទ្រ មកធ្វើជាកម្លាំងជម្រុញចិត្តខ្លួនឯងទេ។ ខ្ញុំចង់ធ្វើដូចពីមុន ពេលដែលគ្មានអ្នកគាំទ្រខ្ញុំ តែនៅតែអាចសរសេរសៀវភៅបាន។

បើមានមិត្តភក្តិជាខ្ញុំគេដែរ អាចណែនាំឱ្យគេអានសៀវភៅនេះបាន។ ចែកគ្នាដឹងខ្លះ ក៏ល្អដែរ។ បើពួកគេអាចមានសេរីភាព គេមិនអរគុណខ្ញុំទេ តែគេនឹងអរគុណអ្នកដែលជួយឱ្យគេអានសៀវភៅនោះប៉ុណ្ណោះ។

**ខ្ញុំគេ គួរអានសៀវភៅទាក់ទងនឹងភាពជាខ្ញុំគេ។**